ក្រសួងបរិស្ថាន
MINISTRY OF ENVIRONMENT

ទស្សនាវដ្ដីបរិស្ថាន

ឆ្នាំទី៨ លេខទី១ ឆ្នាំ២០២២

មាតិកា

៣ ផ្នែកទី១៖ សកម្មភាពឯកឧត្តមរដ្ឋមន្ត្រី

៥៥ ផ្នែកទី២៖ សកម្មភាពថ្នាក់ដឹកនាំ

៨០ ផ្នែកទី៣៖ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

៨៤ ផ្នែកទី៤៖ សំណល់រឹង និងសារធាតុគ្រោះថ្នាក់

៩៤ ផ្នែកទី៥៖ រូបភាពសត្វកម្រ

៩៨ ផ្នែកទី៦៖ ចម្រៀងបរិស្ថាន

នាយកដ្ឋានព័ត៌មាន និងផ្សព្វផ្សាយបរិស្ថាន

អគ្គនាយកដ្ឋាន ចំណេះដឹង និងព័ត៌មានបរិស្ថាន

អារម្ភកថា

ក្នុងនាមក្រុមការងាររៀបចំ និងចងក្រងទស្សនាវដ្តីបរិស្ថាន ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក ដែលបានចែករំលែកជូនសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី មិត្តអ្នកអានជាទីគោរពរាប់អាន តាមរយៈ អត្ថបទ រូបភាព ឯកសារព័ត៌មានសំខាន់ៗប្រចាំឆមាស នៃទស្សនាវដ្តីបរិស្ថាន ឆ្នាំទី៨ លេខទី១ (មករា-មិថុនា ឆ្នាំ២០២២) របស់ក្រសួងបរិស្ថាននេះ។

បរិស្ថាន មានទំនាក់ទំនងជិតស្និតជាមួយវិស័យសេដ្ឋកិច្ច និងសង្គម ជាពិសេសជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ក្នុងពេលថ្មីៗនេះ យើងសង្កេតឃើញការផ្លាស់ប្តូរឥរិយាបថរបស់ប្រជាពលរដ្ឋក្នុងការចូលរួមប្រតិបត្តិមេត្រីភាពបរិស្ថានក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដូចជាការចូលរួមកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ការទុកដាក់សំរាម ការចូលរួមការពារ និងអភិរក្សធនធានធម្មជាតិ ការចូលរួមដាំស្តារព្រៃឡើងវិញ ការច្នៃប្រឌិត និងការគិតគូរខ្ពស់ចំពោះការរស់នៅ និងសុខភាពនៅតាមសហគមន៍។

ទស្សនាវដ្តីបរិស្ថាន ឆ្នាំទី៨ លេខទី១ (មករា-មិថុនា ឆ្នាំ២០២២) ដែលសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី មិត្តអ្នកអាន កំពុងកាន់នៅក្នុងដៃនេះ បានប្រមូលចងក្រងនូវព្រឹត្តិការណ៍សំខាន់ៗ ទាក់ទងទៅនឹងការសម្របខ្លួន និងការចូលរួមក្នុងការសម្រេចចិត្តរបស់កម្ពុជាក្នុងតំបន់ និងពិភពលោកចំពោះការគ្រប់គ្រង បរិស្ថានឱ្យមាននិរន្តរភាព និងការអភិវឌ្ឍដោយចីរភាពបន្ថែមលើកិច្ចខិតខំប្រឹងប្រែង និងសមិទ្ធផលផ្នែកសេដ្ឋកិច្ច-សង្គមជាច្រើនរបស់ក្រសួងបរិស្ថានដែលសម្រេចបានក្នុងឆ្នាំ២០២២។

ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ប៉ិនប្រសព្វ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាដែលបានដាក់ចេញនូវគោលនយោបាយដ៏ត្រឹមត្រូវជាពិសេស "គោលនយោបាយឈ្នះ-ឈ្នះ" និងយុទ្ធសាស្ត្រចតុកោណជាដំណាក់កាលបន្តបន្ទាប់ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិជាច្រើនទៀត ដែលជាការធ្វើឱ្យសេដ្ឋកិច្ចរឹងមាំ កាអភិវឌ្ឍន៍លើគ្រប់វិស័យជាពិសេស បានផ្តល់ជូនប្រជាពលរដ្ឋមានជីវភាពល្អប្រសើរ និងមានការគិតគូរចំពោះបរិស្ថានខ្ពស់ជាងមុន។

ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួងបរិស្ថាន និងមិត្តអ្នកអាន ដែលបានគាំទ្រដល់ការរៀបចំទស្សនាវដ្តីបរិស្ថាន និងសហការចែករំលែកព័ត៌មានបរិស្ថាន ក្នុងគោលបំណងផ្តល់ព័ត៌មានឱ្យកាន់តែទូលំទូលាយ និងចំណេះដឹងថ្មីៗបន្ថែមទៀត ដើម្បីបង្កើនការគិតវិជ្ជមានចំពោះបរិស្ថាន និងការអភិវឌ្ឍដោយចីរភាព បន្ទាប់ពីចេញផ្សាយទស្សនាវដ្តីរៀងរាល់លេខ នាពេលកន្លងមក៕

ក្រុមការងាររៀបចំ និងចងក្រងទស្សនាវដ្តីបរិស្ថាន

ផ្នែកទី ១
សកម្មភាពឯកឧត្តមរដ្ឋមន្ត្រី

ឯកឧត្តម សាយ សំអាល់ ជួបសំណេះសំណាលជាមួយបងប្អូនខ្មែរអ៊ិស្លាម នៅស្រុកព្រៃនប់ ខេត្តព្រះសីហនុ

«សម័យតេជោសន្តិភាព គឺជាឱកាសមាសសម្រាប់បងប្អូនខ្មែរអ៊ិស្លាមអាចគោរពប្រតិបត្តិសាសនា ជាមួយនឹងសិទ្ធិសេរីភាព បង្ហាញអត្តសញ្ញាណខ្លួនឯងបានយ៉ាងពេញលេញ»។

នេះជាប្រសាសន៍របស់ **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ ថ្លែងក្នុងឱកាសពិសាអាហារសាមគ្គីជាមួយបងប្អូនខ្មែរអ៊ិស្លាម នៅឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នៅព្រឹកថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២។ ពិធីនេះ ក៏មានការអញ្ជើញចូលរួមពីឯកឧត្តម តឹករ៉េត សំរេច រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ឯកឧត្តម គួច ចំរើន អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រីជាក្រុមការងារចុះមូលដ្ឋានខេត្តព្រះសីហនុ និងបងប្អូនខ្មែរអ៊ិស្លាមជាច្រើនរូបទៀត។

មានមតិសំណេះសំណាល **ឯកឧត្តម សាយ សំអាល់** បានគូសបញ្ជាក់ឱ្យដឹងទៀតថា កម្ពុជាជាប្រទេសពហុវប្បធម៌ ដែលបើកទូលាយ និងផ្តល់សិទ្ធិសេរីភាពពេញលេញដល់ប្រជាពលរដ្ឋគ្រប់រូបក្នុងការគោរពប្រតិបត្តិសាសនាដែលខ្លួនពេញចិត្ត។ ជាក់ស្តែងបច្ចុប្បន្ន បងប្អូនខ្មែរអ៊ិស្លាម មិនត្រឹមតែអាចប្រតិបត្តិសាសនាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានសិទ្ធិពេញលេញក្នុងការស្លៀកពាក់សម្លៀកបំពាក់ប្រពៃណី រៀនភាសា ឬ ការសាងសង់វិហារសាសនារបស់ខ្លួន ដោយគ្មានការរើសអើង និងឃាត់ឃាំងឡើយ។

ឯកឧត្តម បានឱ្យដឹងទៀតថា ទោះបីជាបងប្អូនខ្មែរអ៊ិស្លាម មានសិទ្ធិក្នុងការគោរពជំនឿសាសនាក៏ដោយ ប៉ុន្តែត្រូវធ្វើយ៉ាងណា ពង្រឹងសមត្ថភាពខ្លួន ដើម្បីជាកោសិកាល្អក្នុងសង្គម ដែលអាចចូលរួមក្នុងបុព្វហេតុកសាង និងអភិវឌ្ឍន៍ជាតិបន្តរីកចម្រើនទៅមុខទៀត។ ប្រមុខរាជរដ្ឋាភិបាល តែងតែយកចិត្ត

ទុកដាក់ដល់បងប្អូនខ្មែរអ៊ិស្លាម មិនត្រឹមតែមានតួនាទីនៅក្នុងសហគមន៍របស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ឱកាសក្នុងការធ្វើការងារ តួនាទីដឹកនាំទាំងក្នុងក្របខ័ណ្ឌរដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិផងដែរ។

ឆ្លៀតក្នុងឱកាសនោះដែរ **ឯកឧត្តម សាយ សំអាល់** បានថ្លែងអំណរគុណដល់បងប្អូនខ្មែរអ៊ិស្លាមទាំងអស់ ដែលបានទៅចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ កន្លងទៅ ដែលនេះបានបង្ហាញពីការអនុវត្តសិទ្ធិជាពលរដ្ឋរបស់បងប្អូនក្នុងការជ្រើសរើសមេដឹកនាំដែលបងប្អូនពេញចិត្តស្របតាមដំណើរនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាផងដែរ៕

ឯកឧត្តម សាយ សំអាល់ អញ្ជើញជាអធិបតីបើកបវេសនកាលឆ្នាំសិក្សា២០២១-២០២២ នៅវិទ្យាល័យហ៊ុន សែន វាលរេញ

ថ្លែងក្នុងឱកាសបើកបវេសនកាលឆ្នាំសិក្សាថ្មី២០២១-២០២២ នៅវិទ្យាល័យហ៊ុន សែន វាលរេញ ក្នុងស្រុកព្រៃនប់ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃចន្ទ ទី១០ ខែមករា ឆ្នាំ២០២២ **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ មានប្រសាសន៍ថា អប់រំជាឈ្នាន់យុទ្ធសាស្ត្រក្នុងការកសាងធនធានមនុស្សនិងរំលេចនូវទេពកោសល្យរបស់បុគ្គលម្នាក់ៗ ដែលអាចចូលរួមកសាងសេដ្ឋកិច្ច និងជានាការទាញប្រយោជន៍ពីការអភិវឌ្ឍរបស់ខេត្តព្រះសីហនុ។

តាមរយៈនេះ **ឯកឧត្តមរដ្ឋមន្ត្រី** លើកឡើងពីការគាំទ្រ របស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍខេត្តព្រះសីហនុឱ្យក្លាយជាតំបន់សេដ្ឋកិច្ចគំរូពហុបំណងដែលជាសក្តានុពលយ៉ាងសំខាន់របស់ប្រទេសកម្ពុជា និងផ្តល់ប្រយោជន៍ដល់ប្រជាពលរដ្ឋ នៅក្នុងខេត្តព្រះសីហនុ។

ឯកឧត្តមរដ្ឋមន្ត្រី បានលើកទឹកចិត្តឱ្យស្ថាប័នមន្ទីរ អង្គភាព អាជ្ញាធរដែនដី សហគមន៍ និងប្រជាពលរដ្ឋគ្រប់រូប យកចិត្តទុកដាក់ និងចូលរួមគាំទ្រឲ្យបានខ្លាំងក្លាបន្ថែមទៀត ក្នុងការអភិវឌ្ឍសាលារៀន ដូចជាការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត កន្លែងលេងកីឡា ការថែរក្សាអនាម័យ និងបរិស្ថាន និងការគាំទ្រផ្សេងទៀត តាមគ្រប់លទ្ធភាព ជាពិសេសការចូលរួមពីដៃគូ ដើម្បីអភិវឌ្ឍន៍សាលារៀន និងបង្កើនធនធានមនុស្សឆ្ពោះទៅកាន់អនាគត។ ពិសេសបន្ថែមទៀត ដំណើរការបង្រៀន និងរៀន ត្រូវមានភាពទន់ភ្លន់ អាស្រ័យទៅតាមទីតាំងភូមិសាស្ត្រ និងស្ថានភាពអប់រំដែលឆ្លើយតបទៅនឹងទីផ្សារការងារ ដោយអនុវត្តវិធីសាស្ត្ររៀន និងបង្រៀនតាមបែបបច្ចេកវិទ្យាទំនើប។

សូមបញ្ជាក់ថា **ឯកឧត្តម សាយ សំអាល់** បានអញ្ជើញជាអធិបតីបើកបវេសនកាលឆ្នាំសិក្សា២០២១-២០២២ នៅខេត្តព្រះសីហនុ រួមដំណើរដោយឯកឧត្តម គួច ចំរើន អភិបាលនៃគណៈអភិបាលខេត្ត ព្រះសីហនុ លោកជំទាវ យុន រចនា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងថ្នាក់ដឹកនាំក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ តំណាងរាស្ត្រ ថ្នាក់ដឹកនាំក្រសួងបរិស្ថាន ប្រធាន-អនុប្រធានមន្ទីរអង្គភាពជុំវិញខេត្ត ដៃគូអភិវឌ្ឍន៍ សហគមន៍ បុគ្គលិកអប់រំ និងសិស្សានុសិស្សជាច្រើននាក់ នៅវិទ្យាល័យ ហ៊ុន សែន វាលរេញ ក្នុងស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ ក្នុងឱកាសនោះ **ឯកឧត្តម** ក៏បានអញ្ជើញផ្តល់ឧបករណ៍គ្រប់គ្រងអនាម័យ ដែលផ្តល់ជូនដោយមូលនិធិព្រីនស៍ និងអង្គការផ្លែនអន្តរជាតិ ព្រមទាំងផ្តល់ជូនថវិកា និងសម្ភារៈសិក្សាដល់គណៈគ្រប់គ្រងសាលា លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស ព្រមទាំងមាតាបិតាសិស្សដែលបានចូលរួមផងដែរ។

ឯកឧត្តម សាយ សំអាល់ ជួបសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ នៅវិទ្យាល័យសាគូរ៉ា

មានមតិសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ ក្នុងឱកាសអញ្ជើញចុះពិនិត្យសាលាបឋមសិក្សា និងអនុវិទ្យាល័យសាគូរ៉ា **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុបានថ្លែងថា លោកគ្រូ អ្នកគ្រូ មិនត្រឹមតែបង្ហាត់បង្រៀនកូនសិស្សឱ្យក្លាយជាមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ ឬបុគ្គលិកក្រុមហ៊ុនឯកជនប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវបង្រៀនកូនសិស្សឱ្យចេះរកចំណូល ដោយបណ្តុះគំនិតកូនសិស្សឱ្យមានចរិត កាយវិការ និងចិត្តសហគ្រិនភាពក្នុងខ្លួន ហើយនេះ គឺជារឿងសំខាន់។

ឯកឧត្តម សាយ សំអាល់ ឱ្យដឹងទៀតថា ដើម្បីឱ្យមានសហគ្រិនភាព **ឯកឧត្តម** នឹងជួយលើវិស័យសិក្សាមួយចំនួនដល់សិស្សានុសិស្សនៅខេត្តព្រះសីហនុ រួមមាន វិទ្យាសាស្ត្រ បច្ចេកវិទ្យា បច្ចេកទេស គណិតវិទ្យា ឬកម្មវិធីសាលាជំនាន់ថ្មី រួមទាំងសិក្សាលើសិល្បៈ ប្រវត្តិសាស្ត្រ សង្គមជាដើម។ ឯកឧត្តមប្រធានក្រុមការងារបានគូសបញ្ជាក់ឱ្យដឹងទៀតថា ខេត្តព្រះសីហនុជាខេត្តសំខាន់ ជាខេត្តទេសចរណ៍ ជាតំបន់សេដ្ឋកិច្ចពិសេសដែលមានកំពង់ផែ និងអាកាសយានដ្ឋាន ដែលអាចចាត់ទុកថា ជាខេត្តរកចំណូលធំមួយសម្រាប់ប្រទេសកម្ពុជា ហេតុនេះ អ្នកខេត្តព្រះសីហនុត្រូវតែពូកែទាំងចំណេះ ជំនាញ ហើយអាចប្រើប្រាស់ភាសាយ៉ាងតិច២ភាសា ក្រៅពីភាសាខ្មែរដែលជាភាសាកំណើត ក្នុងនោះភាសាអង់គ្លេសជាភាសាចំណេះដឹង និងភាសាចិនជាភាសាពាណិជ្ជកម្ម ដែលទាំងអស់នេះគឺផ្តើមចេញពីការអប់រំ។

គួរបញ្ជាក់ឱ្យដឹងថា ការចុះពិនិត្យ និងជួបសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូនៃសាលាបឋមសិក្សា និងអនុវិទ្យាល័យសាគូរ៉ា ស្ថិតនៅសង្កាត់លេខ១ ក្រុងព្រះសីហនុ នាព្រឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២នេះ ក៏មានការអញ្ជើញចូលរួមពីឯកឧត្តម ឈិន ចាន់ពណ៌ អនុប្រធានក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋានក្រុងព្រះសីហនុ ឯកឧត្តមអិបាលរងខេត្ត អភិបាលក្រុងព្រះសីហនុ ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋានខេត្តព្រះសីហនុ សមាជិកក្រុមប្រឹក្សាខេត្ត អង្គភាពជុំវិញខេត្ត រដ្ឋបាលសង្កាត់លេខ១ លោកគ្រូអ្នកគ្រូជាច្រើនរូបទៀត៕

ឯកឧត្តម សាយ សំអាល់ ជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ វិហារកាតូលិក ក្រុងព្រះសីហនុ

«សង្គមកម្ពុជាជាសង្គមមួយដែលសាសនាណាក៏អាចលូតលាស់បាន និងទទួលយកបានគ្រប់ជាតិសាសន៍ ដែលយើងអាចនិយាយបានថា នៅលើពិភពលោកមិនមានច្រើនទេ»។ នេះជាប្រសាសន៍លើកឡើងរបស់ **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ ក្នុងឱកាសជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំវិហារកាតូលិក ក្រុងព្រះសីហនុ នាព្រឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២។

ឯកឧត្តម សាយ សំអាល់ បញ្ជាក់ឱ្យដឹងទៀតថា កម្ពុជាមានសង្គមមួយដែលមានពហុវប្បធម៌។ ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិសេរីភាពពេញលេញ ក្នុងការគោរពប្រតិបត្តិសាសនាទៅតាមជំនឿរៀងៗខ្លួន។ ការគោរពព្រះជារឿងសំខាន់ មិនថាសាសនាណាក៏ដោយ ព្រោះព្រះនៅក្នុងសាសនា គឺអប់រំមនុស្សឱ្យសាងអំពើល្អ គិតល្អ និងជាពន្លឺបំភ្លឺជីវិតដល់អ្នកមានជំនឿ។

ឯកឧត្តម បានលើកឡើងទៀតថា សាសនាក៏មានតួនាទីសំខាន់ក្នុងការកែប្រែ ឬផ្លាស់ប្តូរផ្នត់គំនិតរបស់មនុស្សឆ្ពោះទៅកាន់ផ្លូវត្រូវក្នុងខ្សែជីវិតរបស់ខ្លួនផងដែរ។

គួរបញ្ជាក់ថា **ឯកឧត្តម សាយ សំអាល់** អញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំវិហារកាតូលិក ក្រុងព្រះសីហនុ ដោយមានការចូលរួមពីឯកឧត្តមអភិបាលរងខេត្តព្រះសីហនុ ឯកឧត្តមអភិបាលក្រុង ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ ជាច្រើនរូប៕

ឯកឧត្តម សាយ សំអាល់ លើកឡើងអំពីចំណងមិត្តភាពពិសេសរវាងកម្ពុជា និងជប៉ុន

ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម TAKAHASHI ប្រធានសមាគម កម្ពុជា ជប៉ុន (Japan-Cambodia Association) នៅទីស្តីការក្រសួងបរិស្ថាន ។

នៅក្នុងឱកាសនោះ **ឯកឧត្តមរដ្ឋមន្ត្រី** បានស្វាគមន៍ និងថ្លែងអំណរគុណចំពោះសមាគមកម្ពុជាជប៉ុន ដែលកន្លងមកបានចូលរួមចំណែកចំពោះកិច្ចគាំពារវិស័យបរិស្ថាន តាមរយៈការផ្តល់នូវរថយន្តដឹកសំរាមចំនួន១០គ្រឿងជារៀងរាល់ឆ្នាំ គិតចាប់ពីឆ្នាំ២០២០មក សរុបមកដល់ពេលនេះចំនួន២០គ្រឿង និងគ្រោងផ្តល់ក្នុងឆ្នាំ២០២២នេះ ចំនួន១០គ្រឿងទៀត ដែលផ្តល់ឱកាសឱ្យក្រសួងបានប្រគល់បន្តទៅតាមបណ្តាក្រុងស្រុកនៅទូទាំងប្រទេសក្នុងការអនុវត្តអនុក្រឹតលេខ១១៣ ក្នុងការធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាមទៅថ្នាក់ក្រោមជាតិ។

ជាការឆ្លើយតប ឯកឧត្តម TAKAHASHI បន្តថា ខាងសមាគមនឹងស្វែងរកដៃគូវិនិយោគបន្ថែមមកកម្ពុជា ជួយខាងផ្នែកសម្ភារៈផ្សេងៗដល់ក្រសួងបរិស្ថាន។

ជាមួយគ្នានេះ **ឯកឧត្តមរដ្ឋមន្ត្រី** បានលើកទឹកចិត្តឱ្យសមាគមរកបន្ថែមនូវសមាជិក ដៃគូសហប្រតិបត្តិការ ជាមួយសហគ្រិនវ័យក្មេង និងសភាពាណិជ្ជកម្មកម្ពុជា ដើម្បីចូលរួមជាមួយក្រសួងបរិស្ថានក្នុងការរកទីផ្សារផលិតផលគ្រាប់ស្វាយចន្ទី និងតម្បាញសូត្រ ជូនប្រជាសហគមន៍ក្នុងតំបន់ការពារធម្មជាតិនៅទូទាំងប្រទេស៕



ឯកឧត្តម សាយ សំអាល់ ជួបពិភាក្សាតាមរយៈប្រព័ន្ធវីដេអូជាមួយទីប្រឹក្សាគោលនយោបាយនៃចក្រភពអង់គ្លេស

«រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងបរិស្ថានជាសេនាធិការលើកិច្ចការបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព បាននិងកំពុងបន្ត ជំរុញការអនុវត្តកម្មវិធីកំណែទម្រង់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍និងអ្នកជំនាញពាក់ព័ន្ធ ដោយផ្តោតលើការចូលរួមពង្រឹងមូលដ្ឋានសេដ្ឋកិច្ច ការរៀបចំសង្គមកម្ពុជាសម្របទៅនឹងនិន្នាការសកល និងការធានាបាននូវការអភិវឌ្ឍជាតិប្រកបដោយនិរន្តរភាព ភាពបៃតង បរិយាប័ន្ន និងតុល្យភាពរវាងអាទិភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌» នេះជាការលើកឡើងរបស់ **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន នៅក្នុងជំនួបតាមប្រព័ន្ធវីដេអូពីចម្ងាយ ជាមួយលោក Stefan Dercon ទីប្រឹក្សាគោលនយោបាយនៃរដ្ឋមន្ត្រីការបរទេសកំមិនវេល និងអភិវឌ្ឍន៍នៃចក្រភពអង់គ្លេស កាលពីរសៀលថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២។

ឯកឧត្តមរដ្ឋមន្ត្រី បានគូសបញ្ជាក់ថា សុខសន្តិភាព និងស្ថិរភាពនយោបាយពេញលេញ ក្រោយការអនុវត្តគោលនយោបាយឈ្នះ-ឈ្នះ ព្រមទាំងមាគ៌ាដឹកនាំនយោបាយដ៏ត្រឹមត្រូវ កម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជា យុទ្ធសាស្ត្រត្រីកោណ យុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិជាបន្តបន្ទាប់ បានអនុញ្ញាតឱ្យកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ជាប្រចាំប្រមាណ៧% ក្នុងមួយឆ្នាំ ក្នុងរយៈពេលជាង២០ឆ្នាំ មុនវិបត្តិជំងឺកូវីដ-១៩ និងបានបង្កលក្ខណៈឱ្យមានការកើនឡើងខ្លាំងនូវភាគរយនៃប្រជាពលរដ្ឋមានជីវភាពកម្រិតកណ្តាល និងមានការអប់រំខ្ពស់ ដែលនេះជាតម្រូវការ និងសេចក្តីប៉ងប្រាថ្នាចង់បានឱ្យប្រជាពលរដ្ឋចេះយល់ដឹងពីគុណភាពជីវិតកាន់តែប្រសើរ និងមានចំណាប់អារម្មណ៍កាន់តែខ្លាំងទៅលើគុណភាពបរិស្ថាន។

ដោយឈរលើមូលដ្ឋាន នៃសមិទ្ធផល និងនិន្នាការសង្គម

ទាំងនេះ កម្ពុជា បាននិងកំពុងពង្រឹងតួនាទីជាម្ចាស់ និងឯករាជ្យភាពក្នុងការកំណត់គោលនយោបាយ និងអាទិភាពអភិវឌ្ឍន៍ជាតិ ដោយសម្លឹងឆ្ពោះទៅកាន់ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និងឆ្នាំ២០៥០ ហើយកម្ពុជាសង្ឃឹមថា កិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូជាមួយកម្ពុជានឹងអាចក្លាយទៅជាគំរូមួយក្នុងការភ្ជាប់ទំនាក់ទំនងរវាងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍។

ជាការឆ្លើយតប លោក Stefan Dercon បានកោតសរសើរចំពោះ កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែល ដាក់ចេញនូវគោលនយោបាយ ប្រកបដោយប្រសិទ្ធភាព ភាពស៊ីសង្វាក់ និងសង្គតិភាព និងរក្សាបាននូវការអភិវឌ្ឍគួរឱ្យកត់សម្គាល់នេះ។ ចក្រភពអង់គ្លេសត្រៀមខ្លួនជាស្រេច ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូពិតប្រាកដជាមួយកម្ពុជា ជាពិសេសលើគោលនយោបាយវិស័យបរិស្ថាន៕

ក្រសួងបរិស្ថានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយលទ្ធផលកិច្ចប្រជុំសន្និសីទកំពូលបណ្តាភាគីអនុសញ្ញាសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុលើកទី២៦

ក្រសួងបរិស្ថាន បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយលទ្ធផលកិច្ចប្រជុំសន្និសីទកំពូលបណ្តាភាគីអនុសញ្ញាសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុលើកទី២៦ (COP26) ក្រោមអធិបតីភាព **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ដោយមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងស្ថាប័នស្រាវជ្រាវ។ គោលបំណងសំខាន់ នៃកិច្ចប្រជុំគឺដើម្បីផ្សព្វផ្សាយលទ្ធផលសំខាន់ៗនៃកិច្ចប្រជុំ COP26 ដែលរៀបចំឡើងនៅចក្រភពអង់គ្លេស កាលពីថ្ងៃទី៣១ ខែតុលា ដល់ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១។

ក្នុងនោះ **ឯកឧត្តមរដ្ឋមន្ត្រី** បានបានគូសបញ្ជាក់ចំណុចសំខាន់ៗចំនួន៥ចំណុចរួមមាន៖

១)យន្តការនៃការលក់កាបូនៈ បច្ចុប្បន្នកម្ពុជាបានជោគជ័យក្នុងការលក់ឥណទានកាបូនព្រៃឈើពីគម្រោងREDD+ ហើយថវិកាដែលទទួលបាននឹងប្រើប្រាស់ដើម្បីការការពារព្រៃឈើ លើកកម្ពស់កម្រិតជីវភាព និងសុខមាលភាពប្រជាជននៅមូលដ្ឋាន។ ក្រសួងបរិស្ថានក៏កំពុងរៀបចំនីតិវិធីដើម្បីផ្តល់ហិរញ្ញប្បទានដែលបានមកពីការលក់កាបូននេះជូនដល់ថ្នាក់ក្រោមជាតិដែលជាអ្នកអនុវត្តផ្ទាល់នាពេលខាងមុខ។

២)លើកទឹកចិត្តឱ្យថ្នាក់ក្រោមជាតិឱ្យចូលរួមក្នុងកិច្ចប្រជុំCoP នៅពេលខាងមុខ ដែលជាឱកាសក្នុងការកៀគរធនធានហិរញ្ញប្បទានអាកាសធាតុ ដើម្បីអភិវឌ្ឍន៍នៅមូលដ្ឋាន និងពិនិត្យមើលលើឱកាសក្នុងកិច្ចសហប្រតិបត្តិការទ្វេភាគី ពីសំណាកបណ្តាប្រទេសនានាផងដែរ ដោយបច្ចុប្បន្នកម្ពុជាអាចមានលទ្ធភាពច្រើនក្នុងការទាញយក

ហិរញ្ញប្បទានចេញពីមូលនិធិប្រែប្រួលអាកាសធាតុ តាមរយៈគម្រោងតូចៗនៅថ្នាក់ក្រោមជាតិ ដែលមានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ក្រសួងបរិស្ថាន លើកទឹកចិត្ត និងត្រៀមខ្លួនសហការសម្របសម្រួលជាមួយរដ្ឋបាលស្រុក ខេត្ត ក្នុងការរៀបចំស្នើសុំប្រើប្រាស់កញ្ចប់មូលនិធិនេះ ដើម្បីការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍនៅមូលដ្ឋាន។

៣)ធនាគារៈ យើងអាចទាញយកឱកាសក្នុងការទាញយកប្រភពហិរញ្ញប្បទានដែលមានការប្រាក់ទាប ដោយផ្សារភ្ជាប់នឹងបរិស្ថាន និងការអភិវឌ្ឍន៍បៃតង។

៤) ការប្រែប្រួលអាកាសធាតុបានក្លាយទៅជាបញ្ហានយោបាយ និងសេដ្ឋកិច្ច ដូច្នេះយើងគួរពង្រឹងការផ្សព្វផ្សាយទាំងថ្នាក់ជាតិ និងអន្តរជាតិអំពីការខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការចូលរួមឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងបញ្ហាបរិស្ថាន។

៥)ការដាក់បញ្ចូលឬបន្សីលទ្ធផលកិច្ចប្រជុំសំខាន់ទៅក្នុងគោលនយោបាយ ផែនការយុទ្ធសាស្ត្ររបស់ជាតិ៕

ឯកឧត្តម សាយ សំអាល់ អញ្ជើញជាអធិបតីប្រកាសជាផ្លូវការ និងប្រគល់សៀវភៅ យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន ដល់ស្ថាប័នពាក់ព័ន្ធ

ក្នុងឱកាសអញ្ជើញជាអធិបតី ក្នុងពិធីប្រកាសជាផ្លូវការនិងប្រគល់សៀវភៅយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២ នាទីស្ដីការក្រសួងបរិស្ថាន **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន សូមវាយតម្លៃខ្ពស់ និងអបអរសាទរដល់ក្រុមការងារក្នុងការកសាង "យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែង ប្រកបដោយអព្យាក្រឹតកាបូន – Cambodia's Long Term Strategy for Carbon Neutrality (LTS4CN)" បានទាន់ពេលវេលា ប្រកបដោយជោគជ័យ។ ជាមួយគ្នានេះ **ឯកឧត្តម** ក៏សូមថ្លែងអំណរគុណដល់ដៃគូរពាក់ព័ន្ធ ចំពោះចូលរួមដ៏មានសារៈសំខាន់មិនអាចខ្វះបាន ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រនេះឡើង។

ឯកឧត្តម បានគូសបញ្ជាក់ថា យុទ្ធសាស្ត្រដែលមានក្នុងសៀវភៅនេះ បង្ហាញនូវការប្ដេជ្ញាចិត្តដ៏មោះមុតរបស់កម្ពុជាចំពោះប្រជាជនខ្លួន និងចំពោះពិភពលោកទាំងមូល។ ផ្ដើមចេញពីការដឹកនាំប្រទេសប្រកបដោយភាពភាពឈ្លាសវៃ និងសុខសន្តិភាពដែលអាចឱ្យកម្ពុជាឈានមកគិតគូរពីបរិស្ថាន និងដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូននេះឡើង។ បន្ថែមលើនេះ កម្ពុជាដែលធ្លាប់ឆ្លងកាត់នូវភ្នក់ភ្លើងសង្គ្រាមបានប្រែមកជាប្រទេសចែករំលែកនូវដំណោះស្រាយដើម្បីស្វែងរក និងរក្សាឱ្យបាននូវសន្តិភាពពេញលេញ។

យុទ្ធសាស្ត្រនេះបានដាក់ចេញនូវវិស័យសំខាន់ៗចំនួន៦រួមមាន (១)កសិកម្ម (២)ព្រៃឈើនិងការប្រើប្រាស់ដីផ្សេងទៀត (៣)ថាមពល (៤)ការដឹកជញ្ជូន (៥)ឧស្សាហកម្មនិងការប្រើប្រាស់ផលិតផល និង(៦)ការគ្រប់គ្រងសំណល់ ដែលឈរលើមូលដ្ឋានវិទ្យាសាស្ត្រ និងភាពប្រាកដនិយម ដែលកម្ពុជាបាននិងកំពុងធ្វើដើម្បីសម្រេចឱ្យបាននូវគោលដៅអព្យាក្រឹតកាបូន ត្រឹម៣០ឆ្នាំខាងមុខ។ នេះគឺជាលើកទី១ ដែលកម្ពុជាបង្កើតបាននូវឯកសារយុទ្ធសាស្ត្ររយៈពេលវែងក្នុងការសម្រេចនូវអព្យាក្រឹតកាបូន នៅឆ្នាំ២០៥០ ដែលនេះគឺស្របនឹងគោលដៅប្រែក្លាយកម្ពុជាទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងចំណូលខ្ពស់នៅឆ្នាំ២០៥០ និងផែនការបរិស្ថានជាតិផ្សេងទៀត៕

Launch of
/ Organized by

/ Organized by
/ Supported by
CAMBODIA CLIMATE CHANGE ALLIANCE

Launch of

Launch of
/ Organized by
/ Supported by

ឯកឧត្តម សាយ សំអាល់ អញ្ជើញចុះត្រួតពិនិត្យការងារគ្រប់គ្រងធនធានធម្មជាតិ និងជីវៈចម្រុះនៅតំបន់ការពារធម្មជាតិ ក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ

«សូមបងប្អូនជាមន្ត្រីនៃមន្ទីរបរិស្ថាន មន្ត្រីឧទ្យានុរក្ស សហគមន៍តំបន់ការពារធម្មជាតិ និងអាជ្ញាធរពាក់ព័ន្ធបន្តរួមសហការគ្នាឱ្យកាន់តែខ្លាំងបន្ថែមទៀតដើម្បីបង្កើនប្រសិទ្ធភាពក្នុងការការពារនិងអភិរក្សដែនជម្រកសត្វព្រៃសង្ឃរុក្ខវ័ន ក៏ដូចជាតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សចម្រុះរបស់កម្ពុជា»។នេះគឺជាការថ្លែងរបស់ **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន នៅព្រឹកថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២២ ក្នុងឱកាសដែលឯកឧត្តមចុះពិនិត្យការងារគ្រប់គ្រងធនធានធម្មជាតិ និងជីវៈចម្រុះនៅក្នុងតំបន់ការពារធម្មជាតិក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ ក្នុងនោះរួមមានដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព និងដែនជម្រកសត្វព្រៃសង្ឃរុក្ខវ័ន។

ការចុះពិនិត្យលើការងារគ្រប់គ្រងធនធានធម្មជាតិនិងអភិរក្សជីវៈចម្រុះរបស់ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាននៅថ្ងៃទី១៣ ខែកុម្ភៈនេះ ក៏មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញក្រសួងបរិស្ថាន ថ្នាក់ដឹកនាំនៃរដ្ឋបាលខេត្តឧត្តរមានជ័យ ដឹកនាំដោយឯកឧត្តម ប៉ែន កុសល អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ព្រមទាំងមន្ត្រីនៃមន្ទីរបរិស្ថាន មន្ត្រីឧទ្យានុរក្ស និងសហគមន៍តំបន់ការពារធម្មជាតិផងដែរ។ **ឯកឧត្តម សាយ សំអាល់** បានគូសបញ្ជាក់ថា ការអភិរក្សធនធានធម្មជាតិបានគង់វង្សត្រូវផ្សារភ្ជាប់នឹងការបង្កើតសេដ្ឋកិច្ចនៅមូលដ្ឋាន តាមរយៈការលើកស្ទួយជីវភាពសហគមន៍ ដោយការជំរុញលើការចិញ្ចឹមសត្វ ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងកត្តារួមផ្សំផ្សេងៗ។

នៅក្នុងឱកាសនោះ **ឯកឧត្តមរដ្ឋមន្ត្រី** ឯកឧត្តមអភិបាលខេត្ត និងគណៈប្រតិភូក៏បានចូលរួមដាំដើមឈើជាអនុស្សាវរីយ៍នៅសួនឈើប្រណីត ក្នុងដែនជម្រកសត្វព្រៃសង្ឃរុក្ខវ័នផងដែរ។ សូមបញ្ជាក់ថាខេត្តឧត្តរមានជ័យមានតំបន់ការពារធម្មជាតិចំនួន០៣ មានផ្ទៃដីសរុប ១៩១.៤០៣ហិកតា ក្នុងនោះរួមមាន៖ ដែនជម្រកសត្វព្រៃសង្ឃរុក្ខាវ័នមានផ្ទៃដីទំហំ៣០.២៥៤ហិកតា តំបន់ការពារទេសភាពបន្ទាយឆ្មារមានផ្ទៃដីទំហំ៣៨.៥០៦ហិកតា និងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព១២២.៦៤៣ហិកតា ព្រមទាំងរបៀងអភិរក្សជីវចម្រុះឧត្តរមានផ្ទៃដីទំហំ៣៧.៦៩៦ហិកតា៕

ឯកឧត្តម សាយ សំអាល់ ជួបសំណេះសំណាលជាមួយសិស្សប្រឡងជាប់និទ្ទេស A នៅវិទ្យាល័យក្រុងព្រះសីហនុ

«ភាពជោគជ័យរបស់ប្អូនៗសិស្សានុសិស្សទាំងអស់ជាក្តីសង្ឃឹមថ្មីរបស់ខេត្តព្រះសីហនុ និងជាទំនួលខុសត្រូវដ៏ខ្ពស់សម្រាប់ខ្លួនឯង និងសង្គមជាតិផងដែរ»។ នេះជាប្រសាសន៍លើកឡើងរបស់ **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ ថ្លែងក្នុងឱកាសជួបសំណេះសំណាលជាមួយបេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងប្រគល់រង្វាន់ម៉ូតូដល់សិស្សនិទ្ទេស «A» នៅវិទ្យាល័យក្រុងព្រះសីហនុ ខេត្តព្រះសីហនុ នារសៀលថ្ងៃពុធ ទី១៦ ខែកុម្ភៈ ឆ្នាំ២០២២នេះ។ ។

ឯកឧត្តម សាយ សំអាល់ បានគូសបញ្ជាក់បន្ថែមទៀតថា លោកគ្រូ អ្នកគ្រូ ក៏ជាចំណែកមួយដ៏សំខាន់ក្នុងការចូលរួមជុសខាត់កែច្នៃទំពាំងដែលជាអ្នកស្នងប្រទេសជាតិ និងខេត្តព្រះសីហនុ ដើម្បីឆ្ពោះទៅរកការអភិវឌ្ឍកម្ពុជាប្រកបដោយចីរភាព។ ជាមួយគ្នានេះ **ឯកឧត្តម** ក៏បាននាំនូវការសួរសុខទុក្ខរបស់**សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម ហ៊ុន ម៉ាណែត** បេក្ខភាពនាយករដ្ឋមន្ត្រីនាពេលអនាគត ដែលជានិច្ចកាលលោកតែងគិតគូរ និងខិតខំស្វែងរក

រាំក់សាំងដើម្បីចាក់ជូនប្រជាពលរដ្ឋ ដើម្បីឱ្យមានភាពស៊ាំក្នុងសហគមន៍ ក៏ដូចជាប្អូនៗសិស្សានុសិស្ស ដែលធ្វើឱ្យការប្រឡងរបស់ប្អូនៗប្រព្រឹត្តទៅដោយជោគជ័យ។

គួរបញ្ជាក់ឱ្យដឹងថា តាមរបាយការណ៍របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះសីហនុ បានឱ្យដឹងថា ឆ្នាំសិក្សា២០២០-២០២១ សម័យប្រឡងថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ បេក្ខជនដាក់ពាក្យប្រឡង មានចំនួន១,៣៥២នាក់ ស្រី ៧១០នាក់ ប្រឡងជាប់ចំនួន១,០២៣នាក់ ស្រី ៥៦២នាក់ ស្មើនឹង៧៥,៦៧ភាគរយក្នុងនោះ៖ និទ្ទេសA មានចំនួន២០នាក់ (ស្រី០៩នាក់) ដែលក្នុងនោះវិទ្យាល័យហ៊ុនសែនក្រុងចំនួន០៧នាក់ វិទ្យាល័យ ហ៊ុន សែន មិត្តភាព ចំនួន៣នាក់ វិទ្យាល័យជីវិត ចំនួន០៣នាក់ វិទ្យាល័យ ហ៊ុន សែន ព្រៃនប់ចំនួន០២នាក់ វិទ្យាល័យ ហ៊ុន សែន វាលរេញ ចំនួន០២នាក់ វិទ្យាល័យសុវណ្ណភូមិ ចំនួន០២នាក់និងវិទ្យាល័យស្ទឹងហាវចំនួន០១នាក់។សិស្សនិទ្ទេសB មានចំនួន៦៧នាក់(ស្រី៤៣នាក់) និទ្ទេសC មានចំនួន ១៧០នាក់ (ស្រី៩៩នាក់) និទ្ទេសD មានចំនួន៣៧២នាក់ (ស្រី២០៩នាក់) និង និទ្ទេសE មានចំនួន៣៩៤នាក់ (ស្រី២០២នាក់)។

សម្រាប់សិស្សានុសិស្សដែលទទួលបានការលើកទឹកចិត្ត រួមមាន៖ និទ្ទេសA ចំនួន២០នាក់ ក្នុងម្នាក់ៗទទួលបានម៉ូតូ០១គ្រឿង និងថវិកា៥០០ដុល្លារ, និទ្ទេសB ចំនួន៦៧នាក់ ក្នុងម្នាក់ៗទទួលបានថវិកា២០០ដុល្លារ និងនិទ្ទេសC ចំនួន១៧០នាក់ ក្នុងម្នាក់ៗទទួលបានថវិកា១០០ដុល្លារ។

គួររម្លឹកឱ្យដឹងថា **ឯកឧត្តម សាយ សំអាល់** អញ្ជើញជួបសំណេះសំណាលជាមួយបេក្ខជនប្រឡងជាប់សញ្ញាបត្រ មធ្យមសិក្សាទុតិយភូមិ និទ្ទេស «A,B,C» នៅខេត្តព្រះសីហនុ មានការចូលរួមពីឯកឧត្តម គួច ចំរើន អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ ប្រធានមន្ទីរអង្គភាពជុំវិញខេត្ត លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សជាច្រើនរូបទៀត៕

ឯកឧត្តម សាយ សំអាល់៖ យុវជនត្រូវចេះទាញយកបច្ចេកវិទ្យានិងការវិវឌ្ឍថ្មី ដើម្បីបម្រើឧត្តមប្រយោជន៍ ខ្លួនឯងនិងប្រទេសជាតិខ្លួនឯង

ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានសហភាពសហព័ន្ធយុវជនកម្ពុជារាជធានីភ្នំពេញ បានលើកឡើងថា យុវជនកម្ពុជាត្រូវចេះទាញយកបច្ចេកវិទ្យានិងការវិវឌ្ឍថ្មី ដើម្បីបម្រើឧត្តមប្រយោជន៍ខ្លួនឯង និងប្រទេសជាតិខ្លួនឯង។ **ឯកឧត្តមរដ្ឋមន្ត្រី** បានថ្លែងដូចនេះនៅក្នុងឱកាសអញ្ជើញជាអធិបតី នៅក្នុងពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការមជ្ឈមណ្ឌលពិសោធន៍វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា នៅព្រឹកថ្ងៃសុក្រទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (សាលាតិចណូ) រាជធានីភ្នំពេញ។

ឯកឧត្តម សាយ សំអាល់ បានលើកឡើងបន្ថែមថា អ្វីដែលរៀននៅសាលាគឺមិនសំដៅតម្រូវឱ្យនរណាម្នាក់ទេ គឺសំដៅតម្រូវឱ្យទាំងអស់គ្នា ហើយយើងត្រូវចេះយល់ច្បាស់អ្វីដែលគេបានបង្រៀននៅក្នុងមេរៀនទាំងអស់នោះ ក្នុងការដោះស្រាយបញ្ហាដោយប្រើប្រាស់មូលដ្ឋានបច្ចេកវិទ្យា និងវិទ្យាសាស្ត្រជាគោល ដែលយើងអាចធ្វើបានដោយខ្លួនឯង។ លើសពីនេះ យុវជនត្រូវមានការជឿជាក់លើខ្លួនឯង ហើយមានជំហរមួយជឿថាខ្មែរធ្វើបាន។

ជាមួយគ្នានេះ **ឯកឧត្តមរដ្ឋមន្ត្រី** បានបញ្ជាក់ថា ក្នុងសម័យតេជោសន្តិភាព កម្ពុជាមានឱកាសនិងលទ្ធភាពដូចបណ្តាប្រទេសដទៃទៀតដែរ ក្នុងការក្រសោបទាញប្រយោជន៍ពីការរីកចំរើននៃបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងវិស្វកម្មរបស់ឧស្សាហកម្ម ៤.០។ ក្នុងនោះដែរ កម្ពុជាមានឱកាសស្មើគ្នាជាមួយប្រទេសនានា ក្នុងការឈានទៅរកឧស្សាហកម្ម ៤.០ ស្របតាមចក្ខុវិស័យនៃក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ សំដៅធ្វើពិពិធកម្មសេដ្ឋកិច្ច និងសមាហរណកម្មបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងវិស្វកម្មកម្ពុជាចូលក្នុងតំបន់ និងពិភពលោក។

ឯកឧត្តម សាយ សំអាល់ បានលើកទឹកចិត្តឱ្យយុវជនកម្ពុជា ជាពិសេសយុវសិស្សនៅតាមគ្រឹះស្ថានសិក្សាត្រូវប្រឹងប្រែងសិក្សា និងចាប់យកឱកាសនៃការវិវឌ្ឍនៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា សម្រាប់ឧត្តមប្រយោជន៍របស់សង្គមកម្ពុជា ឆ្ពោះទៅប្រែក្លាយសេដ្ឋកិច្ចកម្ពុជាពីប្រទេសឧស្សាហកម្មបែបប្រពៃណីទៅរកឧស្សាហកម្មទំនើប។

សូមបញ្ជាក់ថានៅក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការមជ្ឈមណ្ឌលពិសោធន៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ជាប្រវត្តិសាស្ត្រនេះដែរ ក៏មានពិធីចុះអនុស្សារណៈនៃការយោគយល់គ្នាស្តីពីកម្មវិធីអប់រំឧស្សាហកម្ម៤.០ រវាងសហភាពសហពន្ធ័យុវជនកម្ពុជារាជធានីភ្នំពេញ ជាមួយស៊ីមមីង ខេមបូឌា និងវិទ្យាល័យព្រះស៊ីសុវត្ថិ សាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប វិទ្យាល័យអ៊ីជូស្វែម ព្រះយុគន្ធរ អង្គការសប្បុរសធម៌ឡៃហ្គ័រ ផងដែរ៕

ឯកឧត្តម សាយ សំអាល់ អនុញ្ញាតឱ្យលោកស្រី Angelina Jolie ជួបសម្តែងការគួរសម

ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថានបាន ថ្លែងអំណរគុណចំពោះលោកស្រី Angelina Jolie តារាភាពយន្តហូលីវូដ ដ៏ល្បីល្បាញដែលបានចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការ ការពារ និងអភិរក្សធនធានធម្មជាតិនៅតំបន់ប្រើប្រាស់ច្រើនយ៉ាង សំឡូត និងការសហការលើផ្នែកផ្សេងៗទៀត។

ការថ្លែងអំណរគុណនេះបានធ្វើឡើងក្នុងជំនួបគួរសម មួយរវាងឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន និងលោកស្រី Angelina Jolie នៅព្រឹកថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ នៅទីស្តីការក្រសួងបរិស្ថាន នៅអំឡុងលោកស្រីធ្វើទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តមរដ្ឋមន្ត្រី សាយ សំអាល់ បានគូសបញ្ជាក់ពីការបន្តកិច្ចសហការ និងការគាំទ្ររបស់ក្រសួងបរិស្ថាន ចំពោះគម្រោងអភិរក្សដែលផ្តួចផ្តើមដោយលោកស្រី Angelina Jolie៕

ឯកឧត្តម សាយ សំអាល់៖ សម្តេចតេជោបានសម្រេចចិត្តដ៏ត្រឹមត្រូវបំផុតចំពោះគោលនយោបាយស្រោចស្រពវ៉ាក់សាំង

«សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវបំផុតចំពោះគោលនយោបាយស្រោចស្រពវ៉ាក់សាំងចំពោះប្រជាពលរដ្ឋ»។

នេះជាការថ្លែងរបស់**ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ ក្នុងឱកាសអញ្ជើញជាអធិបតីភាពក្នុងពិធីកាត់ឫសសីមាព្រះវិហារថ្មី និងសម្ពោធសមិទ្ធផលនានា នៅវត្តសាមគ្គីគិរីស្ទឹងឆាយ នៅស្រុកកំពង់សីលា ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២២។

ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តម សាយ សំអាល់** បាននាំនូវបណ្តាំផ្ញើសាកសួរសុខទុក្ខពីសំណាក់សម្តេចតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ព្រមជាមួយនឹងឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត ដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ ដែលលោកតែងតែគិតគូរពីសុខទុក្ខប្រជាពលរដ្ឋជានិច្ច។ ជាពិសេស ក្នុងបរិបទនៃការរាតត្បាតនៃជំងឺកូវីដ-១៩នេះ សម្តេចតេជោ បានសម្រេចចិត្តដ៏ត្រឹមត្រូវបំផុតចំពោះគោលនយោបាយស្រោចស្រពវ៉ាក់សាំងដល់ប្រជាពលរដ្ឋនូវទូទាំងប្រទេសប្រកបដោយប្រសិទ្ធភាព។

ឯកឧត្តម បន្តឱ្យដឹងទៀតថា ដោយសារតែគោលនយោបាយនេះទទួលបានជោគជ័យ ទើបយើងបានឃើញមានអ្នកមកចូលរួមនឹងជោគជ័យរបស់យើង ដោយបានផ្តល់វ៉ាក់សាំងជាបន្តបន្ទាប់មកឱ្យយើង ព្រោះយើងបានធ្វើការសម្រេចចិត្តមួយដ៏ត្រឹមត្រូវ។ ប្រសិនបើសម្តេចតេជោ មិនបានធ្វើការសម្រេចចិត្តជាយុទ្ធសាស្ត្រ ប្រកបដោយការទទួលខុសត្រូវតាមរយៈការវាយតម្លៃលើស្ថានការណ៍ និងពិចារណាវិនិច្ឆ័យក្នុងការអារកាត់បានហ័សទាន់ពេលវេលាទេនោះ គឺវិនាសកម្មនឹងមានសភាពធំធេង និងច្រើនលើសលប់ពីអ្វីដែលបានកើតឡើង។ ឥឡូវនេះ យើងបានឈានទៅដល់ការចាក់វ៉ាក់សាំងដុសជំរុញ ដើម្បីឱ្យគ្រប់ និងជួយបង្កើននូវភាពស៊ាំ បន្ថយការឈឺធ្ងន់ និងបន្ថយការឆ្លងរីករាលដាលនៅក្នុងសហគមន៍របស់យើង។ ចំណុចពិសេសរបស់រាជរដ្ឋាភិបាលយើង គឺប្រកាន់យកគោលនយោបាយចាក់វ៉ាក់សាំង និងព្យាបាលអ្នកជំងឺកូវីដ-១៩ ដោយឥតគិតថ្លៃផងដែរ។

ជាមួយគ្នានេះ **ឯកឧត្តម សាយ សំអាល់** ក៏សូមអំពាវនាវបន្ថែមដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ ឱ្យទៅចាក់វ៉ាក់សាំងក៏ដូចជាដូសជំរុញលើកទី៣ និងទី៤ ឱ្យបានគ្រប់ៗគ្នា។ **ឯកឧត្តម**

បានក្រើនរម្លឹកថា ទោះបីជាយើងមានរាំងសាំងក៏ដោយ ក៏យើងត្រូវអនុវត្តវិធានរបស់ក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាលនូវវិធាន «៣ការពារ និង៣កុំ» ឱ្យបានខ្ជាប់ខ្ជួន ទើបអាចការពារយើងបានទាំងអស់គ្នា ជាពិសេសនៅអំឡុងពេលដែលមេរោគបម្លែងថ្មី អូមីក្រុងដែលកំពុងរាតត្បាតនាពេលបច្ចុប្បន្ននេះ។

ឯកឧត្តម សាយ សំអាល់ បានសង្កត់ធ្ងន់ថា យើងមិនចង់ឃើញការបាត់បង់ជីវិតទេ ព្រោះប្រទេសយើងធ្លាប់ងើបពីសង្គ្រាម ហេតុនេះរាល់ជីវិតយើងជាកូនខ្មែរ យើងត្រូវតែថែរក្សា។

គួររម្លឹកឱ្យដឹងថា ពិធីកាត់ឫសសីមាព្រះវិហារថ្មី និងសម្ពោធសមិទ្ធផលនានា នៅក្នុងវត្តសាមគ្គីគិរីស្ទឹងឆាយ ប្រព្រឹត្តទៅក្រោមអធិបតីភាព**ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ និងជាតំណាងឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការទ័ពជើងគោក ឯកឧត្តម គួច ចំរើន អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ឯកឧត្តម លោកជំទាវ សមាជិកសមាជិកាព្រឹទ្ធសភា រដ្ឋសភា ព្រមទាំង ឯកឧត្តម លោកជំទាវ លោក លោកស្រីជាប្រធាន អនុប្រធាន ក្រុមការងារចុះមូលដ្ឋានខេត្តព្រះសីហនុ ស្រុកកំពង់សីលា កងកម្លាំងប្រដាប់អាវុធ ព្រះសង្ឃ តាជី យាយជី និងពុទ្ធបរិស័ទចំណុះជើងវត្តជាច្រើនរូបទៀត៕

ជំនួបរវាងឯកឧត្តមរដ្ឋមន្ត្រី និងអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំតំបន់អាស៊ាន និងអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជា

កម្ពុជាចូលរួមសហការជាមួយសហគមន៍អឺរ៉ុបលើកិច្ចសហប្រតិបត្តិការ «បៃតង» ក្នុងក្របខណ្ឌអាស៊ាន-អឺរ៉ុប កាលពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២២ **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានទទួលជួបពិភាក្សាការងារជាមួយ ឯកឧត្តម Igor Driesmans ឯកអគ្គរដ្ឋទូតនៃសហភាពអឺរ៉ុបប្រចាំអាស៊ាន និងលោកជំទាវ Carmen Monero ឯកអគ្គរដ្ឋទូតនៃសហភាពអឺរ៉ុបប្រចាំកម្ពុជា។

ឯកឧត្តម Igor Driesmans បានមានប្រសាសន៍លើកឡើងនូវការគិតគូរអំពីកិច្ចសហប្រតិបត្តិការ «បៃតង» នៅក្នុងក្របខណ្ឌអាស៊ាន-អឺរ៉ុប ដែលនឹងក្លាយជាកត្តាជំរុញបន្ថែមទៀតនូវរបៀបវារៈពាក់ព័ន្ធនឹងវិស័យបរិស្ថាន នៅ ក្នុងតំបន់អាស៊ាន។ កិច្ចសហប្រតិបត្តិការបៃតងអាស៊ាន-អឺរ៉ុបនេះ មានគំនិតផ្តួចផ្តើមថ្មីៗជាអាទិ៍ ហិរញ្ញប្បទាននិងការវិនិយោគប្រកបដោយចីរភាព ការជំរុញសេដ្ឋកិច្ចបៃតង ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ថាមពលស្អាត និងការបន្សាំនិងកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុជាដើម។ សហភាពអឺរ៉ុបក៏នឹងស្នើឱ្យមានកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីបរិស្ថានអាស៊ាន-អឺរ៉ុប នៅក្នុងពេលខាងមុខនេះផងដែរ។

ឯកឧត្តម សាយ សំអាល់ បានបញ្ជាក់ជូនឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំអាស៊ានថា កម្ពុជា ក្នុងនាមជាប្រធានប្តូរវេនអាស៊ាន ត្រៀមខ្លួនរួចជាស្រេចក្នុងការជំរុញកិច្ចសហប្រតិបត្តិការបៃតងនេះ ហើយកម្ពុជាស្នើ ឱ្យមានគំនិតផ្តួចផ្តើមមួយចំនួនទៀតដែលពាក់ព័ន្ធនឹងឥណទានកាបូន ការគ្រប់គ្រងសំណល់ប្លាស្ទិកក្នុងសមុទ្រ ការអភិវឌ្ឍបច្ចេកវិទ្យាបៃតង និងការអភិវឌ្ឍសហគមន៍មូលដ្ឋានក្នុងតំបន់អាស៊ាន៕



គណៈកម្មការទី៣ រដ្ឋសភាស្វែងយល់បន្ថែមពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ និង ការប្រែប្រួលអាកាសធាតុ

ឯកឧត្តម ឡូយ សុផាត ប្រធានគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក នៃរដ្ឋសភា និង**ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និង ជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បានអញ្ជើញជា អធិបតីក្នុងសិក្ខាសាលាផ្សព្វផ្សាយស្តីពី «ការគ្រប់គ្រងឧទ្យានជាតិ និងការប្រែប្រួលអាកាសធាតុ» នាព្រឹកថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ នៅសណ្ឋាគារសុខា ក្រុងបូកគោ ខេត្តកំពត។

ថ្លែងទៅកាន់អង្គសិក្ខាសាលា **ឯកឧត្តម សាយ សំអាល់** បានលើកឡើងថា សិក្ខាសាលាដែលរៀបចំឡើងនៅថ្ងៃនេះ បាន ផ្តល់ឱកាសឱ្យក្រសួងបរិស្ថានបានរាយការណ៍ និងធ្វើបច្ចុប្បន្នភាព ជូនគណៈកម្មាធិការទី៣ អំពីវឌ្ឍភាពនៃការងារការពារបរិស្ថាន និង ការគ្រប់គ្រងអភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះនៅកម្ពុជា ក៏ដូចជា កិច្ចខិតខំប្រឹងប្រែងរបស់សកលលោកក្នុងការដោះស្រាយបញ្ហា ប្រឈមធំៗក្នុងវិស័យបរិស្ថាន ជាពិសេសការប្រែប្រួលអាកាសធាតុ។

ឯកឧត្តម បានគូសបញ្ជាក់ថា នៅប្រទេសកម្ពុជា វិស័យ បរិស្ថានបាននិងកំពុងវិវត្តជាវិជ្ជមានគួរឱ្យកត់សម្គាល់ ដោយសារ កត្តាសំខាន់ៗមួយចំនួនរួមមាន៖ និន្នាការវិវឌ្ឍន៍របស់មនុស្សលោក និងការទទួលខុសត្រូវរួម បានឈានទៅដល់ការអនុម័តអនុសញ្ញារីយ៉ូសំខាន់៣។ សន្តិភាព ស្ថិរភាពនយោបាយ និងកំណើនសេដ្ឋកិច្ចខ្ពស់។ ការឆ្លងកាត់នូវឧបសគ្គដ៏ធំនៃវិបត្តិជំងឺកូវីដ-១៩ ដែលកម្ពុជា អាចគ្រប់គ្រងលំនឹងសង្គម សេដ្ឋកិច្ចល្អប្រសើរ។ កិច្ចខិតខំប្រឹងប្រែង ការលះបង់ និងការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់មន្ត្រីគ្រប់ជាន់ថ្នាក់នៃ ក្រសួងបរិស្ថាន។

ឯកឧត្តម សាយ សំអាល់ បានឱ្យដឹងទៀតថា ផ្អែកលើ កត្តាសំខាន់ៗទាំងនេះ ក្រសួងបរិស្ថានបាននិងកំពុងខិតខំជំរុញ ការអនុវត្តបេសកកម្មរបស់ខ្លួនដែលបានរួមចំណែកពង្រឹងនិងពង្រីក សមិទ្ធផលសង្គម សេដ្ឋកិច្ច វប្បធម៌ សន្តិសុខនយោបាយ និងវិស័យ បរិស្ថានកម្ពុជា រួមមាន៖ ទី១)ការធ្វើទំនើបកម្មស្ថាប័ន និងប្រែក្លាយ ទៅជារដ្ឋបាលទំនើប ២)គោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ ទី៣)ការគ្រប់គ្រងធនធានធម្មជាតិនិងអភិរក្សជីវៈចម្រុះ ទី៤)រៀបចំ គោលនយោបាយ ផែនការ យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និង គំនិតផ្តួចផ្តើមនានាលើវិស័យបរិស្ថានបានល្អប្រសើរ ៥)ការវាយតម្លៃ ហេតុផលប៉ះពាល់បរិស្ថាន និងសង្គម ទី៦)ប្រើប្រាស់ការទូតបរិស្ថាន និងទី៧)បញ្ហាសន្តិសុខនយោបាយពាក់ព័ន្ធនឹងវិស័យបរិស្ថាន។

គួរឱ្យដឹងថា អង្គសិក្ខាសាលាក៏មានការអញ្ជើញចូលរួម ពីឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃរដ្ឋសភា ឯកឧត្តម លោកជំទាវរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករងនៃក្រសួងបរិស្ថាន លោកជំទាវអភិបាលក្រុងបូកគោ ប្រធានមន្ទីរបរិស្ថានខេត្ត និងលោក លោកស្រី ជាសិក្ខាកាមជាច្រើន រូបទៀត។

«វិស័យឯកជនមានតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមលើកកម្ពស់និរន្តរភាពបរិស្ថាន និង ការរស់នៅស្អាត»

«វិស័យឯកជនមានតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមលើកកម្ពស់និរន្តរភាពបរិស្ថាន និងការរស់នៅស្អាត» នេះគឺជាប្រសាសន៍របស់**ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ជម្រាបជូនលោក Donald Kanak ប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន Prudential Insurance Growth Market និងគណៈប្រតិភូ នៅក្នុងជំនួបសម្តែងការគួរសម នៅព្រឹកថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ នៅទីស្តីការក្រសួងបរិស្ថាន។

ក្នុងឱកាសនោះ **ឯកឧត្តមរដ្ឋមន្ត្រី**បានបង្ហាញពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការការពារបរិស្ថាន ជំរុញការប្រតិបត្តិមេត្រីភាពបរិស្ថាន គុណភាពចំណីអាហារ និងការរស់នៅស្អាត ដែលជាមូលដ្ឋានគ្រឹះមួយសម្រាប់គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព ស្របពេលដែលប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចខ្ពស់ និងការកើនឡើងយ៉ាងឆាប់រហ័សនូវសមាសភាគប្រជាជនមានកម្រិតជីវភាពមធ្យម ដោយសារតែសុខសន្តិភាព និងស្ថិរភាពនយោបាយរឹងមាំជាប់មិនដាច់ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ។ ទាំងនេះ គឺជាកត្តាអំណោយផលមួយសម្រាប់ទីផ្សារធានារ៉ាប់រងនៅកម្ពុជា។

ជាការឆ្លើយតប លោកប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន Prudential បានកោតសរសើរចំពោះវឌ្ឍនភាពសង្គមកម្ពុជាលើគ្រប់វិស័យរាប់ទាំងបរិស្ថាន និងការអភិវឌ្ឍដោយចីរភាពផង និងបានបញ្ជាក់ថា នឹងយកអនុសាសន៍ល្អៗរបស់ឯកឧត្តមរដ្ឋមន្ត្រី ទៅគិតគូរបញ្ចូលក្នុងគោលនយោបាយរបស់ក្រុមហ៊ុន សំដៅជំរុញលើកទឹកចិត្តឱ្យអតិថិជនដែលជាវផលិតផលធានារ៉ាប់រងផ្សេងៗរបស់ខ្លួន យកចិត្តទុកដាក់ទៅលើនិរន្តរភាពបរិស្ថាន សុខភាព និងការរស់នៅស្អាត។



ក្រសួងបរិស្ថានរៀបចំពិធីសូត្រមន្តចម្រើនព្រះបរិត្ត ប្រោះព្រំលើករាសី នាំសិរីសួស្តីនៅឆ្នាំថ្មីប្រពៃណីជាតិខ្មែរ

ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រួមជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងបរិស្ថានគ្រប់ លំដាប់ថ្នាក់ នាថ្ងៃពុធ ០៥កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ បានរៀបចំពិធីសូត្រមន្តចម្រើនព្រះបរិត្ត បណ្តេញឧបទ្រពពីឆ្នាំចាស់ ប្រោះព្រំលើករាសី នាំសិរីសួស្តីជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទក្រសួង ដើម្បីអបអរសាទរឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំខាល ត្រីស័ក ពុទ្ធស័ករាជ ២៥៦៥ ដែលនឹងឈានចូលមកដល់ នៅថ្ងៃទី១៤ ដល់ ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២២។

ពិធីនេះបានប្រារព្ធឡើងទៅតាមគន្លងទំនៀមទំលាប់ប្រពៃណី ព្រះពុទ្ធសាសនា ដោយបាននិមន្តព្រះសង្ឃសូត្រមន្តចំរើនព្រះបរិត្ត សមាទានសីល និងសូមទេវតាឆ្នាំថ្មី សូមជួយប្រោះព្រំពរជ័យសិរីសួស្តី វិបុលសុខមហាប្រសើរ សុំសេចក្តីសុខ សេចក្តីចំរើនជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ និងប្រជាពលរដ្ឋទាំងអស់។

សូមបញ្ជាក់ថា បន្ទាប់ពីបញ្ចប់ពិធីសូត្រមន្តចម្រើនព្រះបរិត្ត ក្រសួងបរិស្ថានបានរៀបចំការសម្តែងនូវរបាំជូនពរ និងរបាំត្រុដិ ដើម្បីជាកិច្ចបណ្តាញនូវឧបទ្រពចង្រៃ ក្នុងឆ្នាំចាស់និងទទួលយកសិរីសួស្តីបវរមហាប្រសើរ ក្នុងឆ្នាំថ្មី ជូនដល់ឯកឧត្តរដ្ឋមន្ត្រី និងលោកជំទាវព្រមទាំងបុត្រា បុត្រី និងក្រុមគ្រួសារ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ ទទួលបានជោគជ័យថ្មីៗថែមទៀត។



«រូបវន្តបុគ្គល នីតិបុគ្គលឆ្នើម ទទួលបានបណ្ណសរសើរមេត្រីភាពបរិស្ថាន ពីក្រសួងបរិស្ថាន»

ទីស្តីការក្រសួងបរិស្ថាន៖ រូបវន្តបុគ្គល នីតិបុគ្គលដែលមានស្នាដៃឆ្នើម ចូលរួមជាមួយក្រសួងបរិស្ថាន ក្នុងការផ្លាស់ប្តូរឥរិយាបទសង្គម មកប្រតិបត្តិមេត្រីភាពបរិស្ថាន ទទួលបណ្ណសរសើរមេត្រីភាពបរិស្ថាន ក្រោមអធិបតីភាព **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្នុងពិធីលើកទឹកចិត្តមេត្រីភាពបរិស្ថាន នារសៀលថ្ងៃទី៦ ខែមេសា ឆ្នាំ២០២២ នេះ។

ឯកឧត្តម សាយ សំអាល់ បានមានប្រសាសន៍ថា កម្មវិធីនេះរៀបចំឡើង ដើម្បីជាការលើកទឹកចិត្តចំពោះការចូលរួម និងបំផុសចលនាការរស់នៅស្អាត ភូមិឋានស្អាត ដើម្បីធ្វើយ៉ាងណាឱ្យកិច្ចគាំពារបរិស្ថាន និងការលើកកម្ពស់មេត្រីភាពបរិស្ថាន កាន់តែមានភាពល្អប្រសើរ។ យើងបាននិងកំពុងលើកកម្ពស់សកម្មភាពសាលាមេត្រីបរិស្ថាន អារាមមេត្រីបរិស្ថាន និងស្ថាប័នមេត្រីបរិស្ថាន។ **ឯកឧត្តម** បានបន្តថាក្រសួងបរិស្ថានតែងលើកទឹកចិត្ត និងទទួលស្គាល់ដល់ការខិតខំប្រឹងប្រែងរបស់ពលរដ្ឋកម្ពុជា ស្ថាប័នសាធារណៈ ស្ថាប័នឯកជន អង្គការ និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងវិស័យបរិស្ថាន។ អ្វីដែលកម្ពុជាចង់បានគឺ «ភូមិឋានស្អាត ការរស់នៅស្អាត សុខភាពល្អ សហគមន៍បវរ សង្គមរុងរឿង» ដើម្បីឈានឆ្ពោះទៅកម្ពុជាប្រកបដោយភាពរុងរឿង។ ទន្ទឹមនេះដែរ **ឯកឧត្តមរដ្ឋមន្ត្រី** បានលើកឡើងអំពីវឌ្ឍនភាពនៃសង្គមកម្ពុជា ដែលជាចំណែកនៃការចូលរួមរបស់យើងទាំងអស់គ្នា មិនថាដៃគូរអភិវឌ្ឍន៍ វិស័យឯកជន វិស័យសាធារណៈ និងមន្ត្រីគ្រប់លំដាប់ថ្នាក់នៃក្រសួងបរិស្ថាន ក្នុងការចូលរួមធ្វើកិច្ចការធ្វើឱ្យមានការផ្លាស់ប្តូរឥរិយាបទ ការគិតគូរ និងផ្នត់គំនិតចំពោះបរិស្ថាន។

នាឱកាសនោះដែរ លោកស្រី Nancy J. Eslick នាយកបេសកកម្មរបស់ USAID បានថ្លែងថាពិធីថ្ងៃនេះ គឺជាការទទួលស្គាល់នូវការខិតខំប្រឹងប្រែងរបស់យុវជនកម្ពុជា។ ជាង៦០%នៃប្រជាជនកម្ពុជា គឺជាយុវជនដែលមានសក្តានុពលសម្រាប់ប្រទេសជាតិ ក្នុងនោះផងដែរ គឺការចូលរួមក្នុងការអភិរក្ស និងកិច្ចគាំពារបរិស្ថាន។ USAID បានសហការជាមួយក្រសួងបរិស្ថានក្នុងយុទ្ធនាការផ្សព្វផ្សាយការផ្លាស់ប្តូរឥរិយាបទសង្គមរបស់គម្រោងអនាគតបៃតង ក្រោមប្រធានបទ «ការកាត់បន្ថយតម្រូវការប្រើប្រាស់គ្រឿងសង្ហារឹមពីឈើប្រណិត»។ លោកស្រីសូមអរគុណដល់ក្រសួងបរិស្ថាន ជាពិសេស **ឯកឧត្តមរដ្ឋមន្ត្រី** ក្នុងកិច្ចសហការល្អក្នុងវិស័យបរិស្ថានយ៉ាងល្អកន្លងមក។

គួរឱ្យដឹងថា រូបវន្តបុគ្គល នីតិបុគ្គល ដែលទទួបណ្ណសរសើរក្នុងពិធីនេះ មកពីអន្តរវិស័យ ទាំងវិស័យសាធារណៈ និងឯកជន សរុបចំនួន ៦៨រូប៕

ឯកឧត្តម សាយ សំអាល់៖ កងទ័ពគឺជាឆ្អឹងខ្នងរបស់កម្ពុជា

«កងទ័ព គឺជាឆ្អឹងខ្នងរបស់កម្ពុជាយូរអង្វែងទៅមុខទៀត យើងមិនអាចធ្វេសប្រហែសបានទេ ហើយយើងក៏មិនមានជម្រើសក្រៅពីធ្វើយ៉ាងណារក្សាបាននូវឧត្តមប្រយោជន៍ជាតិរបស់យើង»។ នេះជាប្រសាសន៍លើកឡើងរបស់ **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ

ក្នុងឱកាសអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងជូនពរឆ្នាំថ្មី ដល់នាយនាវី នាយនាវីរង និងពលនាវិក មូលដ្ឋានសមុទ្ររាម នារសៀលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២។ ពិធីនេះ ក៏មានការអញ្ជើញចូលរួមពីឯកឧត្តម គួច ចំរើន អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ឯកឧត្តមឧត្តមនាវីឯក អ៊ុក សីហា មេបញ្ជាការរងកងទ័ពជើងទឹក និងជាមេបញ្ជាការមូលដ្ឋានសមុទ្រ ព្រមទាំងឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ លោក លោកស្រី ជាសមាជិកក្រុមការងារ និងនាយនាវី នាវីរង ពលនាវិក ជាច្រើននាក់ទៀត។

ឯកឧត្តម សាយ សំអាល់ បានលើកឡើងទៀតថា ពិតណាស់យើងអាចមានជំនឿសាសនាខុសគ្នា មានទស្សនៈខុសគ្នា ទស្សនៈនយោបាយខុសគ្នា ប៉ុន្តែអ្វីដែលសំខាន់ គឺតួនាទីភារកិច្ចរបស់យើងជាកងទ័ព យើងត្រូវធ្វើអ្វី? នេះជារឿងសំខាន់។ កងទ័ពរបស់កម្ពុជា ជាកូន ជាចៅ របស់ប្រជាជន ហើយមានតែកងទ័ពទេ គឺជាផ្ទាំងចាំយាមអាយុជីវិតជាតិរបស់យើង។ ក្នុងគោលការណ៍មន្ត្រីរាជការស៊ីវិល ក៏ដូចជាកងទ័ព គឺដូចគ្នា។ យើងធ្វើការដើម្បីបម្រើឧត្តមប្រយោជន៍ប្រទេសរបស់យើង ប្រជាជនយើង ហើយធ្វើការជាមួយគណបក្សណាដែលជាប់ឆ្នោត។

ឯកឧត្តម សាយ សំអាល់ បានរម្លឹកឱ្យដឹងថា បើយើងងាកត្រឡប់ទៅប្រវត្តិសាស្ត្ររបស់ខ្មែរ៥០០ឆ្នាំមុន យើងមិនដែលមានពេលណាដែលមានរដ្ឋាភិបាលតែមួយ រដ្ឋធម្មនុញ្ញតែមួយ ហើយក៏មិនដែលបានឯកភាពទឹកដីដូចពេលនេះដែរ។ យើងមានរដ្ឋាភិបាលតែមួយ មានសុខសន្តិភាព ស្ថេរភាពនេះ ក៏ដោយសារនយោបាយឈ្នះ-ឈ្នះរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ដែលធ្វើឱ្យយើងមានឱកាសកសាងអភិវឌ្ឍប្រទេសរបស់យើង។ ជាមួយគ្នានេះដែរ បងប្អូនយុទ្ធជនរបស់យើង ក៏បានពលីជាច្រើនផងដែរ ក្នុង

ដំណើរស្វែងរកសន្តិភាពនៅកម្ពុជា។ ឯកឧត្តមបានសង្កត់ធ្ងន់ថា កម្ពុជាយើងជាប្រទេសមួយដែលធ្លាប់ងើបពីសង្គ្រាម ពីគំនរឆ្អឹង និងថ្លុកឈាម ហេតុនេះ បើយើងរក្សាបាននូវសន្តិភាព និងស្ថេរភាពនយោបាយដែលកំពុងមានបច្ចុប្បន្ននេះ នោះអនាគតរបស់យើងនឹងកាន់តែល្អប្រសើរ។

គួរឱ្យដឹងថា ក្នុងឱកាសអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ និងជូនពរឆ្នាំថ្មី **ឯកឧត្តម សាយ សំអាល់** បាននាំនូវការផ្ដាំផ្ញើសាកសួរសុខទុក្ខពីសម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ព្រមទាំងនាំយកអំណោយជាគ្រឿងឧបភោគបរិភោគ និងថវិកាមួយចំនួន ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្ដេចទាំងពីរ ប្រគល់ជូនដល់អង្គភាព និងនាយនាវី នាយនាវីរង ពលនាវិក ដែលមកចូលរួមជាងមួយពាន់នាក់ផងដែរ៕

ក្រសួងបរិស្ថាន និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ គាំទ្រការរៀបចំបង្កើតតំបន់បេតិកភណ្ឌធម្មជាតិ វប្បធម៌ប្រវត្តិសាស្ត្រ នគរភ្នំ-ឈើកាច់បាភ្នំ

កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២ នៅទីស្តីការក្រសួងបរិស្ថាន **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ស្តីពីការសិក្សា កំណត់ និងរៀបចំបង្កើតតំបន់បេតិកភណ្ឌធម្មជាតិ និងវប្បធម៌ប្រវត្តិសាស្ត្រ នគរភ្នំ-ឈើកាច់បាភ្នំ ស្ថិតនៅក្នុងឃុំជើងភ្នំ និងឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរ៉ែនិងថាមពល ក្រសួងទេសចរណ៍ និងតំណាងរដ្ឋបាលខេត្តព្រៃវែង។ មតិរួមរបស់អន្តរក្រសួងបានគាំទ្រចំពោះការសិក្សា កំណត់ និងរៀបចំបង្កើតតំបន់បេតិកភណ្ឌធម្មជាតិ និងវប្បធម៌ប្រវត្តិសាស្ត្រ នគរភ្នំ-ឈើកាច់បាភ្នំ ដែលជាទីតាំងដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្រនៃ នគរគោកធ្លក ឬ នគរភ្នំ ដើមកំណើតទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។ អង្គប្រជុំបានឯកភាពជូនក្រុមការងារអន្តរក្រសួង ស្ថាប័នពាក់ព័ន្ធចុះពិនិត្យសិក្សាចុងក្រោយលើទីតាំងជាក់ស្តែង និងកំណត់តំបន់គ្រប់គ្រង ព្រមទាំងដោះស្រាយផលប៉ះពាល់នានា មុននឹងក្រសួងបរិស្ថាន និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ស្នើសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល លើការបង្កើតតំបន់បេតិកភណ្ឌធម្មជាតិ និងវប្បធម៌ប្រវត្តិសាស្ត្រ នគរភ្នំ-ឈើកាច់បាភ្នំ។

«អនុស្សរណៈនៃការយោគយល់រវាងក្រសួងបរិស្ថាន និងក្រុមហ៊ុន សូហ្វៀរឧស្សាហកម្ម សៀមិនស៍ ភីធីអ៊ី អិលធីឌី, វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, បណ្ឌិតសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា, និងសាលា ស្ទីមមីង ខេមបូឌា»v

ទីស្តីការក្រសួងបរិស្ថាន៖ ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់រវាងក្រសួងបរិស្ថាន និងក្រុមហ៊ុន សូហ្វៀរឧស្សាហកម្ម សៀមិនស៍ ភីធីអ៊ី អិលធីឌី, វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, បណ្ឌិតសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា និងសាលា ស្ទីមមីង ខេមបូឌា ត្រូវបានធ្វើឡើងក្រោមអធិបតីភាព **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និង **ឯកឧត្តម ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ នាព្រឹកថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២។

ឯកឧត្តមរដ្ឋមន្ត្រី សាយ សំអាល់ បានថ្លែងអំណរគុណ និងកោតសរសើរចំពោះគ្រប់ភាគីពាក់ព័ន្ធដែលបាននិងកំពុងខិតខំប្រឹងប្រែងជំរុញវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ក្នុងការអភិវឌ្ឍសង្គមកម្ពុជា ប្រកបដោយចីរភាព ភាពធន់ និងធ្វើសមាហរណកម្មទៅក្នុងយុគសម័យបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ (ឧស្សហកម្ម ៤.០)។ អនុស្សរណៈនៃការយោគយល់នេះ គឺជាការចាប់ផ្តើមថ្មីនៃការនាំយកនូវបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងការកសាង ធនធានមនុស្ស ដែលជាកាតាលីករសំខាន់ក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈ ការរួមចំណែកបង្កើនផលិតភាពនិងប្រសិទ្ធភាពការងារ និងប្រែក្លាយកម្ពុជាពីប្រទេសកសិកម្ម និងឧស្សាហកម្មបែបប្រពៃណី ទៅជាឧស្សាហកម្មទំនើបជឿនលឿន។ តាមរយៈអនុស្សរណៈនេះ ក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធ រួមគ្នាប្រកបដោយភាពរស់រវើក ដោយបានរួមបញ្ចូលទស្សនៈ គោលជំហរ ឆន្ទៈ និងការប្តេជ្ញាចិត្ត ដើម្បីលើកកម្ពស់វិស័យបច្ចេកវិទ្យានិងវិទ្យាសាស្ត្រ។ ក្នុងរយៈពេល១០ឆ្នាំខាងមុននេះ ចេញពីការខិតខំប្រឹងប្រែង ក្រោមម្លប់នៃសន្តិភាព និងឈរលើស្មារតីខ្មែរធ្វើបាន កម្ពុជានឹងពោរពេញដោយធនធានមនុស្សប្រកបដោយជំនាញបច្ចេកទេស និងទេព្យកោសល្យខ្ពស់ដើម្បីជាចលករក្នុងការអភិវឌ្ឍសង្គមកម្ពុជា។

ក្នុងឱកាសនោះដែរ **ឯកឧត្តមរដ្ឋមន្ត្រី ជា វ៉ាន់ដេត** ក្នុងនាមជារដ្ឋមន្ត្រីទទួលបន្ទុកវិស័យបច្ចេកវិទ្យានៅកម្ពុជា បានលើកឡើងនូវចំណុចគន្លឹះថា ការកសាងធនធានមនុស្សគឺជារឿងសំខាន់បំផុតក្នុងការឈានឆ្ពោះទៅការអភិវឌ្ឍវិស័យបច្ចេកវិទ្យា និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា។ ឯកឧត្តមសូមវាយតម្លៃខ្ពស់ដល់ភាគីពាក់ព័ន្ធ ជាពិសេសក្រុមហ៊ុន សូហ្វៀរឧស្សាហកម្ម សៀមិនស៍ ភីធីអ៊ី អិលធីឌី ដែលបានខិតខំប្រឹងប្រែងឱ្យសម្រេចបានកិច្ចសហប្រត្តិការនេះ ដែលជាការចាប់ផ្តើមថ្មីដ៏សំខាន់នៃភាពជាដៃគូរវាងរដ្ឋនិង

ឯកជន ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្ស លើជំនាញវិស្វកម្ម បច្ចេកវិទ្យា និងឌីជីថល។ ចាប់តាំងពីវិបត្តិជំងឺកូវីដ១៩ នៅកម្ពុជា ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលមានសន្ទុះកាន់តែខ្លាំងក្នុងវិស័យសាធារណៈ វិស័យឯកជន និងក្នុងចំណោមប្រជាពលរដ្ឋទូទៅ ពិសេសសិស្ស-និស្សិត។ បដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ បានធ្វើឲ្យការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលកាន់តែមានលក្ខណៈចាំបាច់ និងទូលំទូលាយក្នុងគ្រប់វិស័យ រួមចំណែកជំរុញកំណើនសេដ្ឋកិច្ច។ ដើម្បីឲ្យការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលផ្តល់ផលប្រយោជន៍ខ្ពស់ដល់គ្រប់តួអង្គនៃសង្គម "គោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥" ត្រូវបានរៀបចំឡើងដោយមានសសរស្តម្ភចំនួន៣គឺ ពលរដ្ឋឌីជីថល រដ្ឋាភិបាលឌីថល និងធុរកិច្ចឌីជីថល។ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បន្តជំរុញការកសាងធនធានមនុស្សឌីជីថល ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារពលកម្មកម្ពុជា បន្តពង្រឹងវិសាលភាពនៃកម្មវិធីគាំទ្រនិងលើកទឹកចិត្តនានាឈានទៅបង្កើតលក្ខខណ្ឌអំណោយផលដល់ការបង្កើតនិងការវិនិយោគលើបច្ចេកវិទ្យាឌីជីថល ដែលមានសក្តានុពលសម្រាប់ចាប់យកខ្សែច្រវាក់ផលិតកម្មនិងតម្លៃឌីជីថល និងការអភិវឌ្ឍឈានទៅសម្រេចបានចក្ខុវិស័យប្រែក្លាយកម្ពុជា ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងចំណូលខ្ពស់នៅឆ្នាំ២០៥០។

តាមរយៈកិច្ចសហការនេះ ក្រុមហ៊ុន សៀមិនស៍ នឹងផ្តល់ជូននូវកញ្ចប់សូហ្វ៊ែរដែលមានអជ្ញាប័ណ្ណ (License software) ធនធានសម្ភារៈបណ្តុះបណ្តាល និងកម្មវិធីសិក្សាដល់ក្រសួងបរិស្ថាន ដើម្បីផ្តល់ជូនដល់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា តាមរយៈការជួយគាំទ្រសម្របសម្រួលផ្នែកជំបូន្មានបច្ចេកទេស និងការបណ្តុះបណ្តាលពី software ពីសាលា ស្ទឹមមីង ខេមបូឌា។ និស្សិត ដែលមកពីសាកលវិទ្យាល័យដៃគូទាំងនេះនឹងទទួលបានការបណ្តុះបណ្តាល ការប្រើប្រាស់សូហ្វ៊ែរដែលមានអាជ្ញាប័ណ្ណ និងការប្រឡងយកសញ្ញាបត្របញ្ជាក់សមត្ថភាពស្តង់ដាផងដែរ ក្រោមការជួយឧបត្ថម្ភពីក្រសួងបរិស្ថាន៕

ឯកឧត្តម សាយ សំអាល់ អញ្ជើញជួបសំណេះសំណាល និងពិសាអាហារសាមគ្គីជាមួយ បងប្អូនកម្មករកំពង់ផែស្វយ័តខេត្តព្រះសីហនុ

ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ បានអញ្ជើញជួបសំណេះសំណាល និងពិសាអាហារសាមគ្គីជាមួយបងប្អូនកម្មករកំពង់ផែស្វយ័ត នាល្ងាចថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២។

ក្នុងឱកាសសំណេះសំណាលនេះ **ឯកឧត្តមរដ្ឋមន្ត្រី សាយ សំអាល់** បានសម្តែងក្តីសោមនស្សរីករាយ ក៏ដូចជាកោតសរសើរនូវវីរភាពនៃមន្ត្រីគ្រប់លំដាប់ថ្នាក់ក្នុងកំពង់ផែស្វយ័តខេត្តព្រះសីហនុ ដែលបានបំពេញការងារប្រកបដោយវិជ្ជាជីវៈ មានវិន័យ ច្បាស់លាស់ និងការទទួលខុសត្រូវខ្ពស់ ដែលជាផ្នែកមួយក្នុងការចូលរួមរក្សានូវកំណើនសេដ្ឋកិច្ចក្នុងខេត្តព្រះសីហនុ និងទូទាំងប្រទេសផងដែរ។

ជាមួយគ្នានេះ **ឯកឧត្តម** គូសបញ្ជាក់ប្រាប់ដល់បងប្អូនកម្មករឱ្យដឹងបន្ថែមទៀតថា រាជរដ្ឋាភិបាលបាននិងកំពុងគាំទ្រដល់ការអភិវឌ្ឍខេត្តព្រះសីហនុឱ្យក្លាយជាខេត្តគំរូសេដ្ឋកិច្ចពហុបំណងតាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ប្រព័ន្ធចម្រោះទឹកកខ្វក់ ការរៀបចំទីក្រុងបានល្អស្អាត ហើយមានព្រលានយន្តហោះខ្នាតអន្តរជាតិ ដែលជាសក្តានុពលសេដ្ឋកិច្ចយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា និងរួមចំណែកផ្តល់ប្រយោជន៍ដល់ប្រជាពលរដ្ឋនៅក្នុងខេត្តព្រះសីហនុ នាពេលបច្ចុប្បន្ន និងទៅអនាគត។

គួរបញ្ជាក់ឱ្យដឹងថា ពិធីនេះក៏មានការអញ្ជើញចូលរួមពី ឯកឧត្តម គួច ចំរើន អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ឯកឧត្តម លូ គឹមឈន់ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ ថ្នាក់ដឹកនាំក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធ ដែលជាប្រធានក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋានខេត្តព្រះសីហនុ និងបងប្អូនកម្មករកំពង់ផែស្វយ័តខេត្តព្រះសីហនុ ជាង១ពាន់នាក់៕

«ការពង្រឹងមូលដ្ឋានសេដ្ឋកិច្ចសហគមន៍ គឺជាកូនសោរក្នុងការអភិរក្សជីវៈចម្រុះប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព»

នៅព្រឹកថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ នាទីស្តីការក្រសួងបរិស្ថាន **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានទទួលជួបលោកស្រី Timsin Ballard ប្រធានប្រតិភូនៃមូលនិធិ Biodiversity Landscape Fund (BLF) របស់ចក្រភពអង់គ្លេស ដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងការអនុវត្តគម្រោងក្រោមមូលនិធិ BLF នេះនៅប្រទេសកម្ពុជា។ លោកស្រីបានបញ្ជាក់នៅក្នុងជំនួបនេះថា មូលនិធិ BLF ផ្តោតអាទិភាពលើការងារចំនួន ៣ គឺ ការកាត់បន្ថយភាពក្រីក្រ ការអភិរក្សជីវៈចម្រុះ និងការប្រែប្រួលអាកាសធាតុ។

ជាការឆ្លើយតប **ឯកឧត្តមរដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា ការពង្រឹងមូលដ្ឋានសេដ្ឋកិច្ចសហគមន៍ គឺជាកូនសោរក្នុងការអភិរក្សជីវៈចម្រុះប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។ ឯកឧត្តមរដ្ឋមន្ត្រីបានបន្តថា សម្រាប់កម្ពុជា អាទិភាពអភិវឌ្ឍន៍ រួមមានការអភិវឌ្ឍធនធានមនុស្ស ការអភិវឌ្ឍដោយចីរភាព ការពង្រឹងអភិបាលកិច្ច និងការពង្រីកច្រកពាណិជ្ជកម្ម ហើយកម្ពុជាស្វាគមន៍ចំពោះការពង្រីកកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មជាមួយចក្រភពអង់គ្លេស ជាពិសេសការនាំចេញផលិតផលសហគមន៍មូលដ្ឋាន ដូចជា អង្ករ (blueberry rice) ស្វាយចន្ទី និងចេក ការលក់ឥណទានកាបូន និងការវិនិយោគលើប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ និងការអភិវឌ្ឍទេសចរណ៍។ ល្គឹកណាប្រជាសហគមន៍មូលដ្ឋាននៅតែប្រឈមនឹងភាពក្រីក្រ យើងមិនអាចនិយាយអំពីកិច្ចការអភិរក្សបានឡើយ។

លោកស្រី Timsin Ballard បានបញ្ជាក់ជូនឯកឧត្តមរដ្ឋមន្ត្រីថា អាទិភាពអភិវឌ្ឍន៍ទាំងនេះឆ្លើយតបយ៉ាងវិជ្ជមានទៅនឹងគោលដៅ និងគោលបំណងរបស់មូលនិធិ BLF ហើយលោកស្រីនឹងជំរុញឱ្យមានការចុះអនុស្សរណៈនៃការយោគយល់រវាងចក្រភពអង់គ្លេស និងកម្ពុជា ដោយមានក្រសួងបរិស្ថានជាស្ថាប័នបង្គោល ក្នុងការអនុវត្តគម្រោងក្រោមមូលនិធិនេះ៕

ក្រសួងបរិស្ថាន ប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ "សៀវភៅមគ្គុទេសក៍ស្ដីពីគ្រឿងទេសនៅប្រទេសកម្ពុជា" និងវេទិកាកេសរកូលជាតិលើកទី២

ក្រសួងបរិស្ថាន បានផ្ដួចផ្ដើមគំនិត និងរៀបចំជា "សៀវភៅមគ្គុទេសក៍ស្ដីពីគ្រឿងទេសនៅប្រទេសកម្ពុជា" ដំបូងគេ និងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការក្នុងវេទិកាកេសរកូលជាតិលើកទី២ នាថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ នៅអគារខេមរានី សហភាពសហព័ន្ធយុវជនកម្ពុជារាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។

វេទិកាកេសរកូលជាតិលើកទី២នេះ រៀបចំឡើងក្នុងគោលបំណងសំខាន់ៗរួមមាន៖ ១)ផ្សព្វផ្សាយឱ្យសាធារណជនបានស្គាល់ពីប្រភេទកេសរកូលព្រៃរបស់កម្ពុជា ២)ចែករំលែកព័ត៌មានស្ដីពីវឌ្ឍនភាពនៃការរៀបចំមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន ៣)ចូលរួមចំណែកលើកកម្ពស់វិស័យទេសចរណ៍ធម្មជាតិ និង៤)ផ្សារភ្ជាប់បណ្ដាញអ្នកសិក្សាស្រាវជ្រាវ និងពង្រឹងការអភិរក្សកេសរកូលព្រៃនៅកម្ពុជា។

ដោយឡែក សៀវភៅមគ្គុទេសក៍ស្ដីពីគ្រឿងទេសនៅប្រទេសកម្ពុជា ក្រសួងបានរៀបចំឡើង ដើម្បីកំណត់អត្តសញ្ញាណ ចងក្រងទុកជាឯកសារ អំពីលក្ខណៈជីវសាស្ត្រ រូបសាស្ត្រ សារប្រយោជន៍ ចំណេះដឹងជាប្រពៃណី និងរបៀបនៃការប្រើប្រាស់ រុក្ខជាតិគ្រឿងទេសនៅកម្ពុជា ដែលប្រជាជនតែងតែអនុវត្តតាំងពីដូនតាសម្រាប់ធ្វើជាគ្រឿងផ្សំក្នុង ម្ហូបអាហារប្រចាំថ្ងៃ និងជាឱសថថែរក្សាសុខភាព និងព្យាបាលជំងឺ។

ក្នុងឱកាសនោះដែរ ក៏មានការចុះអនុស្សរណៈនៃកិច្ចសហប្រតិបត្តការរវាងក្រសួងបរិស្ថាន និងសួនរុក្ខឧទ្យាន KEW នៃចក្រភពអង់គ្លេស ស្ដីពីកិច្ចសហប្រតិបត្តិការក្នុងការ បង្កើត និងដំណើរការនៃការអភិរក្សជីវៈចម្រុះក្រៅដែនធម្មជាតិនៅកម្ពុជា។ អនុស្សរណៈនៃកិច្ចសហប្រតិបត្តការរវាងក្រសួងបរិស្ថាន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ស្ដីពីកិច្ចសហការរៀបចំ និងប្រតិបត្តិការរបស់ មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន។

គួរបញ្ជាក់ឱ្យដឹងថា វេទិកាកេសរកូលជាតិលើកទី២ និងសៀវភៅមគ្គុទេសក៍ស្ដីពីគ្រឿងទេសនៅប្រទេសកម្ពុជានេះ បានរៀបចំឡើងនៅអគារខេមរានី សហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក.) រាជធានីភ្នំពេញ ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួង ស្ថាប័ន ស្ថានទូត អង្គការដៃគូ វិស័យឯកជន អ្នកជំនាញជាតិ និងអន្តរជាតិ សិស្ស និស្សិត និងអ្នកពាក់ព័ន្ធ។

សៀវភៅមគ្គុទេសក៍ស្តីពីគ្រឿងទេសនៅប្រទេសកម្ពុជា នឹងមានចែកជូនដល់សាធារណជនបណ្តាញសារព័ត៌មាន តំណាងស្ថាប័ន និងសិស្ស និស្សិតដែលអញ្ជើញចូលរួមក្នុងវេទិកាកេសរកូលជាតិ លើកទី២ និងទស្សនាពិព័រណ៍កេសរកូល ដោយសេរី នៅអគារខេមរានីសហភាពសហព័ន្ធយុវជនកម្ពុជារាជធានីភ្នំពេញ៕

ឯកឧត្តម សាយ សំអាល់៖ និស្សិតកម្ពុជា ត្រូវចេះអភិវឌ្ឍន៍សមត្ថភាពខ្លួន ចេះធ្វើការងារជាក្រុម និងរៀនសូត្រអំពីការវិវត្តន៍នៃសភាពការណ៍នយោបាយពិភពលោក

និស្សិតកម្ពុជា ត្រូវចេះអភិវឌ្ឍន៍សមត្ថភាពខ្លួន ចេះធ្វើ ការងារជាក្រុម និងរៀនសូត្រអំពីការវិវត្តន៍នៃសភាពការណ៍នយោបាយពិភពលោក ជាប្រសាសន៍របស់ **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន នាឱកាសជួបសំណេះសំណាលជាមួយនិស្សិតជ័យលាភីអាហារូបករណ៍ទៅសិក្សានៅអូស្ត្រាលី ចំនួន២១នាក់ នៅទីស្តីការក្រសួងបរិស្ថាន នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២។

ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តមរដ្ឋមន្ត្រី** បានចែករំលែកជាពិសោធន៍ក្នុងការរស់នៅអូស្ត្រាលី និងផ្តល់ជាអនុសាសន៍ជូននិស្សិតកម្ពុជាថា ក្រៅពីឱកាសអភិវឌ្ឍន៍សមត្ថភាពខ្លួន ប្អូនៗក៏ត្រូវប្រឹងប្រែងសិក្សាស្វែងយល់អំពីជីវភាពរស់នៅប្រចាំថ្ងៃ ជាពិសេសការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់ប្រទេសអូស្ត្រាលី ដែលជាប្រទេសមានភាពសំបូរបែបលើអាហារូបត្ថម្ភ។ មិនតែប៉ុណ្ណោះ ឯកឧត្តមរដ្ឋមន្ត្រី បានបន្តទៀតថា ប្អូនៗនិស្សិតត្រូវជឿជាក់លើខ្លួនឯង ចេះធ្វើការងារជាក្រុម និងរៀនសូត្រអំពីការវិវត្តន៍នៃសភាពការណ៍នយោបាយពិភពលោក ដើម្បីអភិវឌ្ឍន៍សមត្ថភាពខ្លួន ស្របតាមបរិបទនយោបាយក្នុងតំបន់ និងលើកតម្កើងសេដ្ឋកិច្ចគ្រួសារ ដែលជាផ្នែកមួយក្នុងការលើកកម្ពស់ផលប្រយោជន៍របស់កម្ពុជាផងដែរ៕

ឯកឧត្តម សាយ សំអាល់ ៖ ជាច្រកផ្លូវទៅកាន់ចំណេះដឹង និងវប្បធម៌ បណ្ណាល័យបានដើរតួនាទីយ៉ាងសំខាន់ជាមូលដ្ឋាននៅក្នុងការសិក្សា ក៏ដូចជាសង្គម

«ជាច្រកផ្លូវទៅកាន់ចំណេះដឹង និងវប្បធម៌ បណ្ណាល័យបានដើរតួនាទីយ៉ាងសំខាន់ជាមូលដ្ឋាននៅក្នុងការសិក្សា ក៏ដូចជាសង្គម»។ នេះគឺជាការថ្លែងរបស់**ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ ក្នុងឱកាសនៃការអញ្ជើញជាអធិបតីក្នុងពិធីក្រុងពាលី សុំម្ចាស់ទឹកម្ចាស់ដី ដើម្បីសាងសង់បណ្ណាល័យនៅសាលាបឋមសិក្សា និងវិទ្យាល័យហ៊ុន សែន មិត្តភាព ស្ថិតនៅសង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

ពិធីក្រុងពាលី ដែលប្រព្រឹត្តទៅនៅព្រឹកថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ ក៏មានការអញ្ជើញចូលរួមពីឯកឧត្តម គួច ចំរើន អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ឯកឧត្តម តឹករ៉េត សំរេច ឯកឧត្តម លូ គឹមឈន់ ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី ជាក្រុមកាងារ លោកគ្រូ អ្នកគ្រូ ក្រុមយុវជនកាកបាតក្រហមកម្ពុជា យុវជនកាយាប្ញទ្ធិ សិស្សានុសិស្សនៃសាលាបឋមសិក្សា និងវិទ្យាល័យហ៊ុន សែន មិត្តភាព យ៉ាងច្រើនកុះករ។

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន បានមានប្រសាសន៍ថា បណ្ណាល័យជាកន្លែងបង្កើតឱកាសសម្រាប់សិស្ស និស្សិត ធ្វើការសិក្សា ស្រាវជ្រាវ និងជួយបង្កើតគំនិត និងទស្សនៈថ្មីៗ ដែលជាចំណុចស្នូលនៃសង្គម ប្រកបដោយភាពច្នៃប្រឌិត និងទំនើបកម្ម។

បណ្ណាល័យដែលជាចំណងដៃថ្មីសម្រាប់សិស្សានុសិស្សសាលាបឋមសិក្សា និងវិទ្យាល័យហ៊ុន សែន មិត្តភាព មានបណ្ដោយ២៥ម៉ែត្រ ទទឹង៨ម៉ែត្រ កម្ពស់២ជាន់ ហើយនឹងត្រូវចំណាយពេលសាងសង់ជាង៥ខែ ក្រោមការឧបត្ថម្ភកសាងដោយក្រសួងបរិស្ថាន រដ្ឋបាលខេត្តព្រះសីហនុ ក្រសួងអប់រំ និងកំពង់ផែស្វយ័តក្រុងព្រះសីហនុ៕

ឯកឧត្តម សាយ សំអាល់៖ កម្ពុជាជាប្រធានអាស៊ាន គឺជាមោទនភាពដ៏ធំធេងរបស់ប្រជាជនខ្មែរគ្រប់រូប

«កម្ពុជាជាប្រធានអាស៊ានគឺជាមោទនភាពដ៏ធំធេងរបស់ប្រជាជនខ្មែរគ្រប់រូប។ នេះគឺជាប្រសាសន៍លើកឡើងរបស់ **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ ក្នុងឱកាសអញ្ជើញជួបសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ នៅស្រុកព្រៃនប់ ខេត្តព្រះសីហនុ និងមានការអញ្ជើញចូលរួមពីឯកឧត្តម គួច ចំរើន អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី និងលោកគ្រូ អ្នកគ្រូ ជាច្រើនរូបចូលរួម នាថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ ។

ឯកឧត្តមប្រធានក្រុមការងារ បានគូសបញ្ជាក់ឱ្យដឹងទៀតថា កាលពីថ្មីៗនេះ សម្តេចតេជោនាយករដ្ឋមន្ត្រី បានបំពេញទស្សនកិច្ចនៅសហរដ្ឋអាមេរិក ក្នុងនាមជាប្រធានអាស៊ាន ក្នុងនាមជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ នេះជាលើកទី១ ក្រោយសង្គ្រាមវៀតណាម ដែលថ្នាក់ដឹកនាំកម្ពុជាមានវត្តមាននៅលើទឹកដីសហរដ្ឋអាមេរិក។ ទង់ជាតិកម្ពុជា ជាមួយនឹងទង់ជាតិសហរដ្ឋមេរិក ទង់អាស៊ាន ដែលកម្ពុជាក្នុងនាមជាប្រទេស ជាប្រធានអាស៊ានដឹកនាំគណៈប្រតិភូទៅប្រជុំនៅសហរដ្ឋអាមេរិក។ នេះគឺជាមោទនភាពដ៏ធំធេងរបស់ប្រជាជនខ្មែរគ្រប់រូប។ នេះសរបញ្ជាក់ថា យើងបានធ្វើរឿងដ៏ត្រឹមត្រូវ យើងបានបញ្ចប់សង្គ្រាមដ៏រ៉ាំរ៉ៃនៅកម្ពុជា ស្តារ និងកសាងកម្ពុជា រហូតដល់កម្រិតមួយដែលយើងជាប្រធានអាស៊ានឈរដោយមោទនភាពជាបណ្តាប្រទេសផ្សេងទៀតនៅលើទឹកដីសហរដ្ឋអាមេរិក។ នេះជាជោគជ័យមួយដ៏ធំធេងរបស់ប្រទេសកម្ពុជាតែម្តង។

ឯកឧត្តម សាយ សំអាល់ បានសង្កត់ធ្ងន់ថា ការវិវត្តរបស់កម្ពុជាក្នុងរយៈពេលចុងក្រោយនេះ ជាការវិវត្តជាប្រវត្តិសាស្ត្រ នឹងធ្វើឱ្យអនាគតកម្ពុជាភ្លឺស្វាង និងច្បាស់លាស់ជាងមុនបន្ថែមទៀត ដោយគ្មាននរណាអាចធ្វើបានក្រៅពីសម្តេចតេជោ នាយករដ្ឋមន្ត្រីនោះទេ ដែលដឹកនាំនាវាកម្ពុជាឱ្យទៅមុខបន្តទៀត ជាមួយនឹងការធានាបាននូវអនាគតមួយដ៏រុងរឿងសម្រាប់ប្រជាជនកម្ពុជា។

ឆ្លៀតក្នុងឱកាសជួបសំណេះសំណាលនេះដែរ **ឯកឧត្តម សាយ សំអាល់** បានកោតសសើរ វាយតម្លៃខ្ពស់ និងសូមថ្លែងអំណរគុណចំពោះលោកគ្រូ អ្នកគ្រូ ក្នុងការចូលរួមទប់ស្កាត់រីករាលដាលនៃជំងឺកូវីដ-១៩។ ជាពិសេស គឺការចូលរួមចាក់វ៉ាក់សាំងដើម្បីបង្កើតនូវសហគមន៍បន្សាំ ដែលអនុញ្ញាតឱ្យយើងបានបើក

ប្រទេសឡើងវិញ។ ជាមួយគ្នានេះ ឯកឧត្តមក៏សូមកោតសរសើរដល់លោកគ្រូ អ្នកគ្រូ ក្នុងការចូលរួមអនុវត្តគោលនយោបាយអប់រំយ៉ាងខ្ជាប់ខ្ជួន ការធ្វើកំណែទម្រង់លើវិស័យអប់រំ ជាមួយនឹងការលះបង់ទាំងកម្លាំងកាយ ចិត្ត ប្រាជ្ញា ចូលរួមជាមួយនឹងរាជរដ្ឋាភិបាល ដើម្បីអនុវត្តឱ្យបានជោគជ័យគោលនយោបាយវិស័យអប់រំ។ **ឯកឧត្តម** បានអំពាវនាវ និងលើកទឹកចិត្តចំពោះលោកគ្រូ អ្នកគ្រូ អនុវត្តគោលនយោបាយនេះ ឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត៕

ការលះបង់ពិតប្រាកដប្រកបដោយភាពស្មោះត្រង់របស់លោកបេន និងក្រុមគ្រួសារចំពោះបុព្វហេតុធនធានធម្មជាតិនៅកម្ពុជា ទទួលបានការគាំទ្រនិងលើកទឹកចិត្តដោយការផ្តល់សញ្ជាតិខ្មែរ

«ចាប់តាំងពីព្រះមហាក្សត្រ ជាទីគោរពសក្ការៈនៃយើងឡាយព្រះហស្តលេខាប្រោសព្រះរាជទានសញ្ជាតិខ្មែរជូនដល់លោកបេន និងក្រុមគ្រួសារកាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២មក លោកបេន និងក្រុមគ្រួសារបានក្លាយជាពលរដ្ឋខ្មែរ និងមានសិទ្ធិដូចប្រជាពលរដ្ឋខ្មែរទូទៅដែរ»។ នេះគឺជាការថ្លែងរបស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី មាស សុភា** ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះវិហារ នៅរសៀលថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២២ ក្នុងឱកាសដែលឯកឧត្តមចូលរួមជាអធិបតីប្រគល់ព្រះរាជក្រឹត្យស្តីពីការផ្តល់សញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មជាចង្កោមគ្រួសារដល់គ្រួសារលោក ដាវីស បេន នៅរដ្ឋបាលខេត្តព្រះវិហារ។

ឯកឧត្តមទេសរដ្ឋមន្ត្រីបានគូសបញ្ជាក់ថាពិតជាស័ក្តិសមបំផុតដែលក្រុមគ្រួសារ លោកបេនត្រូវទទួលបានព្រោះលោកនិងក្រុមគ្រួសារ បានសុខចិត្តចោលស្រុកទេសរបស់ខ្លួនមករស់នៅលើទឹកដីកម្ពុជាប្រមាណ ៣០ ឆ្នាំមកហើយ ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ថែរក្សាការពារអភិរក្សធនធានធម្មជាតិ។

ជាមួយការថ្លែងអបអរសាទរដល់លោកបេន និងក្រុមគ្រួសារដែលត្រូវបានព្រះមហាក្សត្រប្រោសព្រះរាជទានផ្តល់សញ្ជាតិខ្មែរជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី មាស សុភា** បានមានប្រសាសន៍ថា៖ «នេះគឺជាលទ្ធផលដែលកើតចេញពីកិច្ចខិតខំប្រឹងប្រែងរបស់លោកបេន និងក្រុមគ្រួសារផ្ទាល់ផង និងចេញពីការយកចិត្តទុកដាក់របស់ព្រះមហាក្សត្រជាទីគោរពសក្ការៈ របស់ប្រមុខរាជរដ្ឋាភិបាល និងរបស់**ឯកឧត្តមរដ្ឋមន្ត្រី**ក្រសួងបរិស្ថានចំពោះអ្វីដែលជាកិច្ចខិតខំប្រឹងប្រែងរបស់លោកបេន និងក្រុមគ្រួសារ និងក្រោមការយកចិត្តទុកដាក់របស់អាជ្ញាធរដែនដីជាពិសេសពីអភិបាលខេត្ត អភិបាលស្រុក និងភូមិឃុំផងដែរ»។

ឯកឧត្តមទេសរដ្ឋមន្ត្រីបានជំរុញនិងលើកទឹកចិត្តដល់លោកបេន និងក្រុមគ្រួសារ ព្រមទាំងអាជ្ញាធរពាក់ព័ន្ធបន្តសហការគ្នាល្អលើការការពារនិងអភិរក្សធនធានធម្មជាតិ ដោយបានកត់សម្គាល់ថា ជាមួយការអប់រំ បំភ្លឺផ្សព្វផ្សាយពន្យល់នាពេលកន្លងទៅ ប្រជាពលរដ្ឋមានការយល់ដឹងអំពីសារៈសំខាន់នៃការអភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះ ហើយពួកគាត់បានចូលរួមក្នុងការអភិរក្ស។

ចូលរួមក្នុងពិធីនេះដែរ **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថានបានថ្លែងថា៖ «កម្ពុជាបានក្លាយជាផ្ទះរបស់បេននិងក្រុមគ្រួសារ។ ថ្ងៃនេះជាថ្ងៃមួយដ៏វិសេសវិសាលសម្រាប់បេន និងក្រុមគ្រួសារ និងក្នុងនាមក្រសួងបរិស្ថានសូមគោរពថ្លឹងគុណ និងថ្លែងអំណរគុណចំពោះ**សម្តេចតេជោនាយករដ្ឋមន្ត្រី**

និងសម្តេចគតិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុន សែន ដែលលោកទាំងពីរបានអនុញ្ញាតដ៏ខ្ពង់ខ្ពស់ឱ្យយើងខ្ញុំតាមសំណើរបស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី មាស សុភា** ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះវិហារ បានធ្វើសំណើទៅសម្តេចតេជោនាយករដ្ឋមន្ត្រីដើម្បីស្នើសញ្ជាតិខ្មែរជូនដល់លោកបេន និងក្រុមគ្រួសារ។ **សម្តេចតេជោ** ក៏បានទូលថ្វាយព្រះមហាក្សត្រ ហើយព្រះមហាក្សត្រជាទីគោរពសក្ការៈនៃយើងក៏បានសព្វព្រះរាជហឫទ័យថ្វាយសញ្ជាតិខ្មែរជូនដល់លោកបេន និងក្រុមគ្រួសារ»។

ជាមួយគ្នានេះ **ឯកឧត្តមរដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់រដ្ឋបាលខេត្ត និងអាជ្ញាធរស្រុកឃុំរបស់ខេត្តព្រះវិហារដែលបានចូលរួម ជាមួយក្រសួងបរិស្ថានក្នុងការអភិរក្សធនធានធម្មជាតិ។

ឯកឧត្តមរដ្ឋមន្ត្រី បានគូសបញ្ជាក់ថា«លោកបេននិងក្រុមគ្រួសារស្ថិតក្នុងចំណោមមនុស្សជាច្រើនដែលបានមកបំពេញការងារនៅកម្ពុជាយូរដែលបានទទួលការលើកទឹកចិត្ត។ លោកបេននិងក្រុមគ្រួសារបានលះបង់កម្លាំងកាយកម្លាំងចិត្តជាមួយមន្ត្រីឧទ្យានុរក្សនៃមន្ទីរបរិស្ថាន ក្រសួងបរិស្ថាន ក៏ដូចជាបានចូលរួមជាមួយរដ្ឋបាលខេត្តក្នុងការការពារនិងអភិរក្សធនធានធម្មជាតិនៅខេត្តព្រះវិហារ បានធ្វើឱ្យការការពារនិងអភិរក្សធនធានធម្មជាតិនៅខេត្តព្រះវិហារកាន់តែមានភាពល្អប្រសើរ»។

សូមបញ្ជាក់ថា លោក បេន ដាវីស ជាសញ្ជាតិអាម៉េរិក និងភរិយាកូនៗមានសញ្ជាតិអូស្ត្រាលី ក៏គ្រួសារលោកបេន ពិតជាស័ក្តិសមបំផុតក្នុងការទទួលបាននូវសញ្ជាតិខ្មែរពីព្រោះលោកបេន បានមករស់នៅ និងបានធ្វើការនៅកម្ពុជាតាំងពីឆ្នាំ១៩៩២មកម្ល៉េះ ពោលគឺតាំងពីលោកបេន មានអាយុ ២៧ឆ្នាំ គឺមានរយៈពេលជិត ៣០ឆ្នាំមកហើយ។ លោកបេន បានមកបំពេញការងារនៅខេត្តព្រះវិហាររយៈពេល ២០ឆ្នាំហើយតាំងពីឆ្នាំ២០០២។ ស្ថិតក្នុងរយៈពេលនេះ លោកបេន និងក្រុមគ្រួសារបាន លះបង់កម្លាំងកាយចិត្ត បញ្ញា និងធនធានផ្ទាល់ខ្លួនដើម្បីបុព្វហេតុមនុស្សធម៌លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ការងារសង្គមផ្សេងៗ និងដើម្បីបុព្វហេតុការពារនិងអភិរក្សធនធានព្រៃឈើនិងសត្វព្រៃនៅក្នុងដែនជម្រកសត្វព្រៃភ្នំត្នោត-ភ្នំពក ស្ថិតក្នុងភូមិសាស្ត្រស្រុកសង្គមថ្មី និងស្រុកគូលែននៃខេត្តព្រះវិហារ និងស្រុកជីក្រែងខេត្តសៀមរាប។ កាលដែលរូបលោកបេន និងគ្រួសារទទួលបានសញ្ជាតិខ្មែរពិតជារឿងដែលត្រឹមត្រូវនិងសក្តិសមជាទីបំផុត។ គ្រួសារលោកបេនតែងតែទទួលបាននូវការយកចិត្តទុកដាក់គាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា និងការស្រឡាញ់រាប់អានពីប្រជាពលរដ្ឋខ្មែរជាទូទៅជាពិសេសមានការគាំទ្រឧបត្ថម្ភពីសំណាក់សម្តេចគតិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុន សែន នូវរថយន្ត និងម៉ូតូ និងថវិកាផងដែរ។ ក្រសួងបរិស្ថានបានផ្តល់នូវការគាំទ្រថវិកាបន្ថែម។

លោក បេន ដាវីស តំណាងក្រុមគ្រួសាររបស់ខ្លួនដែលមានសមាជិក ៤រូប បានថ្លែងអំណរគុណ រាជរដ្ឋាភិបាលកម្ពុជាដែលបានផ្តល់ការគាំទ្រនិងលើកទឹកចិត្តលោក។ លោកបេន ដាវីស បានថ្លែងថា«ខ្ញុំមិននឹកស្មានថាខ្ញុំទទួលបានសញ្ជាតិខ្មែរនេះទេ ខ្ញុំពិតជាមានសេចក្តីសប្បាយរីករាយនិងសូមគោរពថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជានិងអាជ្ញាធរគ្រប់ជាន់ថ្នាក់ដែលបានយកចិត្តទុកដាក់លើយើងខ្ញុំ។ យើងខ្ញុំមានភាពកក់ក្តៅ និងមានការលើកទឹកចិត្តយើងខ្ញុំនិងខ្ញុំមានការសប្បាយចិត្តនឹងកិច្ចសហការជាមួយអាជ្ញាធរក្នុងកិច្ចការអភិវឌ្ឍ និងបច្ចុប្បន្នក្នុងកិច្ចការពារអភិរក្សព្រៃឈើ»៕

ឯកឧត្តម សាយ សំអាល់ លើកទឹកចិត្តឱ្យដៃគូអភិវឌ្ឍន៍ចូលរួមជាមួយក្រសួងបរិស្ថាន រៀបចំប្រព័ន្ធគ្រប់គ្រងសំណល់រឹងនៅទូទាំងប្រទេស

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន បានទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូធនាគារអភិវឌ្ឍន៍អាស៊ី ដែលដឹកនាំដោយ លោក Anthony Gill នាយកស្តីទីប្រចាំប្រទេសកម្ពុជា អំពីការគាំទ្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងវិស័យគ្រប់គ្រងសំរាម សំណល់រឹង និងការពិនិត្យលទ្ធភាពក្នុងការសហការគ្នាពាក់ព័ន្ធការកំណែទម្រង់ និងការផ្តួចផ្តើមរៀបចំប្រព័ន្ធឌីជីថលសម្រាប់ការគ្រប់គ្រងនេះ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ នាទីស្តីការក្រសួងបរិស្ថាន។

ឆ្លៀតក្នុងឱកាសនេះ **ឯកឧត្តមរដ្ឋមន្ត្រី** បានជម្រាបគណៈប្រតិភូ អំពីវឌ្ឍនៈភាពការងារនិងទិសដៅសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹង ដោយផ្តើមពីការរៀបចំឱ្យមានសេវាប្រមូលទីលានទុកដាក់ និងប្រព័ន្ធប្រមូលចំណូល សំដៅរក្សានិរន្តរភាពនៃការគ្រប់គ្រងសំរាម សំណល់រឹង។

ជាលទ្ធផល ក្រុមការងារធនាគារអភិវឌ្ឍន៍អាស៊ី និងក្រសួងបរិស្ថាននឹងបន្តកិច្ចសហការក្នុងការកំណត់កិច្ចការដែលធនាគារអាចផ្តល់ការគាំទ្របន្ថែមពាក់ព័ន្ធនឹងការរៀបចំនិងដំណើរការប្រព័ន្ធឌីជីថល ក៏ដូចជា ការគ្រប់គ្រងសំរាម សំណល់រឹង ដែលក្រសួងបរិស្ថានបាននិងកំពុងអនុវត្ត៕

កិច្ចប្រជុំលើកទី៣ ក្រុមប្រឹក្សាភិបាលប្រតិបត្តិនៃកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ដំណាក់កាលទី៣

នាថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គនាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រ ក្រសួងបរិស្ថាន ក្រោមការគាំទ្រពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជាដំណាក់កាលទី៣ (CCCA3) បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលប្រតិបត្តិលើកទី៣ ក្រោមអធិបតីភាព **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាភិបាល CCCA3 ដោយមានការចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាលប្រតិបត្តិ តំណាងពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងបរិស្ថាន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងរ៉ែនិងថាមពល និងដៃគូអភិវឌ្ឍន៍រួមមាន៖ សហភាពអឺរ៉ុប(EU) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ព្រមទាំងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិពីក្រសួង-ស្ថាប័នពាក់ព័ន្ធនានាផងដែរ។

ឯកឧត្តមរដ្ឋមន្ត្រី មានប្រសាសន៍ថា ប្រទេសកម្ពុជាបានប្រឈមផលប៉ះពាល់ពីការរាតត្បាតនៃជំងឺកូវីដ-១៩ ប៉ុន្តែក្រោមការដឹកនាំយ៉ាងត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជាយើងអាចគ្រប់គ្រងបានទាំងស្រុង ហើយបានបង្ហាញពីការងើបឡើងកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់។ ជំងឺកូវីដ-១៩បង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ច ប៉ុន្តែផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុកាន់តែបង្កហានិភ័យខ្លាំងក្លានិងយូរអង្វែងដល់ការរស់នៅរបស់ប្រជាពលរដ្ឋ និងផែនការអភិវឌ្ឍន៍របស់ប្រទេស ដូចនេះការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមគួរតែត្រូវគិតគូរអំពីភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងបញ្ហាហានិភ័យចំពោះសុខភាពផ្សេងៗទៀត។

ឯកឧត្តម បានបង្ហាញពីសកម្មភាព និងកិច្ចសហការសំខាន់ៗជាមួយក្រសួងពាក់ព័ន្ធក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនិងការលើកកម្ពស់សេដ្ឋកិច្ច រួមមានការបញ្ជ្រាបការប្រែប្រួលអាកាសធាតុក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងកិច្ចសហការជាមួយវិស័យឯកជន។ **ឯកឧត្តមរដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់ផងដែរថា ដើម្បីដោះស្រាយការប្រែប្រួលអាកាធាតុនិងការគ្រប់គ្រងធនធានធម្មជាតិយើងត្រូវកសាងសេដ្ឋកិច្ចគ្រួសារ បង្កើតឱកាសទីផ្សារ និងកសាងសេដ្ឋកិច្ចតំបន់ជនបទ។ ក្នុងឱកាសនោះដែរ លោកជំទាវឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំនៅកម្ពុជាបានបង្ហាញការគាំទ្រ និងកោតសរសើរអំពីសមិទ្ធផលសំខាន់ៗលើការដោះស្រាយការ

ប្រែប្រួលអាកាសធាតុរបស់រាជរដ្ឋាភិបាល។ លោកជំទាវក៏បានបង្ហាញអំពីកម្មវិធីសហភាពអឺរ៉ុបឆ្នាំ២០២១-២០២៧ មានទឹកប្រាក់សរុប១៥៥លានដុល្លារសហរដ្ឋអាមេរិកសម្រាប់វិស័យសំខាន់ៗចំនួន០៣រួមមាន៖ ការអភិវឌ្ឍបៃតងនិងការងារសមរម្យ ការអប់រំនិងបំណិន និងអភិបាលកិច្ចល្អ។

កិច្ចប្រជុំបានពិនិត្យ និងពិភាក្សាលើសមិទ្ធផលការងារសម្រេចបានសំខាន់ៗរបស់CCCA3 ក្នុងឆ្នាំ២០២១ និងបានអនុម័តលើផែនការសកម្មភាពសម្រាប់ឆ្នាំ២០២២-២០២៣។ កិច្ចប្រជុំក៏បានពិភាក្សា អំពីផែនការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូននៅកម្ពុជា វឌ្ឍនភាពនៃការរៀបចំអនុក្រឹត្យស្តីពីការគ្រប់គ្រងយន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការអនុវត្តគម្រោងមូលនិធិជំនួយឥតសំណងនវានុវត្តន៍ការសិក្សាស្រាវជ្រាវ និងកិច្ចសហការរវាងអន្តរក្រសួង ដើម្បីភ្ជាប់ទំនាក់ទំនងគោលនយោបាយនិងហិរញ្ញវត្ថុ និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជានិងសហភាពអឺរ៉ុបក្នុងវិស័យបរិស្ថាននិងសង្គម សម្រាប់ឆ្នាំ២០២១-២០២៧៕

«ការពង្រឹងមូលដ្ឋានសេដ្ឋកិច្ចសហគមន៍ គឺជាកូនសោរក្នុងការអភិរក្សជីវចម្រុះតាមតំបន់ឆ្នេរ ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព»

នៅថ្ងៃទី០៩ខែឧសភាឆ្នាំ២០២២ នាទីស្តីការក្រសួងបរិស្ថាន **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានទទួលជួបគណៈប្រតិភូដៃគូអភិវឌ្ឍន៍ និងអង្គការ ដូចជា កម្មវិធីមូលនិធិសកម្មភាពខៀវ (BAF) គម្រោងធនាគារអភិវឌ្ឍន៍(KfW) អង្គការ FFI ដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងចក្ខុវិស័យ និងការអនុវត្តគម្រោងអភិរក្សនៅតាមតំបន់ឆ្នេរប្រទេសកម្ពុជា។

លោកបានបញ្ជាក់នៅក្នុងជំនួបនេះថា គម្រោងនេះផ្តោតអាទិភាពលើការងារចំនួន០២ គឺការកាត់បន្ថយភាពក្រីក្រក្នុងសហគមន៍ និងការអភិរក្សជីវៈចម្រុះ ។

ជាការឆ្លើយតប **ឯកឧត្តមរដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា ការពង្រឹងមូលដ្ឋានសេដ្ឋកិច្ចសហគមន៍ គឺជាកូនសោរក្នុងការអភិរក្សជីវៈចម្រុះតាមតំបន់ឆ្នេរប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។ ឯកឧត្តមរដ្ឋមន្ត្រី ស្នើឱ្យគម្រោងគិតគូពីការផ្តល់ជម្រើសថ្មីសម្រាប់ប្រជាសហគមន៍មូលដ្ឋាន ពីការពឹងផ្អែកលើអនុផលធនធានធម្មជាតិ តាមរយៈការលើកទឹកចិត្តឱ្យមានការចិញ្ចឹមគ្រឿងសមុទ្រ សត្វ និងការផ្តល់កម្ចីដែលមានការប្រាក់ទាប ដើម្បីផ្តល់ឱកាសឱ្យប្រជាសហគមន៍មានជីវភាពប្រសើរ និងកសាងសេដ្ឋកិច្ចមូលដ្ឋានកាន់តែរឹងមាំ៕

ឯកឧត្តម សាយ សំអាល់៖ កត្តាសុខសន្តិភាព និងស្ថេរភាពនយោបាយ កំពុងធ្វើឱ្យប្រជាជន មានជីវភាពកាន់តែប្រសើរឡើង និងមានការគិតគូរខ្ពស់ពីសុខភាពផ្ទាល់ខ្លួន

កត្តាសុខសន្តិភាព និងស្ថេរភាពនយោបាយ កំពុងធ្វើឱ្យប្រជាជនមានជីវភាពកាន់តែប្រសើរឡើង និងមានការគិតគូរខ្ពស់ពីសុខភាពផ្ទាល់ខ្លួន" នេះជាប្រសាសន៍ **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានថ្លែងក្នុងសុន្ទរកថាក្នុងពិធីសម្ពោធមន្ទីរពហុព្យាបាលអន្តរជាតិខេមា ផ្លូវ២០០៤ នាព្រឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២។

ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តមរដ្ឋមន្ត្រី** បានថ្លែងបន្ថែមទៀតថា កត្តាសុខសន្តិភាព និងស្ថេរភាពនយោបាយ បាននឹងកំពុងធ្វើឱ្យកម្ពុជាមានកំណើនសេដ្ឋកិច្ច និងជីវភាពប្រជាជនកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ហើយប្រជាជនផ្តើមយកចិត្តទុកដាក់ខ្ពស់លើបញ្ហាសុខភាពផ្ទាល់ខ្លួន។ ទន្ទឹងនឹងនេះ យើងជឿជាក់ថា មន្ទីរពហុព្យាបាលអន្តរជាតិខេមា នឹងចូលរួមជាមួយសង្គមជាតិក្នុងការផ្តល់សេវាកាន់តែល្អប្រសើរជូនប្រជាជនយើង ក៏ដូចជាការចូលរួមចំណែករឹកហាត់បណ្តុះបណ្តាលជូនដល់មន្ត្រីការអប់រំផ្សព្វផ្សាយអំពីសុខភាពសាធារណៈជូនប្រជាជន និងការចូលរួមបង្ការជម្ងឺផ្សេងៗនៅក្នុងសង្គមកម្ពុជា ដើម្បីភាពប្រសើរនៃសុខភាពសាធារណៈនៅកម្ពុជា៕

ឯកឧត្តម សាយ សំអាល់ ទទួលជួបពិភាក្សាការងារជាមួយនឹងប្រតិភូនៃមូលនិធិរូបិយវត្ថុអន្តរជាតិ

នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ នៅទីស្តីការក្រសួងបរិស្ថាន **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានទទួលជួបពិភាក្សាការងារជាមួយនឹងប្រតិភូនៃ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដឹកនាំដោយ Fabien Gonguet អំពីការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ គ្រោះធម្មជាតិ និងការគ្រប់គ្រងហិរញ្ញវត្ថុនៅកម្ពុជា។

ឯកឧត្តមរដ្ឋមន្ត្រី បានជម្រាបជូនប្រតិភូ IMF ថា សុខសន្តិភាព និងស្ថិរភាពនយោបាយពេញលេញ បានអនុញ្ញាតឱ្យកម្ពុជា សម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ជាប្រចាំ និងបានបង្កលក្ខណៈឱ្យមានការកើនឡើងខ្លាំងនូវភាគរយនៃប្រជាពលរដ្ឋមានជីវភាពកម្រិតកណ្តាល និងមានការអប់រំខ្ពស់ ដែលមានឥរិយាបទកាន់តែប្រសើរឡើងចំពោះបរិស្ថាន។ **ឯកឧត្តមរដ្ឋមន្ត្រី** បានគូសបញ្ជាក់នូវកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ជាពិសេសក្នុងកិច្ចការគ្រប់គ្រងគ្រោះមហន្តរាយ ការប្រែប្រួលអាកាសធាតុ ការចងក្រងទិន្នន័យ និងការគ្រប់គ្រងសំរាម សំណល់រឹង។

ឯកឧត្តមរដ្ឋមន្ត្រី បានបញ្ជាក់ថា ផ្អែកទៅលើការសិក្សាការប្រែប្រួលអាកាសធាតុ (Climate Change Projection) កម្ពុជាទទួលរងផលប៉ះពាល់ដែលរួមមានទឹកជំនន់ និងភាពរាំងស្ងួត ដែលទាមទាឱ្យគម្រោងវិនិយោគទាំងសាធារណៈ និងឯកជន គិតគូរអំពីបញ្ហានេះឱ្យបានហ្មត់ចត់។ បច្ចុប្បន្ន ក្រសួងបរិស្ថាន បាននិងកំពុងសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការសិក្សាអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ជាពិសេសទៅលើសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។

ប្រតិភូ IMF បានកោតសសើរ និងវាយតម្លៃខ្ពស់លើកិច្ច ខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងក្រសួងបរិស្ថាន ក្នុងកិច្ចការ គ្រប់គ្រង និងការចែករំលែកទិន្នន័យដ៏មានសារសំខាន់ ជាពិសេសគឺបញ្ចីគម្រោងសិក្សា ក្នុងការរៀបចំគោលនយោបាយបរិស្ថានជាតិ។ សូមបញ្ជាក់ថា ក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន១៤ បានរៀបចំផែនការស្តីពីការប្រែប្រួលអាកាសធាតុ ជាមួយគ្នានេះ ការប្រែប្រួលអាកាសធាតុ ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការថវិកាជាតិ៕

ក្រសួងបរិស្ថានរៀបចំសិក្ខាសាលាស្តីពី «ការពង្រឹងប្រសិទ្ធភាព និងលើកទិសដៅការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២ នៅទីស្តីការក្រសួងបរិស្ថាន បានរៀបចំសិក្ខាសាលាស្តីពី «ការពង្រឹងប្រសិទ្ធភាព និងលើកទិសដៅការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន» ក្រោមអធិបតីភាព **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួងបរិស្ថាន អគ្គនាយកដ្ឋានចំណុះក្រសួងបរិស្ថាន តំណាងអន្តរក្រសួងពាក់ព័ន្ធ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរបរិស្ថាន រាជធានី ខេត្ត សរុបប្រមាណ៣៦១នាក់។

សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងស្វែងយល់បន្ថែមអំពីបញ្ហាប្រឈមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរកដំណោះស្រាយសមស្របជាក់ស្តែងរបស់មូលដ្ឋាននីមួយៗ សំដៅធានាបានប្រសិទ្ធភាពនៃការអនុវត្តការងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនឱ្យបានល្អប្រសើរបន្ថែមទៀត ការចូលរួមលើកកម្ពស់នូវសុខុមាលភាព សោភ័ណភាព អនាម័យបរិស្ថាន ជូនដល់ប្រជាពលរដ្ឋ ក៏ដូចជាការចូលរួមអនុវត្តច្បាប់ គោលនយោបាយ ទស្សនវិស័យរបស់រាជរដ្ឋាភិបាល និងលិខិតបទដ្ឋានគតិយុត្តិដែលបានដាក់ចេញ។ អង្គសិក្ខាសាលាបានពិភាក្សាដោយផ្តោតសំខាន់លើ៖ ១)ទិសដៅ និងវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនសម្រាប់រយៈពេលខ្លី និងមធ្យម ២)ការគ្រប់គ្រងប្រតិបត្តិស្ថានីយផ្ទេរ និងទីលានទុកដាក់សំរាម សំណល់រឹង ៣)ដំណើរការនិងការអនុវត្តប្រព័ន្ធប្រតិបត្តិការ «ថ្នាលជាតិគ្រប់គ្រងសំរាម សំណល់រឹង» និងការប្រឡងប្រណាំងការអនុវត្តភូមិ ឃុំ សង្កាត់មានសុវត្ថិភាព៕

ឯកឧត្តម សាយ សំអាល់ កោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែង របស់ក្រសួងសុខាភិបាល

ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងសុខាភិបាល ដែលបានលះបង់កម្លាំងកាយ ចិត្ត និងប្រាជ្ញាស្មារតី ក្នុងបុព្វហេតុ លើកកម្ពស់ និងការពារសុខភាពសាធារណៈជូនរាជរដ្ឋាភិបាល និងប្រជាជន សម្រេចបាននូវសមិទ្ធផលជាច្រើនដូចជា ការកាត់បន្ថយអត្រាមរណៈរបស់មាតា និងទារកអំឡុងពេលសម្រាល អត្រាកាត់បន្ថយជំងឺឆ្លងគ្រប់ប្រភេទ យុទ្ធនាការស្រោចស្រពវ៉ាក់សាំងបង្ការ និងទប់ស្កាត់បានជំងឺកូវីដ-១៩ ជាពិសេសជោគជ័យក្នុងការទប់ស្កាត់ការប្រើប្រាស់ផលិតផលថ្នាំជក់។ ជាក់ស្តែងថ្ងៃនេះ ក្រសួងសុខាភិបាល បានផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រក្នុងការអប់រំ និងកាត់បន្ថយការប្រើប្រាស់ផលិតផលថ្នាំជក់ឆ្នាំ២០២១-២០២៦ ដល់មន្ត្រីរាជការនៃ ក្រសួងបរិស្ថាន។

ការកោតសរសើរ និងវាយតម្លៃខ្ពស់របស់ **ឯកឧត្តម** បានធ្វើឡើងក្នុងឱកាសអញ្ជើញជាអធិបតីក្នុងសិក្ខាសាលាផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រក្នុងការអប់រំ និងកាត់បន្ថយការប្រើប្រាស់ផលិតផលថ្នាំជក់ ឆ្នាំ២០២១-២០២៦ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ និងមានការចូលរួមពីឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងបរិស្ថាន និងក្រសួងសុខាភិបាល ជាច្រើនរូបទៀត។ សិក្ខាសាលានេះ ធ្វើឡើងក្នុងគោលបំណងធ្វើបច្ចុប្បន្នភាពនៃការអនុវត្តការងារអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់នៅកម្ពុជា និងបង្ហាញពីយុទ្ធសាស្ត្រ និងគោលដៅគន្លឹះនានាក្នុងការទប់ស្កាត់ការប្រើប្រាស់ផលិតផលថ្នាំជក់នៅកម្ពុជាដោយអនុវត្តតាមច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់របស់ព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះ **ឯកឧត្តម សាយ សំអាល់** បានលើក ឡើងថា ក្នុងនាមជាមន្ត្រីរាជការក្រសួងបរិស្ថាន ត្រូវតែពង្រឹងចំណេះដឹង និងសមត្ថភាពបន្ថែមទៀត ជាពិសេសជៀសឱ្យឆ្ងាយពីសារធាតុញៀនគ្រប់ប្រភេទ ដូចជា ផលិតផលថ្នាំជក់នេះ ដើម្បីអនាគតខ្លួនឯង និងសង្គមជាតិ ចូលរួមទាំងអស់គ្នាឱ្យវិស័យបរិស្ថានកាន់តែរីកចម្រើនលើការងាររដ្ឋបាលសាធារណៈ មុខងារសាធារណៈ កិច្ចគាំពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ ជីវៈចម្រុះ និងការតាក់តែងនូវគោលនយោបាយនានាក្នុងវិស័យបរិស្ថាន៕

ឯកឧត្តម សាយ សំអាល់ អនុញ្ញាតឱ្យតំណាង GGGI ប្រចាំកម្ពុជា ចូលជួបដើម្បីថ្លែងអំណរគុណនិងជម្រាបលា

នៅព្រឹកថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ នាទីស្តីការក្រសួងបរិស្ថាន **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានអនុញ្ញាតឱ្យលោកស្រី Karolien Casaer-Diez តំណាង GGGI ប្រចាំកម្ពុជា ចូលជួបដើម្បីថ្លែងអំណរគុណនិងជម្រាបលាក្រោយបានបញ្ចប់អាណត្តិការងាររយៈពេល៤ឆ្នាំនៅកម្ពុជា។ **ឯកឧត្តមរដ្ឋមន្ត្រី**បានវាយតម្លៃខ្ពស់ លើកិច្ចសហការនាពេលកន្លងមកលើវិស័យការរៀបចំក្រុង ទីប្រជុំជន ការគ្រប់គ្រងសំរាមសំណល់រឹង និងការអភិវឌ្ឍបៃតងនៅកម្ពុជា។ ទន្ទឹមនឹងនោះ **ឯកឧត្តមរដ្ឋមន្ត្រី**បានលើកឡើងពីការរីកចម្រើនជីវភាពរបស់ប្រជាជន និងភាពចាំបាច់នៅក្នុងការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ ការកំណត់ព្រំប្រទល់ឧទ្យានជាតិ ការចុះបញ្ជីដីតំបន់ ការពារធម្មជាតិនិងរបៀងអភិរក្សជីវៈចម្រុះ ការពង្រីកហេដ្ឋារចនាសម្ព័ន្ធគាំទ្រសម្រាប់ជំរុញមុខងារប្រតិបត្តិសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ **ឯកឧត្តមរដ្ឋមន្ត្រី** បានបន្តថា សម្រាប់កម្ពុជា អាទិភាពនៃការអភិវឌ្ឍរួមមាន៖ ការអភិវឌ្ឍធនធានមនុស្សប្រកបដោយវិជ្ជាជីវៈ ការជំរុញកម្លាំងពលកម្មដែលមានជំនាញច្បាស់លាស់ ការលើកកម្ពស់ប្រសិទ្ធភាពធនធាន និងលើកស្ទួយសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា នៅក្នុងតំបន់ និងសកល។

លោកស្រី Karolien Casaer-Diez បានថ្លែងអំណរគុណ **ឯកឧត្តមរដ្ឋមន្ត្រី** ថ្នាក់ដឹកនាំ ក្រុមការងារនិងមន្ត្រីក្រសួងបរិស្ថានទាំងអស់ បានចូលរួមសហការ និងការជំរុញការអភិវឌ្ឍបៃតងនៅកម្ពុជា ឱ្យសម្រេចបានសមិទ្ធផលសំខាន់ៗនាពេលកន្លងមក និងបានលើកឡើងពីការប្តេជ្ញាចិត្តរបស់ GGGI ក្នុងការបន្តគាំទ្រដើម្បីរួមចំណែកសម្រេចបានចក្ខុវិស័យរបស់ក្រសួងបរិស្ថាន។ គួរបញ្ជាក់ថា តំណាងថ្មីរបស់ GGGI ប្រចាំកម្ពុជា នឹងមកបំពេញការងារនៅកម្ពុជាបន្តពាក់កណ្តាលខែសីហា ឆ្នាំ២០២២៕



ឯកឧត្តម សាយ សំអាល់ ទទួលជួបឯកអគ្គរដ្ឋទូតថ្មីនៃសាធារណរដ្ឋបារាំង



ថ្ងៃទី២៨ខែមិថុនា ឆ្នាំ២០២២ **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានទទួលជួបឯកឧត្តម Jacques PELLET ឯកអគ្គរដ្ឋទូតថ្មីនៃសាធារណរដ្ឋបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា សម្តែងការគួរសម នៅទីស្តីការក្រសួងបរិស្ថាន។ នៅក្នុងជំនួបនេះ **ឯកឧត្តមរដ្ឋមន្ត្រី** បានជម្រាបជូនឯកឧត្តមឯកអគ្គរដ្ឋទូត អំពីអាទិភាពការងារមួយចំនួនរបស់ក្រសួងបរិស្ថាន ក្នុងនោះរួមមាន ការងារប្រែប្រួលអាកាសធាតុ ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹត្យកាបូននៅកម្ពុជា ការងារអភិរក្សជីវៈចម្រុះ ការសិក្សាស្រាវជ្រាវអំពីប្រភពថាមពលស្អាត ការងាររៀបចំទីក្រុង និងការអប់រំសិក្សាស្រាវជ្រាវ៕

ឯកឧត្តម សាយ សំអាល់ ជួបសម្តែងការគួរសម ដើម្បីចូលរួមអបអរសាទរ និងពិភាក្សាការងារទ្វេភាគីជាមួយ ប្រធានាធិបតីទី១៧ នៃសាធារណរដ្ឋហ្វីលីពីន

ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាបេសកជនពិសេសតំណាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានចូលជួបសម្តែងការគួរសម ដើម្បីចូលរួមអបអសាទរ និងពិភាក្សាការងារទ្វេភាគីជាមួយ **ឯកឧត្តមហ្វឺឌីណាន់ ម៉ាកូស ជេអរ** (Ferdinand Marcos Jr.) ប្រធានាធិបតីទី១៧ នៃសាធារណរដ្ឋហ្វីលីពីន ដែលបានប្រព្រឹត្តទៅនៅវិមានប្រធានាធិបតី នាថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២។

ភាគីទាំងពីរបានវាយតម្លៃខ្ពស់លើចំណងមិត្តភាពជាប្រពៃណី កិច្ចសហប្រតិបត្តិការ ការរីកចម្រើននៃជីវភាពរស់នៅរបស់ប្រជាជន និងការផ្លាស់ប្តូរចំណងមិត្តភាពនៃប្រជាជាតិទាំងពីរ។ ភាគីទាំងពីរក៏បានពិភាក្សាលើការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម សុវត្ថិភាពស្បៀង អាហារូបត្ថម្ភ សន្តិសុខថាមពល ពាណិជ្ជកម្ម និងកិច្ចខិតខំប្រឹងប្រែងរួមគ្នាលើការប្រយុទ្ធប្រឆាំងការប្រែប្រួលអាកាសធាតុដែលជាបញ្ហារួមរបស់តំបន់ និងពិភពលោក។

ក្នុងឱកាសនេះដែរ **ឯកឧត្តមបេសកជនពិសេស**ក៏បានពាំនាំការសាកសួរសុខទុក្ខ និងផ្តាំផ្ញើការជូនពរពី**សម្តេចតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**ជូនចំពោះ**ឯកឧត្តមប្រធានាធិបតី** ចំពោះការជាប់ឆ្នោតជាប្រធានាធិបតីទី១៧នៃសាធារណរដ្ឋហ្វីលីពីន ដែលទទួលបានការគាំទ្រពីប្រជាជនហ្វីលីពីនយ៉ាងច្រើនលើសលប់ ដោយសរបញ្ជាក់ឱ្យឃើញពីជំនឿទុកចិត្ត និងចក្ខុវិស័យនៃការដឹកនាំរបស់ឯកឧត្តមប្រធានាធិបតី។

ជាការឆ្លើយតប **ឯកឧត្តមប្រធានាធិបតី**ក៏បានផ្តាំផ្ញើការសាកសួរសុខទុក្ខជូនចំពោះ**សម្តេចតេជោនាយករដ្ឋមន្ត្រី** និងសូមអបអរសាទរចំពោះសមិទ្ធផលដែលសម្រេចបានក្រោមការដឹកនាំរបស់សម្តេច ហើយហ្វីលីពីនបានត្រៀមខ្លួនរួចជាស្រេចក្នុងការលើកយកកិច្ចការអាទិភាពមួយចំនួនដើម្បីពិភាក្សាជាមួយថ្នាក់ដឹកនាំអាស៊ាននៅក្នុងអំឡុងពេលដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ាននាពេលខាងមុខ៕

ផ្នែកទី ២
សកម្មភាពថ្នាក់ដឹកនាំ

ឯកឧត្តម ផៃ ប៊ុនឈឿន ចុះតាមបណ្ដាខេត្តមួយចំនួនដើម្បីលើកទឹកចិត្ត កោតសរសើរ និងថ្លែងអំណរគុណដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

ឯកឧត្តម ផៃ ប៊ុនឈឿន រដ្ឋលេខាធិការប្រចាំការក្រសួងបរិស្ថាន បានចុះតាមបណ្ដាខេត្តមួយចំនួនដើម្បីលើកទឹកចិត្ត កោតសរសើរ និងថ្លែងអំណរគុណដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអនុវត្តបានល្អប្រសើរ នូវសកម្មភាពសំខាន់ៗមួយចំនួនរួមមាន៖

ទី១-គោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព លក្ខណៈសម្បត្តិទី៦ «អនាម័យ សោភ័ណភាពល្អ បរិស្ថាន ដែលផ្ដោតលើ ការរៀបចំសេវាប្រមូល ការកំណត់ទីលានទុកដាក់ និងជំរុញការបង់ថ្លៃសេវាប្រមូលសំរាម សំណល់រឹងទីប្រជុំជន ដើម្បី«ការរស់នៅស្អាត ភូមិឋានស្អាត សុខភាពល្អ ជីវិតរីករាយ និងអនាគតរុងរឿង»។

ទី២-ការបង្កើនកិច្ចសហការរវាងក្រសួងបរិស្ថាន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការដោះស្រាយបញ្ហាដីធ្លីក្នុងតំបន់សហគមន៍ និងតំបន់ការពារធម្មជាតិ និងជំរុញការចុះបញ្ជីដីរដ្ឋ និងការបោះបង្គោលព្រំដីតាមតំបន់ការពារធម្មជាតិ ក៏ដូចពង្រឹងការទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសធនធានធម្មជាតិ ស្របតាមស្មារតីសារាចរណែនាំលេខ០៥ របស់រាជរដ្ឋាភិបាល។

ទី៣-ការលើកកម្ពស់ជីវភាពសហគមន៍ និងកសាងសេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការបង្កើតទេសចរណ៍ធម្មជាតិផ្សារភ្ជាប់ទឹកដីការធានាសន្តិសុខស្បៀងក្នុងគ្រួសារតាមរយៈកសិកម្មចម្រុះ ការបណ្ដុះបណ្ដាលជំនាញ និងបង្កើនការអប់រំដល់កូនចៅប្រជាសហគមន៍ ។ ឯកឧត្តមក៏បានផ្សព្វផ្សាយការងារប្រលងប្រណាំងអង្គភាពគំរូ បច្ចុប្បន្នភាពស្ថានភាពបរិស្ថានកម្ពុជា ដែលយើងសម្រេចបាន និងបញ្ហាប្រឈម ក៏ដូចជាការចែករំលែកនូវសិល្បៈនៃការដោះស្រាយបញ្ហាទាំងនោះផងដែរ៕

ឯកឧត្តម អ៊ិង សុផល្លែត៖ ប្រជាពលរដ្ឋប្រើប្រាស់ថង់បរិស្ថាន ដើម្បីកាត់បន្ថយប្លាស្ទិក ដែលបង្កហានិភ័យដល់សុខុមាលភាពមនុស្ស និងប៉ះពាល់បរិស្ថាន

ឯកឧត្តម អ៊ិង សុផល្លែត រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានស្រុកអូររាំងឪ ក្នុងយុទ្ធនាការ «កាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក និងផ្សព្វផ្សាយកន្ត្រកបរិស្ថាន» បានជំរុញឱ្យប្រជាពលរដ្ឋប្រើប្រាស់ថង់បរិស្ថាន ដើម្បីកាត់បន្ថយប្លាស្ទិក ដែលបង្កហានិភ័យដល់សុខភាពមនុស្ស ពិសេសប៉ះពាល់បរិស្ថានយ៉ាងធ្ងន់ធ្ងរនៅលើភពផែនដី។

ឯកឧត្តម រដ្ឋលេខាធិការក្រសួងបរិស្ថាន បានបន្ថែមថា ថង់ប្លាស្ទិកផលិតឡើងមានសារធាតុគីមីច្រើន ដែលបានបង្កផលប៉ះពាល់ដល់សុខុមាលភាពរបស់មនុស្សជាតិ នាំឱ្យកើតជម្ងឺជាច្រើនប្រភេទ ក្នុងនោះក៏មានជម្ងឺមហារីកផងដែរ មិនតែប៉ុណ្ណោះអនាម័យបរិស្ថាន និងសោភណ្ឌភាពក៏ត្រូវបានបំផ្លាញដោយសំណល់ប្លាស្ទិក ដែលកើតឡើងនៅតាមទីសាធារណៈ ទីក្រុង ទីប្រជុំជន រហូតដល់ភូមិឋាន និងតំបន់បេតិកភណ្ឌធម្មជាតិនិងប្រវត្តិសាស្ត្រ រួមសមុទ្រផងដែរ។

ឯកឧត្តម បានបញ្ជាក់ដែរថា យុទ្ធនាការកាត់បន្ថយថង់ប្លាស្ទិក នាពេលនេះ គឺបានឆ្លុះបញ្ចាំងពីឆន្ទៈរួមគ្នាដើម្បីកិច្ចគាំពារបរិស្ថាន និងបង្ហាញពីការយកចិត្តទុកដាក់របស់កម្ពុជា រួមជាមួយប្រជាជាតិលើសកលលោក ដើម្បីបុព្វហេតុរួមចំណែកការពារនិងថែរក្សាគុណភាពបរិស្ថានភពផែនដី ឱ្យឈានឆ្ពោះទៅកាន់ការរស់នៅប្រកបដោយចីរភាព សម្រាប់មនុស្សជាតិបច្ចុប្បន្ន និងមនុស្សជំនាន់ក្រោយៗទៀត និងការពារសោភណ្ឌភាពមូលដ្ឋាន និងតំបន់បេតិកភណ្ឌរបស់យើងទាំងអស់គ្នា។ ឯកឧត្តម បានសំណូមពរដល់ប្រជាពលរដ្ឋគួរប្រែក្លាយទម្លាប់ងាកមកប្រើប្រាស់ថង់ ឬកន្ត្រកបរិស្ថាន ដែលជួយសន្សំសំចៃថវិកានិងងាយស្រួលទុកដាក់ថែមទៀតផង។

សូមបញ្ជាក់ថា យុទ្ធនាការ «កាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក និងផ្សព្វផ្សាយកន្ត្រកបរិស្ថាន» ប្រព្រឹត្តទៅនៅផ្សារអូររាំងឪ ក្នុងស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃសុក្រ ទី១១ ខែកុម្ភៈ ឆ្នាំ២០២២ ក្រោមអធិបតីភាព **ឯកឧត្តម អ៊ិង សុផល្លែត** រដ្ឋលេខាធិការក្រសួងបរិស្ថាន និងមានការចូលរួមពី ឯកឧត្តមបណ្ឌិត ជាម ច័ន្ទសោភ័ណ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ ឯកឧត្តម លោក លោកស្រីថ្នាក់ដឹកនាំក្រសួងបរិស្ថាន លោក លោកស្រីថ្នាក់ដឹកនាំរដ្ឋបាលខេត្តត្បូងឃ្មុំ អាជ្ញាធរស្រុកអូររាំងឪ

យុវជន សសយក សិស្សានុសិស្ស ប្រជាពលរដ្ឋ និងអាជីវករផ្សារអូររាំងឪមួយចំនួនទៀត។

យុទ្ធនាការនេះរៀបចំឡើងក្នុងគោលបំណង ៖

១)ផ្សព្វផ្សាយជាផ្លូវការនូវចលនាទូលំទូលាយរួមគ្នាកាត់បន្ថយសំណល់ប្លាស្ទិកនៅកម្ពុជា តាមគោលការណ៍ស្ម័គ្រចិត្តស្របតាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ស្ដីពី ការគ្រប់គ្រងថង់ប្លាស្ទិក

២)ជំរុញ និងលើកទឹកចិត្តដល់អាជីវករឱ្យបញ្ឈប់ជាអចិន្ត្រៃយ៍នូវការផ្ដល់ថង់ប្លាស្ទិកដោយមិនគិតថ្លៃដល់អតិថិជន

និង៣)ចូលរួមចំណែកលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមសហគមន៍ តាមរយៈការផលិតកន្ត្រកដែលធ្វើពីចចូតជាផលិតផលក្នុងស្រុក។

តាមរយៈយុទ្ធនាការនេះ គណៈអធិបតី បានប្រគល់នូវកន្ត្រកបរិស្ថានជូនអ្នកចូលរួម និងបានអញ្ជើញសំនេះសំណាលផ្សព្វផ្សាយការប្រើប្រាស់កន្ត្រកបរិស្ថានជាមួយប្រជាពលរដ្ឋ និងអាជីវករក្នុងផ្សារអូររាំឪ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ដើម្បីជំរុញការឈប់ប្រើប្រាស់ប្លាស្ទិកក្នុងជីវភាពប្រចាំថ្ងៃ៕

ក្រសួងបរិស្ថានសហការជាមួយរដ្ឋបាលខេត្តកំពង់ឆ្នាំង បន្តដាំស្តារឡើងវិញព្រៃលិចទឹកក្នុង តំបន់៣ នៃបឹងទន្លេសាប

ដើមឈើចម្រុះចំនួន២៤០០០ដើម ត្រូវបានក្រសួងបរិស្ថាន សហការជាមួយរដ្ឋបាលខេត្តកំពង់ឆ្នាំង បានដាំស្តារឡើងវិញ នៅព្រៃលិចទឹកក្នុងតំបន់៣ នៃតំបន់បឹងទន្លេសាប ស្ថិតក្នុងភូមិថ្នល់ឈើទាល ឃុំផ្លូវទូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ក្រោមអធិបតីភាព **ឯកឧត្តម សូ ខនឫទ្ធីគុណា** រដ្ឋលេខាធិការតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន អមដំណើរដោយថ្នាក់ដឹកនាំក្រសួង តំណាងគណៈអភិបាលខេត្តកំពង់ឆ្នាំង មន្ទីរពាក់ព័ន្ធ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ និងសិស្សានុសិស្សជាច្រើននាក់ នាព្រឹកថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២។

លោកជំទាវ ប៊ិន សុភី អភិបាលរងខេត្តកំពង់ឆ្នាំង បានឱ្យដឹងថា នេះជាលើកទី២ហើយដែលរៀបចំការដាំស្តារឡើងវិញ នៅព្រៃលិចទឹកក្នុងតំបន់៣ នៃតំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងទន្លេសាប បានចំនួន២៣២៤៤ដើម ក្នុងនោះមានដើមរាំង១០០០ដើម ម្តេញ៧០០០ដើម ឫស្សីផ្អែម៧៤០០ដើម ពីងពុង១៧៣៥ដើម ត្នោត៩ដើម គ្រាប់ត្នោតដាំតាមព្រំតំបន់បីបានចំនួន២៣៨៩៤គ្រាប់ ដែលមានប្រវែង១១៤,១៣គីឡូម៉ែត្រ។

ក្នុងឱកាសនោះ **ឯកឧត្តម សូ ខនឫទ្ធីគុណា** បានលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ក្នុងការទប់ស្កាត់ការទន្ទ្រានឈូសឆាយដីព្រៃលិចទឹក និងបានដកហូតយកមកវិញជាមួយអាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធ ពីជនខិលខូច។ ជាក់ស្តែងនៅថ្ងៃនេះក្រសួងបរិស្ថាន បានធ្វើការដាំស្តារដើមឈើចម្រុះឡើងវិញ ជាប្រយោជន៍ សម្រាប់បំផុសស្មារតីប្រជាពលរដ្ឋយើងឱ្យចេះស្រឡាញ់ព្រៃឈើ និងចូលរួមដាំដើមឈើឡើងវិញ និងចូលរួមទប់ស្កាត់ការប្រែប្រួលអាកាសធាតុ។

ឯកឧត្តមរដ្ឋលេខាធិការ បានចាត់ទុកថា ពិធីដាំកូនឈើនាពេលនេះ និងការចូលរួមយ៉ាងច្រើនកុះករពីសំណាក់គ្រប់មជ្ឈដ្ឋានពាក់ព័ន្ធ បាននឹងកំពុងឆ្លុះបញ្ចាំងនូវការភ្ញាក់រលឹករបស់សហគមន៍យើងទាំងមូល ក្នុងការប្រឈមមុខដោះស្រាយចំពោះការបាត់បង់ព្រៃឈើ និងជាស្មារតីម្ចាស់ការក្នុងការទទួលខុសត្រូវ លើការគ្រប់គ្រងធនធានធម្មជាតិ អនាគតភូមិ ឃុំ និងជាជោគវាសនានៃមាតុភូមិយើង ជាពិសេសទុកសម្រាប់កូនចៅជំនាន់ក្រោយ និងដើម្បី

ឱ្យមានភាពបៃតង និងរក្សាបាននូវប្រភពទឹកក្រោមដីថែមទៀតផង ។

សូមបញ្ជាក់ថា ព្រៃលិចទឹកក្នុងតំបន់៣ នៃតំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងទន្លេសាប ស្ថិតក្នុងភូមិថ្នល់ឈើទាល ឃុំផ្លូវទូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ដែលត្រូវដាំស្តារឡើងវិញទាំង២លើក គឺលើកទី១នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២ បានចំនួន២០ហិកតា ស្មើនឹង៨០០០ដើម រួមមាន ៖ ឫស្សី រាំងទឹក ម្តេញ និងសណ្តាន់ ។ លើកទី២លើផ្ទៃដី៦០ហិកតា ចំនួន២៤០០០ដើម រួមមាន ៖ រាំងទឹក ចំនួន១៣៥០០ដើម សណ្តាន់ចំនួន៤៥០០ដើម ម្តេញ៣៥០០ដើម និងឫស្សីស្រុកចំនួន២៥០០ដើម៕

ឯកឧត្តម រ័ត្ន ថិរៈ អញ្ជើញជួបសំណេះសំណាល និងចែករំលែកបទពិសោធន៍ដល់សិស្សានុសិស្ស អនុវិទ្យាល័យដូងប្រេងតានៃ

ឯកឧត្តម រ័ត្ន ថិរៈ រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាអនុប្រធានគណៈអចិន្ត្រៃយ៍ក្រុមការងារចុះមូលដ្ឋានស្រុកព្រៃនប់ បានអញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាល ចែករំលែកបទពិសោធន៍ដល់សិស្សានុសិស្ស និងចែកវត្ថុអនុស្សាវរីយ៍ ដែលបានមកពីក្រុមសមាគមធុរកិច្ចអេឡិចត្រូនិកកម្ពុជា និងអង្គការការីតាសកម្ពុជា ជូនដល់សិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូ នៅអនុវិទ្យាល័យដូងប្រេងតានៃ ស្ថិតនៅភូមិតានៃ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃសប្តាហ៍កន្លងទៅនេះ។

ក្នុងឱកាសនោះ **ឯកឧត្តមរដ្ឋលេខាធិការ** បាននាំនូវការសាកសួរសុខទុក្ខពីសំណាក់**ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ជូនចំពោះលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់ផងដែរ។ **ឯកឧត្តម**ក៏បានលើកទឹកចិត្ត និងអរគុណដល់ការលះបង់ទាំងកម្លាំងកាយ កម្លាំងចិត្តរបស់លោកគ្រូ អ្នកគ្រូ ដែលបានខិតខំប្រឹងប្រែងបង្ហាត់បង្រៀនដល់សិស្សានុសិស្ស ដែលជាទំពាំងស្នងឫស្សី និងជាធនធានបន្តវេនសម្រាប់ប្រទេសជាតិនាពេលអនាគត។

បន្ថែមពីនេះ **ឯកឧត្តម រ័ត្ន ថិរៈ** បានថ្លែងអំណរគុណដល់ឯកឧត្តម តាន់ មុន្នីវណ្ណ ប្រធានសមាគមធុរកិច្ចអេឡិចត្រូនិកកម្ពុជា និងក្រុមការងារដែលបានផ្តួចផ្តើមកម្មវិធីនេះឡើង ដើម្បីផ្តល់ឱកាសក្នុងការសិក្សាស្វែងយល់ និងចែករំលែកបទពិសោធន៍ល្អៗជូនដល់សិស្សានុសិស្ស ក្នុងការតម្រង់ទិសពួកគេឱ្យក្លាយជាធនធានមនុស្សប្រកបដោយប្រសិទ្ធភាព។

ជាមួយគ្នានេះ **ឯកឧត្តម រ័ត្ន ថិរៈ** និងក្រុមសមាគមធុរកិច្ចអេឡិចត្រូនិក បានចែកជូនវត្ថុអនុស្សាវរីយ៍ជូនដល់សិស្សានុសិស្ស លោកគ្រូអ្នកគ្រូ លោកមេឃុំ និងអញ្ជើញដាំកូនឈើប្រណិតចំនួន ១០០ដើម ដែលជាអំណោយរបស់ក្រសួងបរិស្ថាន នៅក្នុងអនុវិទ្យាល័យផងដែរ។

គួរបញ្ជាក់ឱ្យដឹងថា ក្នុងពិធីសំណេះសំណាលនេះ ក៏មានការអញ្ជើញចូលរួមពីឯកឧត្តមឧកញ៉ាបណ្ឌិត តាន់ មុន្នីវណ្ណ ប្រធានសមាគមធុរកិច្ចអេឡិចត្រូនិកកម្ពុជា លោក មុំ វ៉ារិន អនុប្រធានសមាគមធុរកិច្ចអេឡិចត្រូនិកកម្ពុជា និងលោក គឹម រតនា នាយកប្រតិបត្តិអង្គការការីតាសកម្ពុជា ព្រមទាំង ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសមាជិកក្រុមសមាគមធុរកិច្ចអេឡិចត្រូនិកកម្ពុជា ក្រុមការងារចុះមូលដ្ឋានស្រុកព្រៃនប់ អាជ្ញាធរមូលដ្ឋាន លោកគ្រូអ្នកគ្រូ កងកម្លាំងប្រដាប់អាវុធ អាណាព្យាបាល និងសិស្សានុសិស្សជាច្រើនរូបទៀត៕

ឯកឧត្តម សៅ សុភាព និងឯកឧត្តម ជា សំអាង ដឹកនាំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និង ផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ



នៅទីស្តីការក្រសួងបរិស្ថាន នៅរសៀលថ្ងៃព្រហស្បតិ៍ ៩កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ **ឯកឧត្តម សៅ សុភាព** រដ្ឋលេខាធិការ និង **ឯកឧត្តម ជា សំអាង** រដ្ឋលេខាធិការនៃក្រសួងបរិស្ថាន ជាសហប្រធានអង្គប្រជុំ បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ពេញលេញ (ESIA) សម្រាប់គម្រោងសាងសង់ប្រព័ន្ធខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រ ហុងកុង-ព្រះសីហនុ និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ ដែលឆ្លងកាត់ដែនសមុទ្រកម្ពុជាមានប្រវែង ៣២៣,៥គីឡូម៉ែត្រ រួមទាំងស្ថានីយខ្សែកាប្លិ៍អុបទិក ស្ថិតនៅក្នុងភូមិសាស្ត្រភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ របស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ (ម្ចាស់គម្រោង) និងការរចនាគម្រោង និងសាងសង់ដោយក្រុមហ៊ុន CRCC Harbour & Channel Engineering Bureau Group Co., Ltd. ព្រមទាំងសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ (ESIA) ដោយក្រុមហ៊ុនទីប្រឹក្សា Creative Green Research Co., Ltd.។

លទ្ធផលនៃកិច្ចប្រជុំនេះរួមមាន៖ ១).អង្គប្រជុំសូមគាំទ្រគម្រោងសាងសង់ប្រព័ន្ធខ្សែកាប្លិ៍អុបទិកនេះ ២).ក្រុមហ៊ុនត្រូវធ្វើការកាត់បន្ថយការសាយភាយកករល្អក់នៅពេលជីកកប់ខ្សែកាប្លិ៍អុបទិកនេះ កាត់បន្ថយផលប៉ះពាល់ដល់ជីវៈចម្រុះសមុទ្រ ៣).ក្រុមហ៊ុនត្រូវមានផែនការគ្រប់គ្រងសំណល់រឹង និងសំណល់រាវ ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ៤). ក្រុមហ៊ុនត្រូវសិក្សាឱ្យបានច្បាស់លាស់ទាក់ទងនឹងផ្កាថ្មនៅតំបន់គម្រោង ក្នុងករណីពេលជីកកប់ខ្សែកាប្លិ៍អុបទិកប៉ះពាល់ផ្កាថ្ម ក្រុមហ៊ុនត្រូវផ្អាកសកម្មភាពសាងសង់ ហើយធ្វើការបញ្ចៀស ដើម្បីកាត់បន្ថយការប៉ះពាល់ផ្កាថ្មទាំងអស់នេះ និង ៥).ស្នើឱ្យក្រុមហ៊ុនម្ចាស់គម្រោងសហការជាមួយក្រុមហ៊ុនទីប្រឹក្សាបញ្ចូលនូវមតិយោបល់វិជ្ជមានរបស់អង្គប្រជុំទៅក្នុងរបាយការណ៍ ESIA ឱ្យបានត្រឹមត្រូវ។

សូមបញ្ជាក់ថា កិច្ចប្រជុំនេះបានប្រព្រឹត្តទៅដោយមានការចូលរួមពីឯកឧត្តមអនុរដ្ឋលេខាធិការ តំណាងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួង

សាធារណការ និងដឹកជញ្ជូន ក្រសួងទេសចរណ៍ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងរ៉ែ និងថាមពល ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការនៃគណៈកម្មាធិការជាតិសន្តិសុខលំហសមុទ្រ កំពង់ផែស្វយ័តក្រុងព្រះសីហនុ រដ្ឋបាលខេត្តព្រះសីហនុ មន្ទីរបរិស្ថានខេត្តព្រះសីហនុ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ម្ចាស់គម្រោងក្រុមហ៊ុនសាងសង់ និងក្រុមហ៊ុនទីប្រឹក្សាផងដែរ៕



ឯកឧត្តម ស្រ៊ុន ដារិទ្ធិ អញ្ជើញសម្ពោធអគារមជ្ឈមណ្ឌលគ្រប់គ្រងតំបន់រ៉ាមសារព្រែកទាល់

នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ **ឯកឧត្តម ស្រ៊ុន ដារិទ្ធិ** រដ្ឋលេខាធិការ បានអញ្ជើញសម្ពោធអគារមជ្ឈមណ្ឌលគ្រប់គ្រងតំបន់រ៉ាមសារព្រែកទាល់ដោយមានការចូលរួមពីឯកឧត្តមChristian Berger ឯកអគ្គរដ្ឋទូតសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ប្រចាំកម្ពុជា តំណាងអគ្គនាយកដ្ឋានចំណុះក្រសួងបរិស្ថាន តំណាងនាយកដ្ឋានចំណុះអគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ រដ្ឋបាលជលផល មន្ទីរបរិស្ថានខេត្តបាត់ដំបង មន្ទីរបរិស្ថានខេត្តសៀមរាប អាជ្ញាធរមូលដ្ឋាន អង្គការដៃគូពាក់ព័ន្ធ ឧទ្យានុរក្សតំបន់រ៉ាមសារ ព្រែកទាល់ និងប្រជាសហគមន៍ជាច្រើនរូបទៀត។ អគារមជ្ឈមណ្ឌលគ្រប់គ្រងតំបន់រ៉ាមសារព្រែកទាល់ត្រូវបានជួសជុលឡើងវិញ ដោយមានការគាំទ្រមូលនិធិពីក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍អាល្លឺម៉ង់(BMZ) តាមរយៈធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់(KfW) ក្រោមគម្រោងគ្រប់គ្រង និងអភិរក្សតំបន់ដីសើមអាងទន្លេមេគង្គក្រោមដែលបាននិងកំពុងអនុវត្តដោយ អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ។

ឆ្លៀតឱកាសនេះ គណៈប្រតិភូ និងឯកឧត្តមអគ្គរដ្ឋទូតសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ប្រចាំកម្ពុជា បានចុះទៅទស្សនាបន្ទាយសត្វស្លាបទឹកដ៏ធំជាងគេនៅអាស៊ីអាគ្នេយ៍ នៅតំបន់រ៉ាមសារព្រែកទាល់ផងដែរ។ ឯកឧត្តមអគ្គរដ្ឋទូតសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ប្រចាំកម្ពុជា បានកោតសរសើរចំពោះការងារអភិរក្សនៅតំបន់រ៉ាមសារព្រែកទាល់ ដោយលោកផ្ទាល់បានមកទស្សនាតំបន់នេះចំនួន ៥ ដងហើយ។ លោកសង្ឃឹមថា ជីវៈចម្រុះ និងធនធានធម្មជាតិក្នុងតំបន់រ៉ាមសារព្រែកទាល់ ជាពិសេសចំនួនសត្វស្លាបទឹកនឹងបន្តកើនឡើង តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងបរិស្ថាន និងអាជ្ញាធរថ្នាក់ក្រោមជាតិ៕

ក្រសួងបរិស្ថានគាំទ្រឲ្យមានការវិនិយោគលើការអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹង ធម្មជាតិខ្នាតតូច នៅក្នុងតំបន់ការពារធម្មជាតិ

នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២ **លោកជំទាវ ម៉ុម ថានី** រដ្ឋលេខាធិការក្រសួងបរិស្ថាន អញ្ជើញបើកសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីប្រកាសព្រាងគោលការណ៍ណែនាំស្តីពីការអនុវត្តគម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូចនៅក្នុងតំបន់ការពារធម្មជាតិនិងរបៀងអភិរក្សជីវៈចម្រុះ ព្រមទាំងវត្តមាន ឯកឧត្តម អស់លោក លោកស្រី តំណាងក្រុមហ៊ុនមកពីវិស័យឯកជនជាច្រើនរូបចូលរួមសរុបចំនួន៥៣នាក់ ។

ឯកឧត្តម ខៀវ ប៊ូរិន អគ្គនាយកនៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន និងជានាយកនៃគម្រោងនិរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា(CSLEP) បានថ្លែងនៅក្នុងអង្គសិក្ខាសាលាថាការរៀបចំនូវព្រឹត្តិការណ៍នេះមានគោលបំណងដើម្បីប្រមូលនូវធាតុចូលបន្ថែមពីគ្រប់ភាគីពាក់ព័ន្ធដើម្បីពិនិត្យមើលលើខ្លឹមសារនៃសេចក្តីព្រាងប្រកាស ក្នុងការរៀបចំអភិវឌ្ឍន៍តំបន់ការពារធម្មជាតិ ដែលអាចជួយទាំងកំណើនសេដ្ឋកិច្ចសង្គម សេដ្ឋកិច្ចគ្រួសារ និងពិសេសជួយលើកកម្ពស់ដល់ជីវភាពសហគមន៍មូលដ្ឋានផងដែរ។

ឯកឧត្តម បានបញ្ជាក់បន្ថែមថា ខ្លឹមសារនៃសេចក្តីព្រាងប្រកាសនេះ គឺមានគោលបំណងណែនាំ ដោយបង្កឱ្យមានលក្ខណៈងាយស្រួល និងសម្របសម្រួលដល់ម្ចាស់សំណើ និងម្ចាស់គម្រោងអំពីនីតិវិធី និងដំណើរការអនុវត្តគម្រោងអភិវឌ្ឍន៍ ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូចក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវចម្រុះ និងកំណត់ វិសាលភាពនៃការអនុវត្តលើគម្រោងដែលមានទំហំដីមិនលើសពី ១០ (ដប់) ហិកតា ដោយប្រើប្រាស់លក្ខណៈ វិនិច្ឆ័យជាឧបករណ៍ក្នុងការវាយតម្លៃលើគ្រប់ទិដ្ឋភាពពាក់ព័ន្ធ។

លោកជំទាវ ម៉ុម ថានី រដ្ឋលេខាធិការ ក្រសួងបរិស្ថានបានមានប្រសាសន៍ដែរថាសិក្ខាសាលាពិគ្រោះយោបល់នឹងផ្តល់ឱកាសសម្រាប់អ្នកវិនិយោគទុនទាំងក្នុង និងក្រៅប្រទេស ដែលមានចំណាប់អារម្មណ៍ មានបទពិសោធន៍ ជំនាញ និងដើមទុនគ្រប់គ្រាន់អាចដាក់ពាក្យស្នើសុំចូលរួមក្នុងការអភិវឌ្ឍទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិឱ្យមាននិរន្តរភាព និងប្រកបដោយទំនួលខុសត្រូវខ្ពស់។ លោកជំទាវបានបញ្ជាក់បន្ថែមថា ព័ត៌មាន និងធាតុចូលទាំងឡាយដែលប្រមូលបានពីសិក្ខាសាលាពិគ្រោះយោបល់នេះនឹងចូលរួមដល់ការកែលំអ ក៏ដូចជាការបញ្ចប់នូវការរៀបចំខ្លឹមសារនៃសេចក្តីព្រាង

ប្រកាសគោលការណ៍ណែនាំ សំដៅជានាបាននូវការឆ្លើយតបទៅនឹងតម្រូវការ និងចំណាប់អារម្មណ៍នានា និងសម្របសម្រួលដល់ការវិនិយោគប្រកបដោយនិរន្តរភាពលើគម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូចនៅក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ។

គូសបញ្ជាក់ថាសិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណងដើម្បីប្រមូលគំនិតនិងការចូលរួមផ្តល់មតិយោបល់បន្ថែមឱ្យបានកាន់តែទូលំទូលាយពីគ្រប់ភាគីពាក់ព័ន្ធជាពិសេសពីក្រុមហ៊ុនដែលបានដាក់គម្រោងស្នើសុំរួចរាល់ ក្រុមហ៊ុនដែលទទួលបានការអនុញ្ញាត ពីក្រសួងបរិស្ថានឱ្យធ្វើការអភិវឌ្ឍទេសចរណ៍ធម្មជាតិ ក៏ដូចជានីតិបុគ្គល និងរូបវន្តបុគ្គលដែលបានបង្ហាញចំណាប់អារម្មណ៍ផ្ទាល់ខ្លួន និងដែលអាចមានចំណាប់អារម្មណ៍ទៅថ្ងៃអនាគត ពាក់ព័ន្ធនឹងការអនុវត្តគម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូចក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ៕

យុទ្ធនាការអន្ទាក់សូន្យនៅក្នុងតំបន់ការពារធម្មជាតិកម្ពុជា

«យុទ្ធនាការអន្ទាក់សូន្យនៅក្នុងតំបន់ការពារធម្មជាតិកម្ពុជា» ផ្តួចផ្តើមនិងដឹកនាំរៀបចំដោយក្រសួងបរិស្ថានដោយមានការចូលរួមរបស់អង្គការអន្តរជាតិដៃគូក្នុងកិច្ចការអភិរក្សធនធានធម្មជាតិនឹងចាប់ផ្តើមជាផ្លូវការនៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២២ សម្រាប់រយៈពេល៦ខែ នៅក្នុងបណ្តាខេត្តរួមមាន ខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ព្រះវិហារ និងខេត្តកំពង់ធំ។ នេះគឺជាការប្រកាសឱ្យដឹងរបស់**ឯកឧត្តម នេត្រ ភក្ត្រា** រដ្ឋលេខាធិការក្រសួងបរិស្ថាន នៅក្នុងសន្និសីទសារព័ត៌មានមួយនៅរសៀលថ្ងៃទី២ ខែមីនា ឆ្នាំ២០២២ នេះនៅទីស្តីការក្រសួងបរិស្ថាន ដែលមានការចូលរួមពីតំណាងអង្គការដៃគូរួមមានអង្គការមូលនិធិសកលសម្រាប់អភិរក្សធនធានធម្មជាតិ (WWF) សមាគមអភិរក្សសត្វព្រៃកម្ពុជា (WCS) អង្គការជីវិតសត្វស្លាបអន្តរជាតិ (Birdlife International) អង្គការអភិរក្សអន្តរជាតិ (CI) គម្រោងព្រៃឡង់បៃតងរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍ អន្តរជាតិ (USAID Green Prey Lang) និងអង្គការ FFI។

ឯកឧត្តមរដ្ឋលេខាធិការ បានថ្លែងថា ការបើកយុទ្ធនាការអន្ទាក់សូន្យនៅថ្ងៃទី៣ ខែមីនាស្របពេលដែលពិភពលោកប្រារព្ធទិវាសត្វព្រៃពិភពលោកផងដែរ និងមានគោលបំណងសំខាន់រួមមាន ការផ្សព្វផ្សាយអប់រំអំពីផលប៉ះពាល់ដោយសារអន្ទាក់ទៅលើជីវិត សត្វ និងជីវិតមនុស្ស ពង្រឹងការអនុវត្តច្បាប់ ការផ្លាស់ប្តូរឥរិយាបថពលរដ្ឋឱ្យបង្កើនការប្រតិបត្តិមេត្រីបរិស្ថាន ស្រឡាញ់សត្វព្រៃ ជីវៈចម្រុះ និងការលុបបំបាត់ការបរបាញ់សត្វ ការដាក់អន្ទាក់ខុសច្បាប់ និងការលុបបំបាត់ការជួញដូរសាច់សត្វព្រៃ ក៏ដូចជាបង្កើនសុវត្ថិភាពដល់សត្វព្រៃគ្រប់ប្រភេទ។

ឯកឧត្តមរដ្ឋលេខាធិការ នេត្រ ភក្ត្រា បានថ្លែងថា ស្ថានភាពនៃ ការការពារនិងអភិរក្សធនធានធម្មជាតិដែលជាទីជម្រករបស់សត្វព្រៃនៅកម្ពុជាមានភាពល្អប្រសើរ ដែលបានផ្តល់ជាជម្រកសម្រាប់សត្វព្រៃ និងជាប្រភពទឹក និងចំណីរបស់សត្វព្រៃ តែអ្វីដែលយើងត្រូវគិតគូរបន្ថែមទៀតគឺធ្វើឱ្យតំបន់ការពារធម្មជាតិ កាន់តែមានសុវត្ថិភាពសម្រាប់សត្វព្រៃនិងជីវៈចម្រុះផ្សេងទៀត។ **ឯកឧត្តម** បានថ្លែងថា អន្ទាក់គឺកត្តាដែលគំរាមកំហែងខ្លាំងចំពោះសត្វព្រៃ។ **ឯកឧត្តម នេត្រ ភក្ត្រា** បានលើកឡើងថា បរិមាណអន្ទាក់ដែលបានដោះនៅឆ្នាំ២០២១ មានចំនួន ៦១៦១១ អន្ទាក់ កើនឡើងប្រមាណជាង២០% បើប្រៀបធៀបនឹងបរិមាណអន្ទាក់ដោះបាននៅ

ឆ្នាំ២០២០ ដែលមានចំនួន ៤៣ ២៧០ អន្ទាក់។ ឯកឧត្តមបានថ្លែងថា អន្ទាក់ដែលត្រូវបានដោះចេញ អន្ទាក់ជាឃាតកលាក់មុខដែលបន្តសម្លាប់សត្វព្រៃនៅក្នុងតំបន់ការពារធម្មជាតិនៅកម្ពុជា ព្រោះមានប្រភេទអន្ទាក់ចក់ខ្សែភ្លើង អន្ទាក់វាយបំបាក់ស្មងជើង និងប្រភេទគ្រោះថ្នាក់ផ្សេងៗទៀត។ **ឯកឧត្តម នេត្រ ភក្ត្រា** បានថ្លែងថា យុទ្ធនាការ អន្ទាក់សូន្យនឹងជាផ្នែកមួយនៃការជួយបញ្ជ្រាបការយល់ដឹងរបស់ប្រជាពលរដ្ឋ និងចូលរួមកាត់បន្ថយចំនួនអន្ទាក់នៅក្នុងតំបន់ការពារធម្មជាតិ។

ថ្លែងក្នុងសន្និសីទសារព័ត៌មាន ឯកឧត្តម គឹម ណុង អគ្គនាយកនៃអគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ នៃក្រសួងបរិស្ថានបានថ្លែងថា ក្នុងយុទ្ធនាការនេះសំដៅធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋតាមមូលដ្ឋានដែលមានទម្លាប់ដាក់អន្ទាក់ចាប់សត្វព្រៃឱ្យងាកមក គោរពច្បាប់ និងឱ្យពួកគាត់យល់ពីតម្លៃសត្វព្រៃ ហើយរួមគ្នាមក ចូលរួមអភិរក្សសត្វព្រៃដែលជាសត្វមានតម្លៃមហាសាលមិនអាចកាត់ថ្លៃបានជាសាកល។ ឯកឧត្តមបានថ្លែងថា កម្ពុជាមានច្បាប់សម្រាប់ដាក់ទោសពិន័យហើយនិងសម្រាប់បទល្មើសដាក់អន្ទាក់គឺជាច្បាប់ល្មើសធនធានធម្មជាតិថ្នាក់លេខ៣ដែលក្នុងនេះមានទាំងការផាកពិន័យ និងទោសទណ្ឌ ដោយក្នុងនេះអាចប្រឈមនឹងជាប់ពន្ធនាគារពី១-៥ឆ្នាំ និងពិន័យជាប្រាក់ពី១៥លានដល់១៥០លានរៀល។ ឯកឧត្តមមានប្រសាសន៍ថា ក្នុងយុទ្ធនាការនេះគឺយើងនឹងរួមគ្នាធ្វើឡើងរយៈពេល៦ខែ ហើយក្នុងអំឡុងពេលនេះយើងនឹងឱ្យអាជ្ញាធរមូលដ្ឋាននិងសហគមន៍រួមគ្នាទប់ស្កាត់ក៏ដូចជាអប់រំផ្សព្វផ្សាយឱ្យពួកគាត់យល់ច្បាស់ពីច្បាប់ ពីទោសទណ្ឌនិងរួមទាំងតម្លៃរបស់សត្វព្រៃ។

ជាមួយគ្នានេះ លោក សេង ទៀក ប្រធានអង្គការ WWF បានឱ្យដឹងថា បច្ចុប្បន្នអន្ទាក់ដែលត្រូវបានគេដោះនៅតាមតំបន់ការពារធម្មជាតិបានត្រឹមតែ២០ភាគរយប៉ុណ្ណោះហើយចំនួន៨០ភាគរយទៀតមិនទាន់បានដោះដែលជនល្មើសបានដាក់នៅតាមតំបន់ធនធានធម្មជាតិនានានៅប្រទេសកម្ពុជា។ លោកបានលើកឡើងដោយបញ្ជាក់ថា ផ្អែកតាមរបាយការណ៍ឆ្នាំ ២០២០នៅតំបន់អាស៊ីអាគ្នេយ៍មានអន្ទាក់ប្រមាណ១២លានអន្ទាក់ដូចជាប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី វៀតណាម ឡាវ ថៃ និងកម្ពុជាដែលកំពុងគំរាមកំហែងសត្វព្រៃ។ ដោយអន្ទាក់ទាំងនេះគឺជាដើមចមធ្វើឱ្យបាត់បង់នូវសត្វកម្រៗក្នុងលោកដូចជា ខ្លា ខ្លារខិន ខ្លាពពកស ឆ្កែព្រៃ ខ្លាឃ្មុំជាដើម។ ប្រធានអង្គការរូបនេះ ចង់ឱ្យស្ថាប័នពាក់ព័ន្ធអនុវត្តច្បាប់ចំពោះជនល្មើសសម្លាប់សត្វព្រៃកម្រ ក៏ដូចជាភោជនីយដ្ឋាន ឬតំបន់នានាដែលបានជួញដូរសត្វព្រៃ ដែលទាំងនេះសំដៅធ្វើយ៉ាងណាការពារសត្វព្រៃកម្ពុជាមិនឱ្យបាត់បង់ពូជនៅថ្ងៃខាងមុខ។

ទាក់ទិនក្នុងរឿងនេះដែរ លោក ឈិន សំអាត តំណាងមកគម្រោង USAID ព្រៃឡង់បៃតងបានលើកឡើងថា បើយើងពុំមានវិធានការណាមួយឱ្យជាក់លាក់ទៅលើបញ្ហាអន្ទាក់ដែលត្រូវបានជនល្មើសកំពុងប្រព្រឹត្តិរៀងរាល់ថ្ងៃទេយើងពិតជាទទួលរងផលលំបាកនិងសត្វព្រៃនឹងបាត់បង់បន្តបន្ទាប់ទៀតជាក់ជាពុំខាន។ទន្ទឹមជាមួយគ្នាក៏ត្រូវអនុវត្តច្បាប់និងការផ្សព្វផ្សាយក៏ជាការមួយចាំបាច់ដែលត្រូវធ្វើឡើងដល់សហគមន៍មូលដ្ឋានផងដែរ។

លោក ប៊ូវក្សេសក្ស ប្រធានអង្គការ Birdlife in Cambodia បានលើកថា អន្ទាក់ក្រៅពីបានសម្លាប់សត្វជើងជំពាម សត្វព្រៃដទៃទៀត វាក៏បានសម្លាប់សត្វស្លាបជាបន្តបន្ទាប់ផងដែរ។ ពួកគេក្រៅពីដាក់អន្ទាក់ នៅវាយមង និងដាក់ឧបករណ៍ដទៃទៀតសម្រាប់សម្លាប់សត្វដ៏កម្រថែមទៀត។ ជាក់ស្តែងក្នុងឆ្នាំ២០២១កន្លងមកសត្វត្រយ៉ងយក្ស៣ក្បាលត្រូវបានជាប់អន្ទាក់ ប៉ុន្តែត្រូវបានក្រុមសង្គ្រោះជួយដោះលែងវិញបានទាន់ពេលវេលា។ ដោយឡែកលោក Leremy Parker តំណាងមកពីអង្គការ FFI បានថ្លែងបញ្ជាក់ឱ្យដឹងថា អន្ទាក់គឺជាបញ្ហាមួយដែលយើងតែងជួបប្រទះ ហើយយើងចាំបាច់ត្រូវពង្រឹងតាមសហគមន៍ដើម្បីឱ្យគាត់ដើរល្បាត និងស្ការនៅតាមតំបន់សំខាន់ៗដើម្បីធ្វើយ៉ាងណាកុំឱ្យសម្លាប់សត្វបន្តទៅទៀត។

សូមបញ្ជាក់ថា ពិធីបើកយុទ្ធនាការអន្ទាក់សូន្យនៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២២ នឹងប្រព្រឹត្តទៅតាមប្រព័ន្ធអនឡាញដោយមានការចូលរួមពីអន្តរក្រសួង រដ្ឋបាលខេត្តពាក់ព័ន្ធ នឹងអង្គការដៃគូនានាដែលសហការជាមួយក្រសួងបរិស្ថានក្នុងយុទ្ធនាការអន្ទាក់សូន្យនេះ៕

ឯកឧត្តម សាប៊ូ អូហ្សាណា ដឹកនាំគណៈប្រតិភូចូលរួមសន្និបាតបរិស្ថាននៃអង្គការសហប្រជាជាតិលើកទី៥ និងខួបលើកទី៥០ នៃកម្មវិធីបរិស្ថានអង្គការសហប្រជាជាតិនៅទីក្រុងណៃរ៉ូប៊ី ប្រទេសកេនយ៉ា

ឯកឧត្តម សាប៊ូ អូហ្សាណា រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាតំណាង **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បានដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមសន្និបាតបរិស្ថាន នៃអង្គការសហប្រជាជាតិលើកទី៥ និងខួបលើកទី៥០ នៃកម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ នៅទីក្រុងណៃរ៉ូប៊ី ប្រទេសកេនយ៉ា ចាប់ពីថ្ងៃទី២៨ ខែកុម្ភៈ ដល់ថ្ងៃទី៤ ខែមីនា ឆ្នាំ២០២២។ កម្មវិធីទាំងពីរនេះត្រូវបានរៀបចំឡើងដោយកម្មវិធីបរិស្ថានអង្គការសហប្រជាជាតិប្រចាំទីក្រុងណៃរ៉ូប៊ី ប្រទេសកេនយ៉ា ក្រោមកិច្ចសហការ និងសម្របសម្រួលដោយរដ្ឋាភិបាលនៃសាធារណរដ្ឋកេនយ៉ា ដែលប្រធានដឹកនាំក្រោមអធិបតីភាព ឯកឧត្តម Espen Barth Eide រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងអាកាសធាតុ ប្រទេសន័រវែស ព្រមទាំងមានការចូលរួមពីតំណាងរដ្ឋជាសមាជិកជុំវិញពិភពលោកប្រមាណជាង១៩០ប្រទេស ដៃគូអភិវឌ្ឍន៍អន្តរជាតិ តំណាងអង្គការរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងបណ្ដាភាគីពាក់ព័ន្ធប្រមាណជាង ៣០០០នាក់ ដែលបានចូលរួមដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញពីចម្ងាយ។

សន្និបាតបរិស្ថាននៃអង្គការសហប្រជាជាតិលើកទី៥ មានគោលបំណងសំខាន់ក្នុងការពិភាក្សាក្រោមវិធានបទរួមដ៏មានសារៈសំខាន់ស្ដីពីការពង្រឹងសកម្មភាពគាំទ្រធម្មជាតិ ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ចំពោះលទ្ធផលរំពឹងទុក និងជាកាលានុវត្តភាពនៃវត្តមានពីបណ្ដារដ្ឋជាសមាជិកដើម្បីធ្វើបទអន្ដាគមន៍នៃការប្រកាសសេចក្តីថ្លែងការណ៍ជាតិដែលត្រូវគូសបញ្ជាក់ពីកាតព្វកិច្ចផ្លូវច្បាប់រៀងៗខ្លួន ក្នុងការចូលរួមដោះស្រាយបញ្ហាប្រឈមនានា ដែលធ្វើឱ្យប៉ះពាល់ដល់ធម្មជាតិ និងបរិស្ថាន រួមមាន ការប្រែប្រួលអាកាសធាតុ ការបាត់បង់ជីវចម្រុះ ការបំពុល និងសំណល់ ដោយកំណត់បាននូវបញ្ហាគន្លឹះក្នុងការបង្កើនសកម្មភាពទប់ស្កាត់ និងដោះស្រាយទៅបញ្ហាពាក់ព័ន្ធ ដូចជាការបំពុលដោយប្លាស្ទិក សេដ្ឋកិច្ចចក្រា និងការការពារជីវចម្រុះ។

ចំណែកខួបលើកទី៥០នៃកម្មវិធីបរិស្ថានអង្គការសហប្រជាជាតិប្រព្រឹត្តទៅក្នុងគោលបំណងសំខាន់ ដើម្បីរំលឹកខួបនូវការសម្រេចបានសមិទ្ធផលដែលទទួលបានចាប់តាំងពីថ្ងៃនៃការបង្កើតកម្មវិធីបរិស្ថានអង្គការសហប្រជាជាតិអំឡុងពេលមហាសន្និបាតអង្គការសហប្រជាជាតិស្ដីពីបរិស្ថានមនុស្សជាតិ ដែលបានរៀបចំនៅទីក្រុងស្តុកខុម ប្រទេសស៊ុយអែត។ ស្របតាមរបៀបវារៈនៃអង្គសន្និបាតនាថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ **ឯកឧត្តម សាប៊ូ អូហ្សាណា** រដ្ឋលេខាធិការក្រសួងបរិស្ថាន ដែលជាប្រធានដឹកនាំគណៈប្រតិភូកម្ពុជា និងជាតំណាងឯកឧត្តមប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បានចូលរួមថ្លែងប្រកាសសេចក្តីថ្លែងការណ៍ជាតិនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងអង្គសន្និបាតផងដែរ៕

សិក្ខាសាលាស្តីពីការផ្តើមនិងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធគម្រោងលើកកម្ពស់ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព តាមរយៈការប្រើប្រាស់អភិក្រមនវានុវត្តន៍

ក្រុមការងាររៀបចំគោលនយោបាយយុទ្ធសាស្ត្រដាំឈើលើដីឯកជន និងការដាំឈើនៅទីប្រជុំជននិងទីធ្លាសាធារណៈ នៃក្រសួងបរិស្ថាន សហការជាមួយអង្គការ FAO បានរៀបចំសិក្ខាសាលាស្តីពីការផ្តើមនិងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ គម្រោងលើកកម្ពស់ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព តាមរយៈការប្រើប្រាស់អភិក្រមនវានុវត្តន៍ ដែលដឹកនាំដោយ **ឯកឧត្តម ជា សំអាង** រដ្ឋលេខាធិការក្រសួងបរិស្ថាន។ សិក្ខាសាលាដែលប្រព្រឹត្តទៅនៅសណ្ឋាគារសាន់វេ នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២នេះ ក៏មានការអញ្ជើញចូលរួមពី អគ្គនាយកដ្ឋានពាក់ព័ន្ធចំណុះក្រោមក្រសួងបរិស្ថាន តំណាងរដ្ឋបាលព្រៃឈើ តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសាធារណៈការ និងដឹកជញ្ជូន តំណាងសាលារាជធានីភ្នំពេញ សាលកវិទ្យាល័យ និងដៃគូអភិវឌ្ឍន៍ UNDP, ADB, Worldbank, SDC, GGGI, CSIP ជាច្រើនរូបទៀត។

សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណងសំខាន់ៗ រួមមាន៖ ១)ជូនដំណឹងដល់ភាគីពាក់ព័ន្ធ និងដៃគូ អំពីវិធីសាស្ត្រ លទ្ធផលរំពឹងទុក និងការអនុវត្តគម្រោង ២)ស្វែងរកកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ ៣)ដើម្បីពិភាក្សាអំពីរបៀបបង្កើត និងទទួលគំនិតផ្តួចផ្តើមរួមមួយ និង៤)ប្រមូលធាតុចូលពីភាគីពាក់ព័ន្ធសម្រាប់ឆ្ពោះទៅមុខ អនុសាសន៍គោលនយោបាយលើដើមឈើធនធានក្រៅព្រៃឈើ សម្រាប់កម្ពុជា៕

ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់រវាងក្រសួងបរិស្ថាន ក្រសួងសាធារណៈការ និងដឹកជញ្ជូន និងទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ស្តីពី«អនុវត្តគម្រោង លើកកម្ពស់ គុណភាព ខ្យល់នៅកម្ពុជា»

«ពិធីចុះអនុស្សរណៈថ្ងៃនេះ គឺជាសក្ខីភាពបញ្ជាក់នូវស្មារតីរួមសហការគ្នា ក្នុងការលើកកម្ពស់គុណភាពបរិស្ថាន ដែលជាអាទិភាពខ្ពស់មួយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហា សេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ដែលបានដាក់ចេញនូវវិធានការជាបន្តបន្ទាប់ ក្នុងនោះរួមមានសារាចរណែនាំស្តីពីវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់សាធារណៈ និងផែនការខ្យល់ស្អាតកម្ពុជា ដែលជាផែនការយុទ្ធសាស្ត្រជាតិសម្រាប់កំណត់ សកម្មភាពកាត់បន្ថយការបញ្ចេញសារធាតុបំពុលខ្យល់នៅកម្ពុជា សំដៅធានាឱ្យបាននូវស្រទាប់បរិយាកាស ទ្រទ្រង់ជីវិតដ៏ល្អប្រសើរ។»

នេះជាការលើកឡើងរបស់ **ឯកឧត្តម សុខ គាង** រដ្ឋលេខាធិការក្រសួងបរិស្ថាន ក្នុងឱកាសអញ្ជើញជាអធិបតីពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់រវាងក្រសួងបរិស្ថាន ក្រសួងសាធារណៈការ និងដឹកជញ្ជូន និងទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ នៅស្តីការក្រសួងបរិស្ថាន នៅរសៀលថ្ងៃអង្គារ ទី១០ ខែឧសភា ឆ្នាំ២០២២។

ឯកឧត្តម តូច ចាន់កុសល រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន បានមានប្រសាសន៍ថា តាមរយៈការចុះហត្ថលេខាលើ MOU នេះក្រសួងយើងទាំង២ នឹងពង្រីកកិច្ចសហប្រតិបត្តិការបន្ថែមទៀត លើការងារកាត់បន្ថយការបំភាយឧស្ម័នដោយយានយន្ត ដើម្បីលើកកម្ពស់ គុណភាពខ្យល់ និងឈានទៅរកការលើកកម្ពស់សុខមាលភាពរបស់ប្រជាពលរដ្ឋយើងផងដែរ។

លោក Yazid Bensaid នាយកទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ (AFD)ប្រចាំតំបន់អាស៊ីអាគ្នេយ៍ បានមានប្រសាសន៍ថា AFD គឺជាដៃគូរសហការជាយូរមកហើយជាមួយរាជរដ្ឋាភិបាលកម្ពុជាតាំងពីឆ្នាំ១៩៩៣មកម្ល៉េះ ដោយបានធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួងស្ថាប័នជាច្រើន ។ បច្ចុប្បន្នAFD បានគាំទ្រលើគម្រោងចំនួន ៣២ ពាក់ពន្ធ័នឹងវិស័យ បច្ចេកវិទ្យាបរិស្ថាន សេដ្ឋកិច្ច និងដឹកជញ្ជូន ។ តាមរយៈការអនុវត្តកម្មវិធីថ្នាក់តំបន់របស់ទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ ដើម្បីលើកកម្ពស់គុណភាពខ្យល់នៅអាស៊ី

អាគ្នេយ៍ AFD នឹងគាំទ្រ ដល់បណ្តាប្រទេស និងទីក្រុងទាំងឡាយណា ដែលមានគោលនយោបាយ និងគម្រោង ដើម្បីធ្វើអោយប្រសើរឡើងនូវគុណភាពខ្យល់។

គួរបញ្ជាក់ថា៖ ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ ស្តីពីការអនុវត្តកម្មវិធីលើកកម្ពស់គុណភាពខ្យល់នាថ្ងៃនេះ ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង នឹងគាំទ្រ២ ចំនុចសំខាន់ គឺ ១-ការបណ្តុះបណ្តាលដល់មន្ត្រីជំនាញ និងការរៀបចំបទប្បញ្ញត្តិ និងគោលនយោបាយពាក់ពន្ធ័ទៅនឹងការកម្រិតការបំភាយឧស្ម័នពីយានយន្ត ២-ការជួយអភិវឌ្ឍន៍គម្រោងនានាទាក់ទងនឹងការបំលាស់ទី ដោយថាមពលអគ្គិសនី៕

លោកជំទាវ ចាន់ សុម៉ាលី ដឹកនាំប្រតិភូចូលរួមកិច្ចប្រជុំបច្ចេកទេស SBTTA-24 និង SBI-3 និងកិច្ចប្រជុំក្រុមការងារ WG2020-3 នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស

ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ **លោកជំទាវ ចាន់ សុម៉ាលី** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន បានដឹកនាំប្រតិភូកម្ពុជា មកពីនាយកដ្ឋានជីវៈចម្រុះនៃក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចូលរួមកិច្ចប្រជុំបច្ចេកទេស SBTTA-24 និង SBI-3 និងកិច្ចប្រជុំក្រុមការងារ WG2020-3 នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ដែលរៀបចំឡើងដោយលេខាធិការដ្ឋានអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ (UNCBD) និងមានការចូលរួមពីប្រទេសជារដ្ឋភាគី ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការសង្គមស៊ីវិល ក្រុមយុវជនស្ត្រី និងបណ្តាញសហគមន៍ជនជាតិដើមភាគតិច សរុបប្រមាណជាង៣០០០នាក់។

គោលបំណងកិច្ចប្រជុំនេះគឺដើម្បីពិនិត្យ និងពិភាក្សាថ្នាក់បច្ចេកទេស និងលើកជាអនុសាសន៍សម្រាប់ដាក់ជូនសន្និសីទកំពូលលើកទី១៥ (COP-15) នៅទីក្រុងគួនមីង សាធារណរដ្ឋប្រជាមានិតចិន ពិនិត្យ និងអនុម័ត នាពេលខាងមុខ។

ជាលទ្ធផល កិច្ចប្រជុំទាំងបីនេះ បានពិនិត្យ និងអនុម័តកំរិតបច្ចេកទេសលើសេចក្តីព្រាងឯកសារនៃរបៀបវារៈជាច្រើន រួមមាន៖

១. សេចក្តីព្រាងអនុសាសន៍ស្តីពីទស្សនវិស័យជីវៈចម្រុះសកល និងសារៈសំខាន់ផ្សេងៗទៀតសម្រាប់អ្នកនយោបាយក្នុងការធ្វើសម្រេចចិត្ត។

២. ការពិនិត្យឡើងវិញអំពីវឌ្ឍនភាពនៃការអនុវត្តអនុសញ្ញា UNCBD និងផែនការយុទ្ធសាស្ត្រជីវៈចម្រុះសកលឆ្នាំ២០១១-២០២០។

៣. ការពិចារណាលើសេចក្តីព្រាងអនុសាសន៍សម្រាប់អនុម័តលើក្របខណ្ឌការងារជីវៈចម្រុះសកលក្រោយឆ្នាំ២០២០ (Post-2020 GBF) ដែលរួមមាន៖ ក)ផែនការអនុវត្តក្របខណ្ឌជីវៈចម្រុះ ខ)ផែនការសកម្មភាពយេនឌ័រ គ)ក្របខណ្ឌយុទ្ធសាស្ត្រទំនាក់ទំនង និង ឃ)ការកសាងសមត្ថភាពសម្រាប់អនុវត្តអនុសញ្ញា UNCBD និងពិធីសារពាក់ព័ន្ធ។

៤. ការពិនិត្យលើខ្លឹមសារនៃសេចក្តីព្រាង Post-2020 GBF ដោយផ្តោតជាសំខាន់លើ គោលដៅ(Goal) ទិសដៅ(Targets) សមិទ្ធផលរំពឹងទុក(Milestone) ជាពិសេសគឺការកសាងសមត្ថភាព

យន្តការសម្របសម្រួល វិធានការ និងថវិកាសម្រាប់អនុវត្ត។ ទន្ទឹមនឹងនេះ បណ្តាដៃគូភាគី ភ្នាក់ងារអង្គការសហប្រជាជាតិ និងសង្គមស៊ីវិល ក៏បានជំរុញឱ្យការអនុវត្ត Post-2020 GBF អាចទទួលបាននូវលទ្ធផលតាមការរំពឹងទុកគឺនៅឆ្នាំ២០៣០ ផ្ទៃសមុទ្រ និងតំបន់ឆ្នេរ៣០% ត្រូវបានការពារ ឬហៅថា (៣០x៣០)។ អង្គប្រជុំក៏បានសម្រេចថា សម្រាប់សេចក្តីព្រាង Post-2020 GBF និងយន្តការរៀបចំ និងការប្រើប្រាស់ Digital Sequence Information (DSI) on Genetic Resources នឹងត្រូវលើកយកទៅពិភាក្សាក្នុងកិច្ចប្រជុំលើកទី៤ WG2020-4 ដើម្បីឱ្យមានការសម្រេចរួមសម្រាប់ថ្នាក់បច្ចេកទេស មុននឹងដាក់ជូនសន្និសីទកំពូលលើកទី១៥ (COP-15) ពិនិត្យ និងអនុម័ត។

តាមរយៈការចូលរួមកិច្ចប្រជុំខាងលើ ប្រតិភូកម្ពុជា ក៏បានជួបពិភាក្សាទ្វេភាគី និងចូលរួមកិច្ចប្រជុំដោយឡែកជាមួយបណ្តាប្រទេស អង្គការអន្តរជាតិ និងម្ចាស់ជំនួយនានា ដើម្បីពិភាក្សាការងារពាក់ព័ន្ធ រួមទាំងការកៀរគរថវិកា និងជំនួយបច្ចេកទេសសម្រាប់អនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងសកម្មភាពអាទិភាពនានាពាក់ព័ន្ធនឹងការគ្រប់គ្រង និងអភិរក្សជីវៈចម្រុះនៅកម្ពុជាផងដែរ។

កម្ពុជាចែករំលែកបទពិសោធន៍កម្មវិធីរេដបូកជាមួយឥណ្ឌូនេស៊ី

មន្ត្រីជាន់ខ្ពស់នៃក្រសួងបរិស្ថានកម្ពុជា បានចែករំលែកបទពិសោធន៍ជោគជ័យលើការអនុវត្ត កម្មវិធីរេដបូកជាមួយប្រតិភូក្រសួងបរិស្ថាននិងព្រៃឈើឥណ្ឌូណេស៊ី ជាពិសេសលើការការពារនិងអភិរក្សធនធានធម្មជាតិដោយថែរក្សាឈើឈរ តាមរយៈឥណទានកាបូន ក្នុងទីផ្សារកាបូនស្ម័គ្រចិត្ត។

ឯកឧត្តម ជួប ប៉ារីស៍ អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន បានថ្លែងថា ជំនួបនៃភាគីទាំងពីរកម្ពុជានិងឥណ្ឌូនេស៊ី នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ នៅទីស្តីការក្រសួងបរិស្ថាន បានធ្វើការផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ក្នុងនោះកម្ពុជាដែលស្ថិតនៅក្នុងចំណោមប្រទេសមួយកំពុងអនុវត្តកម្មវិធីរេដបូក (REDD+) បានយ៉ាងល្អប្រសើរ និងកម្ពុជាក៏មានព្រៃឈើមួយដ៏ល្អផងដែរ។

ឯកឧត្តមអនុរដ្ឋលេខាធិការ បានលើកឡើងផងដែរថា កម្ពុជាទទួលបានល្អទៅលើការអនុវត្តរេដបូកនេះដោយសារកត្តា៣យ៉ាង សំខាន់ៗគឺ ទី១.កម្ពុជាមានសន្តិភាព ទី២.ការតាំងចិត្ត និងប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ជាពិសេសការយកចិត្តទុកដាក់ពីប្រមុខរាជរដ្ឋាភិបាល សម្តេចតេជោ ហ៊ុន សែនក្នុងកិច្ចការពារនិងអភិរក្សធនធានធម្មជាតិ និងទី៣. គឺកត្តាដឹកនាំ ដោយយើងអាចការពារព្រៃឈើបាន និងលក់ឥណទានកាបូន ក្នុងទីផ្សារកាបូនស្ម័គ្រចិត្ត ដោយជោគជ័យរហូតមកដល់បច្ចុប្បន្ន។ សម្រាប់ថវិកាទាំងអស់ពីការលក់កាបូននេះ បានយកទៅប្រើប្រាស់សម្រាប់ការពារព្រៃឈើ និងអភិវឌ្ឍជីវភាពសហគមន៍មូលដ្ឋាន។

ឯកឧត្តម ជួប ប៉ារីស៍ បានលើកឡើងបន្ថែមថារេដបូកមានគោលបំណង (១)ការពារព្រៃឈើឱ្យបានគង់វង្សសម្រាប់ជាផលប្រយោជន៍ជាតិ និង(២)ចូលរួមកាត់បន្ថយការប្រែប្រួលអាកាសធាតុសកល ក្នុងអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ ក្រៅពីផលប្រយោជន៍ជាឈើប្រើប្រាស់ និងជាមុខងារក្នុងប្រព័ន្ធអេកូឡូស៊ី ព្រៃឈើនៅមានមុខងារដ៏សំខាន់មួយទៀត គឺការស្រូបយកឧស្ម័នកាបូនិច (ឧស្ម័នផ្ទះកញ្ចក់) ពីបរិយាកាស ដែលមុខងារនេះ ដើរតួនាទីសំខាន់ ក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់សកល។

ទាក់ទិនក្នុងរឿងនេះដែរ លោកStephan Bognar ប្រចាំនៅ WWC CAMBODIA/ASIA SUSTAINABILITYក្នុងប្រទេស



កម្ពុជាបានឱ្យដឹងថា កិច្ចពិភាក្សារវាងភាគីកម្ពុជា-ឥណ្ឌូនេស៊ីស្តីពីរេដបូកបានធ្វើការផ្លាស់ប្តូរយោបល់គ្នា ទៅវិញទៅមក ហើយភាគីឥណ្ឌូណេស៊ីបានស្វែងយល់ពីយន្តការគ្រប់គ្រងកម្មវិធីរេដបូកជាតិរបស់កម្ពុជា ដែលទទួលបានជោគជ័យលើការលក់ឥណទានកាបូនក្នុងទីផ្សារកាបូនស្ម័គ្រចិត្ត នាពេលកន្លងមក៕

ការផ្សព្វផ្សាយពង្រឹងសមត្ថភាពមន្ត្រីក្នុងការគ្រប់គ្រងព័ត៌មានបរិស្ថានតាមប្រព័ន្ធទំនាក់ទំនងសង្គម

«ការយល់ដឹងពីប្រព័ន្ធសុវត្ថិភាពនៃការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម នឹងអាចចូលរួមប្រឆាំងនឹងព័ត៌មានក្លែងក្លាយ។» នេះជាការលើកឡើងរបស់ **ឯកឧត្តម ខៀ អាទិត្យា** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន ក្នុងឱកាសបើកសិក្ខាសាលាផ្សព្វផ្សាយស្តីពី «ការការពារនិងទប់ស្កាត់ការផ្សព្វផ្សាយព័ត៌មានមិនពិត Cyber Security» នៅទីស្តីការក្រសួងបរិស្ថាន នាថ្ងៃអង្គារ ទី១៧ ខែឧសភា ឆ្នាំ២០២២។

ឯកឧត្តមអនុរដ្ឋលេខាធិការ បានបន្ថែមថានៅកម្ពុជា ប្រព័ន្ធទំនាក់ទំនងសង្គមមានច្រើន តែពេញនិយមជាងគេគឺហ្វេសប៊ុក ដែលជាបណ្តាញប្រភពព័ត៌មានចម្រុះ។ ប៉ុន្តែកាផ្សព្វផ្សាយលើហ្វេសប៊ុកមួយចំនួនមិនមែនជាការពិត ដែលវាអាចបង្កគ្រោះថ្នាក់ សម្រាប់អ្នកលេងហ្វេកប៊ុក ក្នុងការយកព័ត៌មានទាំងនោះ ទៅប្រើប្រាស់ក្នុងផ្លូវអាក្រក់ណាមួយ។

ក្នុងឱកាសនោះ **ឯកឧត្តម** បានលើកឡើងថាក្រសួងបរិស្ថានបានបើកសិក្ខាសាលាស្តីពីការការពារ និងទប់ស្កាត់ការផ្សព្វផ្សាយព័ត៌មានមិនពិត នាពេលនេះ ក្នុងគោលបំណងកសាងសមត្ថភាពមន្ត្រីជំនាញ ដែលគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីបង្កើនសុវត្ថិភាពលើការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម។

ឯកឧត្តម បានបន្តថា «ដើម្បីប្រយុទ្ធប្រឆាំងនឹងព័ត៌មានក្លែងក្លាយប្រកបដោយប្រសិទ្ធភាព យើងត្រូវផ្សព្វផ្សាយពីការពិតឱ្យបានច្រើន និងឱ្យបានលឿន ព្រោះការផ្តល់ព័ត៌មានពិត គឺជាវិធានការដ៏មានប្រសិទ្ធភាពប្រឆាំងនឹងព័ត៌មានក្លែងក្លាយផង និងជាការបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ ហើយពេលប្រជាពលរដ្ឋយល់ដឹង នោះពួកគាត់នឹងចូលរួម គាំទ្រនូវបុព្វហេតុរបស់ស្ថាប័នកាន់តែសកម្មថែមទៀត។ យើងមិនត្រូវជឿលើការផ្សព្វផ្សាយព័ត៌មានដែលគ្មានប្រភពច្បាស់លាស់នោះឡើយ ពោលគឺត្រូវពិនិត្យឱ្យបានច្បាស់លាស់មុននឹងផ្សព្វផ្សាយ ឬស៊ែរសារនានាលើបណ្តាញទំនាក់ទំនងសង្គមនោះបន្ត។

សូមបញ្ជាក់ថា ការផ្សព្វផ្សាយស្តីពីការការពារនិងទប់ស្កាត់ការផ្សព្វផ្សាយព័ត៌មានមិនពិត Cyber Security បានរៀបចំឡើងដោយនាយកដ្ឋានព័ត៌មាននិងផ្សព្វផ្សាយបរិស្ថាន នៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ដោយមានបទបង្ហាញពីអ្នកជំនាញ

ផ្នែកប្រព័ន្ធព័ត៌មានវិទ្យា នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងមានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីរាជការ តំណាងអគ្គនាយកដ្ឋាននានា និងមកពីមន្ទីរបរិស្ថានរាជធានី ខេត្តទាំង២៥។ សិក្ខាសាលានេះបានផ្ដោតសំខាន់ទៅលើចំណុចមួយចំនួនមានដូចជា ការគ្រប់គ្រង Facebook Page ការគ្រប់គ្រងសន្តិសុខនិងសុវត្ថិភាពក្នុងការប្រើប្រាស់បណ្តាញសង្គមហ្វេសប៊ុក ដំណោះស្រាយនៅពេលមានគណនីហ្វេសប៊ុកត្រូវបានHack ធ្វើយ៉ាងណាដើម្បីឱ្យការប្រើប្រាស់ប្រកបដោយសុវត្ថិភាព និងកាត់បន្ថយហានិភ័យនៃការវាយប្រហារពីចោរបច្ចេកវិទ្យា និងដើម្បីយល់ដឹងអំពីបច្ចេកទេសថ្មីៗ ក្នុងការឆ្លើយតបទៅនឹងហានិភ័យនានាដែលអាចកើតមានឡើងតាមរយៈប្រព័ន្ធអ៊ីនធឺណិត៕

ឯកឧត្តម ជា ស៊ីណា ដឹកនាំកិច្ចប្រជុំ Retreat ដើម្បីពិនិត្យ ផ្ដល់យោបល់ និង កែសម្រួល លើសេចក្ដីព្រាងមួយចំនួន

ឯកឧត្ដម ជា ស៊ីណា អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន បានដឹកនាំកិច្ចប្រជុំ Retreat ដើម្បីពិនិត្យ ផ្ដល់យោបល់ និង កែសម្រួល លើសេចក្ដីព្រាងមួយចំនួនរួមមាន៖ ១) សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការគ្រប់គ្រងផលិតផល និងសំណល់ប្លាស្ទិក ២) សេចក្ដីព្រាងរបាយការណ៍សិក្សាពីការទទួលខុសត្រូវបន្ថែមរបស់អ្នកផលិត (Extended Producer Responsibility-EPR) ៣)សេចក្ដីព្រាងរបាយការណ៍សិក្សាពីវិសាលភាពទីផ្សារនៃការគ្រប់គ្រងប្លាស្ទិក និងEPR និង៤)សេចក្ដីព្រាងរបាយការណ៍ស្ដីពីការកែច្នៃ ដែលបានរៀបចំដោយគម្រោងការទប់ស្កាត់សំណល់ប្លាស្ទិកសមុទ្រនៅកម្ពុជា នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ នាខេត្តកំពង់ឆ្នាំង ដោយមានការចូលរួមពី ឯកឧត្តម គិត ច័ន្ទគ្រីស្នា ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី និងជានាយកគម្រោងជាតិ ឯកឧត្តម ប៉ាក់ សុខាវ៉ារុធ អគ្គនាយកនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន លោកជំទាវ ងិន លីណា អគ្គនាយិការងនៃអគ្គនាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ ព្រមទាំងមន្ត្រីជំនាញមកពីនាយកដ្ឋានគ្រប់គ្រងសំណល់រឹង នាយកដ្ឋានសេដ្ឋកិច្ចបៃតង តំណាងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) និងក្រុមការងារគម្រោងការទប់ស្កាត់សំណល់ប្លាស្ទិកសមុទ្រនៅកម្ពុជា ជាច្រើនរូបទៀត។ កិច្ចប្រជុំពិនិត្យ ផ្ដល់យោបល់ និង កែសម្រួល លើសេចក្ដីព្រាងទាំងនេះ ធ្វើឡើងក្នុងគោលបំណងដើម្បីបង្កើនយន្តការក្នុងកាត់បន្ថយសំណល់ប្លាស្ទិក និងលើកទឹកចិត្តការប្រើប្រាស់សម្ភារជំនួសប្លាស្ទិក៕

ផ្នែកទី ៣
ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១០៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលមាត្រា៤ មាត្រា៩ មាត្រា១១ មាត្រា១២ មាត្រា១៧ និងតារាង ឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ ឧបសម្ព័ន្ធ៤ និងឧបសម្ព័ន្ធ៥ នៃអនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សម្រេច

មាត្រាមួយ .-

មាត្រា៤ មាត្រា៩ មាត្រា១១ មាត្រា១២ មាត្រា១៧ និងតារាងឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ ឧបសម្ព័ន្ធ៤ និងឧបសម្ព័ន្ធ៥ នៃអនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក ត្រូវបានធ្វើការកែសម្រួល ដូចតទៅៈ

មាត្រា៨.-ថ្មី

ការបញ្ចេញសំណល់រាវពីប្រភពបំពុលនានា ត្រូវអនុលោមតាមកម្រិតកំណត់ស្តង់ដានៃការបញ្ចេញសំណល់រាវដែលមានចែងក្នុងតារាងឧបសម្ព័ន្ធ២ នៃអនុក្រឹត្យនេះ។

មាត្រា៩.-ថ្មី

ហាមឃាត់ដាច់ខាត៖

ក-ការបញ្ចេញទឹកកខ្វក់ពីប្រភពបំពុលចូលទៅក្នុងបណ្តាញលូសាធារណៈឬតំបន់ទឹកសាធារណៈ ដោយមិនបានធ្វើប្រព្រឹត្តកម្មសម្អាតឬមិនឆ្លើយតបស្តង់ដាបញ្ចេញដែលមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ខ-ការបញ្ចេញសំណល់រាវមិនឆ្លងកាត់អាងប្រព្រឹត្តកម្មសម្អាតសំណល់រាវ។

គ-ការបង្កប់លូឬការបូមបញ្ចេញសំណល់រាវវាងមិនឆ្លងកាត់អាងប្រព្រឹត្តកម្មសម្អាតសំណល់រាវ។

ឃ-ការមិនដាក់ឱ្យដំណើរការអាងប្រព្រឹត្តកម្មសម្អាតសំណល់រាវឬដំណើរការអាងប្រព្រឹត្តកម្មសម្អាតសំណល់រាវមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដែលបានកំណត់នៅក្នុងលិខិតអនុញ្ញាតរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច។

មាត្រា១១.-ថ្មី

ប្រភពបំពុលដែលតម្រូវឱ្យសុំការអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការបញ្ចេញចោលឬដឹកជញ្ជូនចេញនូវសំណល់រាវរបស់ម្ចាស់សំណើទៅកន្លែងដទៃទៀត ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ៣ នៃអនុក្រឹត្យនេះ មានបីកម្រិតដូចខាងក្រោម៖

ក-ប្រភពបំពុលកម្រិតទី១ តម្រូវឱ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន ក្នុងករណីដែលបរិមាណសំណល់រាវរបស់ប្រភពបំពុលនោះមានចំនួនច្រើនជាង៤០ម៉ែត្រគូបក្នុងមួយថ្ងៃ ដោយពុំគិតបញ្ចូលនូវបរិមាណទឹកដែលប្រើប្រាស់សម្រាប់ប្រព័ន្ធត្រជាក់គ្រឿងចក្រ។

ខ-ប្រភពបំពុលកម្រិតទី២ តម្រូវឱ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន ក្នុងករណីដែលបរិមាណសំណល់រាវរបស់ប្រភពបំពុលនោះមានចំនួនច្រើនជាង២០ម៉ែត្រគូបក្នុងមួយថ្ងៃ ដោយពុំគិតបញ្ចូលនូវបរិមាណទឹកដែលប្រើប្រាស់សម្រាប់ប្រព័ន្ធត្រជាក់គ្រឿងចក្រ។

គ-ប្រភពបំពុលកម្រិតទី៣ តម្រូវឱ្យមានការសុំការអនុញ្ញាតពីក្រសួងបរិស្ថាន ទោះបីក្នុងបរិមាណណាក៏ដោយ។

នីតិវិធីនៃការស្នើសុំការអនុញ្ញាតធ្វើការបញ្ចេញចោលឬដឹកជញ្ជូនចេញនូវសំណល់រាវរបស់ម្ចាស់សំណើទៅកន្លែងដទៃទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថានស្តីពីនីតិវិធីនៃការស្នើសុំការអនុញ្ញាតធ្វើការបញ្ចេញចោលឬដឹកជញ្ជូនចេញនូវសំណល់រាវ។

មាត្រា១២.-ថ្មី

ការស្នើសុំបញ្ចេញចោលនូវសំណល់រាវពីប្រភពបំពុលអាចទទួលបានការអនុញ្ញាត លុះត្រាតែ៖

ក-មានការបំពាក់បរិក្ខារប្រព្រឹត្តកម្មសម្អាតសំណល់រាវ និងបញ្ចេញសំណល់រាវបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងស្ថិតក្នុងស្ថានភាពដំណើរការជាប្រក្រតី។

ខ- ការបញ្ចេញសំណល់រាវ គឺបានឆ្លើយតបនឹងស្តង់ដានៃការបញ្ចេញសំណល់រាវ។

ការស្នើសុំដឹកជញ្ជូនចេញនូវសំណល់រាវពីប្រភពបំពុលអាចទទួលបានការអនុញ្ញាត លុះត្រាតែ៖

ក-មានការបញ្ជាក់ច្បាស់ពីគោលបំណងនៃការស្នើសុំដឹកជញ្ជូនចេញនូវសំណល់រាវ និងមធ្យោបាយគ្រប់គ្រងសំណល់របស់ទីតាំងដែលទទួលសំណល់រាវ។

ខ-បានបំពេញលក្ខខណ្ឌតម្រូវដូចមានកំណត់នៅក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថានស្តីពីនីតិវិធីនៃការស្នើសុំការអនុញ្ញាតធ្វើការបញ្ចេញចោលឬដឹកជញ្ជូនចេញនូវសំណល់រាវ។

មាត្រា១៧.- ថ្មី

លិខិតអនុញ្ញាតបញ្ចេញចោលឬដឹកជញ្ជូនចេញនូវសំណល់រាវ ត្រូវព្យួរជាបណ្តោះអាសន្នឬដកហូតជាស្ថាពរ ក្នុងករណីណាមួយដូចខាងក្រោម៖

ក-មិនបានអនុវត្តត្រឹមត្រូវតាមស្តង់ដានៃការបញ្ចេញសំណល់រាវ។

ខ-ខកខានមិនបានអនុវត្តលក្ខខណ្ឌតម្រូវ ដែលមានកំណត់ក្នុងលិខិតអនុញ្ញាត។

គ-កើតមានករណីការបំពុលបរិស្ថានឬការបង្កគ្រោះថ្នាក់ដល់សុខភាពបណ្តាលមកពីសកម្មភាពគ្រប់គ្រងសំណល់រាវមានការខ្វះចន្លោះឬការធ្វេសប្រហែស។

មាត្រាពីរ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រាបី .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៥ រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សាយ សំអាល់

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រាបី
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

៣/៣

ផ្នែកទី ៤
សំណល់រឹង និងសារធាតុគ្រោះថ្នាក់

សារធាតុបារត

បារត
ឈានដល់ពេលាមួយដែលយើងត្រូវគិតគូរ និងចូលរួមទាំងអស់គ្នា

រៀបរៀងដោយ៖ **នាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់** នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន

១.តើអ្វីទៅជាបារត?

បារត ដែលត្រូវបានគេស្គាល់ថាជា quicksilver ជាប្រភេទលោហៈធ្ងន់មានពណ៌សបែកប្រផេះ (silvery-white) ស្ថិតក្នុងទម្រង់ជាអង្គធាតុរាវ និងងាយហួត។

បារត មាន ០៣ទម្រង់គឺ៖ បារតរាវ (Elemental) (Hg^0) បារតអសរីរាង្គ (Inorganic Mercury) (Hg^+) និង (Hg^{++})និង បារតសរីរាង្គ (មេទីលបារត) (CH_3Hg^+)។

- **បារតរាវ(Elemental)៖** ស្ថិតក្នុងទម្រង់ជាអង្គធាតុរាវ និងមានពណ៌ប្រាក់។ បារតងាយនឹងរលាយ និងហួតទៅជាចំហាយទៅក្នុងបរិយាកាស ដែលធ្វើឱ្យងាយចូលក្នុងខ្លួនយើងពេលដែលយើងដកដង្ហើម។

  លក្ខណៈគ្រោះថ្នាក់៖ បារតងាយឆ្លងទៅក្នុងប្រព័ន្ធឈាម/ខួរក្បាល និងអាចចូលទៅក្នុងទឹកដោះបាន។បារតគឺជាសារធាតុ neurotoxin ដ៏ខ្លាំងក្លាដែលជះឥទ្ធិពលដល់មជ្ឈមណ្ឌលប្រសាទដែលបង្កជាបញ្ហាដូចជា ញ័រ ការផ្លាស់ប្តូរអារម្មណ៍ញឹកញាប់ គេងមិនលក់ បាត់បង់ការសម្របសម្រួលការនិយាយ (រដុប ឬនិយាយមិនច្បាស់)។ការប៉ះពាល់ខ្លាំងអាចប៉ះពាល់ដល់តម្រងនោម ដំណកផ្លូវដង្ហើម និងអាចបណ្តាលឱ្យស្លាប់ផងដែរ។

- **បារតអសរីរាង្គ (Inorganic Mercury)៖** ជាធម្មតាមានពណ៌សលើកលែងតែ cinnabar ដែលមានពណ៌ក្រហម។ បារតអសរីរាង្គអាចចូលក្នុងខ្លួនតាមរយៈមាត់ និងស្បែកពីផលិតផលដូចជាថ្នាំសម្លាប់សត្វល្អិត ផ្សិត ឬផលិតផលលាបស្បែក។ សមាសធាតុបារតអសរីរាង្គត្រូវបានរកឃើញជាញឹកញាប់នៅក្នុងមន្ទីរពិសោធន៍វិទ្យាសាស្ត្រសាលារៀន។

  លក្ខណៈគ្រោះថ្នាក់៖ បារតអសរីរាង្គមានជាតិពុលតិចបំផុតក្នុងចំណោមទម្រង់ទាំងបីនៃបារត។ បារតអាចធ្វើឱ្យខូចដល់ប្រព័ន្ធរំលាយអាហារ ក៏ដូចជាតម្រងនោម និងប្រព័ន្ធសរសៃប្រសាទ។ ការ

ប៉ះពាល់កម្រិតធ្ងន់ធ្ងរអាចបណ្តាលឱ្យមានកន្ទួលលើស្បែក របកស្បែក ផ្លាស់ប្តូរអារម្មណ៍ បាត់បង់ការចងចាំ ខូចខាតដល់ផ្លូវចិត្ត និងខ្សោយសាច់ដុំ។

- **បារតសរីរាង្គ (មេទីលបារត)៖** មេទីលបារតជាទូទៅត្រូវបានរកឃើញនៅក្នុងបរិស្ថាន។ វាត្រូវបានបំលែងពីទម្រង់អសរីរាង្គរបស់វាដោយដំណើរការបាក់តេរីជីវសាស្ត្រ ។ វាអាចបង្កើនបរិមាណតាមបែបជីវសាស្ត្រ(bioaccumulate)នៅក្នុងបរិស្ថានហើយជាទូទៅត្រូវបានរកឃើញនៅក្នុងត្រី។ ការទទួលទានត្រីចូលតាមមាត់គឺជាផ្លូវទូទៅបំផុតចូលទៅក្នុងខ្លួនមនុស្ស ។

  គ្រោះថ្នាក់៖ មេទីលបារតឆ្លងកាត់ឈាម/ខួរក្បាល និងអាចឆ្លងកាត់ទៅកាន់សុករបស់ទារកក្នុងផ្ទៃដែលអាចបណ្តាលឱ្យខូចមជ្ឈមណ្ឌលប្រសាទ និងពិការភាពពីកំណើត បញ្ហាសរសៃប្រសាទ និងការយឺតយ៉ាវក្នុងការអភិវឌ្ឍ។ ទារកគឺងាយនឹងទទួលរងផលប៉ះពាល់ទៅនឹងឥទ្ធិពលនៃសារជាតុពុលមេទីលបារត ពីព្រោះការសិក្សាបានបង្ហាញថា កម្រិតឈាមរបស់ទារកមានផ្ទុកទៅដោយបរិមាណកំហាប់បារតទ្វេដងបើធៀបទៅនឹងបរិមាណកំហាប់បារតដែលមានផ្ទុកក្នុងកម្រិតឈាមរបស់ម្តាយ។ ការប៉ះពាល់រ៉ាំរ៉ៃទៅនឹងមេទីលបារតអាចបណ្តាលឱ្យមានបញ្ហាចុះខ្សោយចក្ខុវិស័យ ការនិយាយ ការដើរ ការស្តាប់ និងការខ្វះការសម្របសម្រួល។ ការប៉ះពាល់ខ្លាំងអាចបណ្តាលឱ្យស្លាប់។

២.ប្រភេទ និងប្រភពនៃការសាយភាយបារត

២.១ ប្រភេទនៃការសាយភាយបារត

ប្រភេទនៃការសាយភាយបារត ចែកចេញជា 02ប្រភេទ ដូចខាងក្រោម៖

- **ប្រភេទធម្មជាតិ** ៖ សំដៅដល់ការចល័ត (mobilization) ឬការសាយភាយបារតតាមរយៈដំណើរការភាវៈមានជីវិត (natural biotic) និងភាវៈគ្មានជីវិត (abiotic) ដោយបម្លាស់ទី (mass transfer) នៃបារតចូលទៅក្នុងបរិយាកាស។
- **ប្រភេទដែលកើតឡើង ឬបង្កឡើងតាមរយៈសកម្មភាពមនុស្ស៖** សំដៅដល់ការចល័ត (mobilization) ឬការសាយភាយបារតតាមរយៈសកម្មភាពមនុស្សដោយបម្លាស់ទី (mass transfer) នៃបារតចូលទៅក្នុងបរិយាកាស។

២.២ ប្រភពនៃការសាយភាយបារត

- **ប្រភេទធម្មជាតិ** ដែលបណ្តាលឱ្យមានការសាយភាយបារតមានប្រភពមកពី ៖ បន្ទុះភ្នំភ្លើង ភ្លើងឆេះព្រៃ Cinnabar (រ៉ែ) និងផូស៊ីលឥន្ធនៈដែលមានដូចជាធ្យូងថ្ម និងប្រេងឥន្ធនៈ (petroleum)។ល។

- **ប្រភេទដែលកើតឡើង ឬបង្កឡើងតាមរយៈសកម្មភាពមនុស្ស** ដែលបណ្ដាលឱ្យមានការសាយភាយបារតមានប្រភពមកពីសកម្មភាពដូចខាងក្រោម៖
  - ចំហេះឥន្ធនៈ
  - ការដុតសំណល់
  - ដំណើរការឧស្សាហកម្ម
  - ការដុតរ៉ែលោហៈ (metal ore roasting)
  - ការចម្រាញ់
  - ដំណើរការកែច្នៃផ្សេងៗ ។ល

យោងតាមការវាយតម្លៃបារតជាសកលរបស់អង្គការកម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) នាឆ្នាំ2018 បានឱ្យដឹងជាសកលថា អាជីវកម្មរ៉ែមាសខ្នាតតូច និងលក្ខណៈគ្រួសារ (ASGM) គឺជាប្រភពធំចម្បងបំផុតនៃការសាយភាយបង្កឡើងដោយសកម្មភាពមនុស្ស (37.7%) និងចំហេះធ្យូងថ្ម (21%)។ ប្រភពដទៃទៀតបង្កឱ្យមានការសាយភាយបារតគឺផលិតផលលោហៈមិនមែនដែក (Non-Ferrous Metals Production) (15%) និងផលិតកម្មផលិតស៊ីម៉ង់ត៍ (11%)។

ប្រភពនៃការសាយភាយបារតជាសកលនាឆ្នាំ2018

ប្រភព	**បរិមាណ (គីឡូក្រាម)**
អាជីវកម្មរ៉ែមាសខ្នាតតូច និងលក្ខណៈគ្រួសារ (ASGM)	837,658
ចំហេះធ្យូងថ្ម	473,777
ផលិតកម្មលោហៈមិនមែនដែក	326,657
ផលិតកម្មផលិតស៊ីម៉ង់ត៍	233,168
សំណល់ចេញពីផលិតផល	146,938
វីនីលក្លរីនម៉ូណូមែរ (Vinyl Chlorine Monomer)	58,268
ការដុតជីវម៉ាស	51,860
ផលិតកម្មលោហៈដែក	39,903
ផលិតកម្មក្លរអាល់កាលី (Chlor-Alkali Production)	15,146
ការដុតសំណល់	14,944
ការចំរាញ់ប្រេង	14,377
ចំហេះប្រេង និងឧស្ម័ន	7,130
ការបូជាសព	3,768

៣. ការប្រើប្រាស់បារត

រហូតមកទល់បច្ចុប្បន្ន **បារត** ត្រូវបានប្រើប្រាស់ជាទូទៅនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ ផលិតផលមួយចំនួនដែលមានប្រើប្រាស់បារត មានដូចជា ឧបករណ៍អគ្គិសនី និងអេឡិចត្រូនិក ឧបករណ៍វាស់ និងត្រួតពិនិត្យ អំពូលភ្លើងអរដែលមានប្រសិទ្ធភាពថាមពល ថ្នាំពិល ម៉ាស្ការ៉ា ឡេលាបស្បែក និងផលិតផលគ្រឿងសម្អាងដទៃៗផ្សេងទៀតដែលមានផ្ទុកបារត និងផលិតផលប្រើប្រាស់ដទៃៗទៀតដែលសុទ្ធសឹងតែមានប្រើប្រាស់បារតជាសកល។ ក្រៅពីផលិតផលប្រើប្រាស់ ក៏មានសកម្មភាព ឬវិស័យមួយចំនួនមានប្រើប្រាស់បារត ដូចជាវិស័យទន្តសាស្ត្រដែលប្រើប្រាស់បារតសម្រាប់ប៉ះធ្មេញ សកម្មភាពអាជីវកម្មរ៉ែមាសខ្នាតតូច និងលក្ខណៈគ្រួសារត្រូវបានប្រើប្រាស់បារតសម្រាប់ចាប់យកមាស។ លើសពីនេះទៅទៀត ផលិតផលអាហារមួយចំនួនដូចជា ពពួកត្រី ថនិកសត្វរស់នៅលើដីគោក និងផលិតផលមួយចំនួនទៀតដូចជាស្រូវក៏មានផ្ទុកវត្តមានបារតផងដែរ។ បារតក៏ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងបរិក្ខារថែទាំវេជ្ជសាស្ត្រ ដែលភាគច្រើនមានប្រើប្រាស់នៅក្នុងឧបករណ៍វាស់សម្ពាធឈាម និងទែម៉ូម៉ែត្រ បើទោះបីការប្រើប្រាស់បារតនៅក្នុងបរិក្ខារ ក៏ដូចជាឧបករណ៍ទាំងនេះមានការថយចុះក៏ដោយ។

គួរឱ្យកត់សម្គាល់ផងដែរថា ក្នុងចំណោមផលិតផលដែលមានបន្ថែមបារត **ផលិតផលគ្រឿងសម្អាង** ជាផលិតផលដែលត្រូវបានគេរកឃើញថាជាទូទៅមានផ្ទុកបារត ជាពិសេសពពួកផលិតផលឡេលាបស្បែក និងសាប៊ូដុំដូសខ្លួនអោយស។ នៅក្នុង**ផលិតផលគ្រឿងសម្អាងធ្វើអោយស** ជាទូទៅមានផ្ទុកបារតអសរីរាង្គ និងសរីរាង្គ ដែលបារតអសរីរាង្គត្រូវបានប្រើប្រាស់ក្នុងផលិតផលឡេលាបស្បែក និងសាប៊ូដុំដុសខាតស្បែកអោយស ហើយសមាសធាតុបារតសរីរាង្គ (ដូចជា thiomersal ដែលមានផ្ទុកនូវអេទីលបារត (ethyl mercury) និងពពួកអំបិល (phenyl mercuric salts) ត្រូវបានប្រើប្រាស់ជា preservatives ក្នុងផលិតផលម៉ាស្ការ៉ា (mascara) មួយចំនួន។

៤. ផលប៉ះពាល់បារតលើបរិស្ថាន និងសុខភាពមនុស្ស

៤.១ ផលប៉ះពាល់បារតលើបរិស្ថាន

ការសាយភាយបារតចូលទៅក្នុងខ្យល់ភាគច្រើនក្នុងទម្រង់ជា អង្គធាតុឧស្ម័ន (gaseous elemental mercury) ដែលអាចផ្លាស់ទីជាសកលទៅកាន់តំបន់ដែលឆ្ងាយពីប្រភពសាយភាយ។ ការសាយភាយដែលនៅសេសសល់ក្នុងទម្រង់ជាបារតអសរីរាង្គ (gaseous inorganic ionic mercury forms) ដែលមានដូចជា mercuric chloride ឬមានជាប់ទៅភាគល្អិតដែលបានសាយភាយ។ បារតអាចសាយភាយស្ថិតនៅក្នុងបរិយាកាសបានរយៈចម្ងាយប្រហែលពី ១០០ទៅ ១០០០គីឡូម៉ែត្រ ពីប្រភពដើម។



- **ការបំពុលខ្យល់**

បារតរាវ (Elemental) ឬ metallic ជាអង្គធាតុរាវមួយស្ថិតក្នុងសីតុណ្ហភាពបន្ទប់ ហើយមានលក្ខណៈប្រហាក់ប្រហែលទៅនឹងអង្គធាតុរាវដដែទៀតដែរ ដែលហួតចូលទៅក្នុងបរិយាកាស។ កំហាបបារតដែលសាយភាយបារតនៅក្នុងទីកន្លែងបិទជិតអាចកើនខ្ពស់ដល់កម្រិតមួយបង្គគ្រោះថ្នាក់ដល់សុខភាព។ ពេលមនុស្សដកដង្ហើមចូលកាន់តែយូរជាមួយខ្យល់ដែលទទួលរងការបំពុលដោយបារត ហានិភ័យកាន់តែខ្ពស់ដល់សុខភាពរបស់គេ។ លើសពីនេះទៅទៀតបារតដែលស្ថិតលើសម្លៀកបំពាក់ គ្រឿងសង្ហារឹម កំរាលព្រំ និងរបស់របរផ្សេងៗទៀតគឺមានការលំបាក់ក្នុងការសម្អាត។

ប្រភពនៃការសាយភាយបារតចូលទៅក្នុងខ្យល់អាចកើតចេញពីផលិតផលប្រើប្រាស់នៅផ្ទះសំបែងមានដូចជា ទែម៉ូម៉ែត្រ ប៉ារ៉ូម៉ែត្រ និងកុងតាក់បិទបើកភ្លើង។ ប្រភេទអំពូលភ្លើងក្លុយអរមានផ្ទុក

បរិមាណបារតតិចតួចស្ថិតក្នុងទម្រង់ជាឧស្ម័ន និងបរិមាណបារតដ៏ច្រើនស្ថិតក្នុងទម្រង់ជាម្សៅ ឬជាធូលី ដែលអាចបង្កផលប៉ះពាល់នៅពេលធ្លាក់បែកមាននៅក្នុងលំនៅដ្ឋាន។

▪ **ការបំពុលទឹក**

ទឹកគឺជាផ្នែកមួយដ៏សំខាន់សម្រាប់ជីវិតមនុស្ស និងសត្វ។ ការបំពុលទឹកដោយបារតគឺជាបញ្ហាប្រឈមមួយធំសម្រាប់ពិភពលោក។ សកម្មភាពមនុស្សគឺជាកត្តាចម្បងនៃការបំពុលទឹកតាមរយៈការបញ្ចេញសំណល់រាវឧស្សាហកម្ម និងសំណល់រាវចេញពីការធ្វើអាជីវកម្មរ៉ែចូលទៅក្នុងប្រភពទឹកដោយមិនធ្វើប្រព្រឹត្តកម្មសម្អាតបារតជាមុនបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។ ការបំពុលទឹកដោយបារតនេះមិនត្រឹមតែបង្កផលប៉ះពាល់ដល់ប្រភពទឹកទេ ប៉ុន្តែបង្កការបំពុលដល់សត្វរស់នៅក្នុងទឹកដែលជាប្រភពអាហារសំខាន់សម្រាប់មនុស្ស។



៤.២ ផលប៉ះពាល់នៃបារតលើសុខភាពមនុស្ស

បារតគឺសារធាតុគីមីពុលខ្លាំងបំផុត សូម្បីតែទទួលរងប៉ះពាល់តិចតួចក៏ដោយ អាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពមនុស្ស ដូចជាបង្កផលប៉ះពាល់ដល់ប្រព័ន្ធប្រសាទ ប្រព័ន្ធរំលាយអាហារ ប្រព័ន្ធបន្សាំ សួត តម្រងនោម ស្បែក ភ្នែក និងការលូតលាស់ទារកនៅក្នុងផ្ទៃពោះ។ បារតចូលក្នុងខ្លួនមនុស្សតាមរយៈការស្រូបចូលតាមផ្លូវដង្ហើម និងការលេប ហើយការទទួលរង សញ្ញានៃការពុលបារតអាចបង្ហាញក្នុងរយៈពេលខ្លី ឬយូរ អាស្រ័យលើកម្រិតបរិមាណបារតដែលដកដង្ហើមចូល ឬលេបចូល។

នៅទសវត្ស ៥០ មានករណីបំពុលបារតដ៏ធ្ងន់ធ្ងរមួយនៅប្រទេសជប៉ុន ឬ ជម្ងឺមីណាម៉ាតា ដែលបង្កឡើងដោយការបញ្ចេញសំណល់រាវមានផ្ទុកបារតពីរោងចក្រផលិតគីមីរបស់ក្រុមហ៊ុន ជីសូ ចូលទៅក្នុងឆកសមុទ្រមីណាម៉ាតា នៃទីក្រុងមីណាម៉ាតា។ ប្រជាជនជប៉ុនជាច្រើនរស់នៅក្នុងទីក្រុងនោះបានទទួលរងផលប៉ះ

ពាល់ដល់សុខភាពតាមរយៈការទទួលទានផលនេសាទពីក្នុងឆកសមុទ្រមីណាម៉ាតាដែលមានផ្ទុកបារតពី ៥.៦១ ដល់ ៣៥.៧ភាគលាន។ កម្រិតបារតនៅក្នុងសក់ប្រជាជននៅតំបន់នោះមានចំនួនអតិប្បរិមា ៧០៥ភាគលាន ហើយប្រជាជនដែលទទួលរងផលប៉ះពាល់ភាគច្រើនមានអការៈ ដូចជាបាត់បង់សមត្ថភាពគ្រប់គ្រងការធ្វើចលនាសាច់ដុំ ការមើលឃើញ ការស្តាប់ ការហិនក្លិន ការចងចាំ និងញាក់ញ័រ ។ នៅក្នុងរយៈពេល ៣៦ ឆ្នាំកន្លងទៅនេះ មានប្រជាជនទទួលរងគ្រោះចំនួន ២២៥២ ត្រូវបានទទួលស្គាល់ជាផ្លូវការមានជម្ងឺ មីណាម៉ាតា និង ប្រជាជនចំនួន១០៤៣ នាក់ បានស្លាប់។



៥.អនុសញ្ញាមីណាម៉ាតាស្តីពីបារត

នៅឆ្នាំ ២០១០ ដោយពិនិត្យឃើញផលប៉ះពាល់ធ្ងន់ធ្ងរនៃបារតលើសុខភាពមនុស្ស និងបរិស្ថាន កម្មវិធីបរិស្ថានសហប្រជាជាតិបានផ្តួចផ្តើមរៀបចំ **អនុសញ្ញាមីណាម៉ាតាស្តីពីបារត** ដើម្បីការពារសុខភាពមនុស្ស និងបរិស្ថានពីបារត និងសមាធាតុបារត។ ការរៀបចំអនុសញ្ញានេះត្រូវបានឆ្លងកាត់កិច្ចប្រជុំពិភាក្សាយ៉ាងស្វិតស្វាញនៃគណៈកម្មាធិការចរចារអន្តររដ្ឋាភិបាលចំនួន ៥ លើក ក្នុងរយៈពេលបីឆ្នាំចាប់ពីខែមិថុនា ឆ្នាំ ២០១០ ដល់ខែ មករា ឆ្នាំ ២០១៣ ។ បន្ទាប់ពីកិច្ចប្រជុំលើកទី ៥ របស់គណកម្មាធិការចរចារអន្តររដ្ឋាភិបាល អនុសញ្ញាមីណាម៉ាតាស្តីពីបារតត្រូវបានអនុមត័ និងបើកអោយចុះហត្ថលេខានៅថ្ងៃទី ១០-១១ ខែ តុលា ឆ្នាំ ២០១៣ និងចូលជាធរមាននៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៧។ បច្ចុប្បន្ន មានប្រទេស ចំនួន ១៣១ បានផ្តល់សច្ចាប័នចូលជាភាគីនៃអនុសញ្ញាមីណាម៉ាតាស្តីពីបារត។ ដើម្បីចូលរួមជាមួយសហគមន៍អន្តរជាតិក្នុងកិច្ចគាំពារបរិស្ថាន និងសុខភាពមនុស្ស ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាមីណាម៉ាតាស្តីពីបារត នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ ក្នុងសន្និសីទពេញអង្គដែលបានរៀបចំឡើងនៅទីក្រុងគូម៉ាម៉ូតូនៃប្រទេសជប៉ុន និង បានផ្តល់សច្ចាប័នចូលជាភាគីនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ ។

❖ **គោលបំណង**

អនុសញ្ញាមីណាម៉ាតា គឺជាអនុសញ្ញាអន្តរជាតិ ដែលមានគោលបំណងការពារសុខភាពមនុស្ស និងបរិស្ថាន ដែលបណ្តាលមកពីការសាយភាយសារធាតុបារតដោយសកម្មភាពមនុស្ស។

❖ **ភាតព្វកិច្ចជាភាគីនៃអនុសញ្ញា**

- ចាត់វិធានការកាត់បន្ថយ ឬ លុបបំបាត់ការប្រើប្រាស់បារត និងផលិតផលមានបន្ថែមបារត
- ចាត់វិធានការកាតបន្ថយការសាយភាយបារតចូលក្នុងបរិស្ថាន
- ចាត់វិធានការគ្រប់គ្រងការធ្វើពាណិជ្ជកម្ម ការប្រើប្រាស់បារត ផលិតផលមានផ្ទុកបារត និងការសាយភាយសារធាតុបារត
- រៀបចំលិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្រ្តនិងគោលការណ៍ណែនាំបច្ចេកទេសគ្រប់គ្រងសារធាតុបារត និងសំណល់បារតប្រកបដោយសុវត្ថិភាពបរិស្ថាន
- រៀបចំសារពើកណ្ឌសារធាតុបារត និងសំណល់បារត
- រៀបចំរបាយការណ៍អំពីការប្រើប្រាស់ និងការសាយភាយសារធាតុបារត ព្រមទាំងវិធានការគ្រប់គ្រង និងកាត់បន្ថយការសាយភាយសារធាតុបារតចូលក្នុង បរិស្ថានដើម្បីផ្តល់ជូនលេខាធិការដ្ឋាននៃអនុសញ្ញា

❖ **ការអនុវត្ត និងការឧបត្ថម្ភគាំទ្រ**

ក្នុងនាមជាសមាជិកនៃអនុសញ្ញាមីណាម៉ាតា កម្ពុជាអាចស្នើសុំការឧបត្ថម្ភគាំទ្របន្ថែម ដើម្បីបំពេញនូវកាតព្វកិច្ចសំដៅសម្រេចបាននូវគោលបំណងនៃអនុសញ្ញានេះ។ រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ កម្ពុជាបានទទួលការគាំទ្រជាថវិកា និងបច្ចេកទេសដើម្បីចូលរួមចំណែកក្នុងការសម្រេចបាននូវគោលដៅនៃអនុសញ្ញានេះ និងរៀបចំនូវសកម្មភាពនានាមានជាអាទិ៍៖

- បានរៀបចំរបាយការណ៍វាយតម្លៃស្តីពីបារតនៅកម្ពុជា
- បានធ្វើបច្ចុប្បន្នភាពរបាយការណ៍សារពើភ័ណ្ឌស្តីពីបារត
- បានរៀបចំការវាយតម្លៃសមត្ថភាពស្ថាប័ន និងលិខិតបទដ្ឋានដែលពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញា
- បានកំណត់សកម្មភាពអាទិភាពសម្រាប់ការអនុវត្តអនុសញ្ញាមីណាម៉ាតា
- បានរៀបចំផែនការជាតិគ្រប់គ្រងសំណល់បារត
- បានរៀបចំផែនការយុទ្ធសាស្រ្តគ្រប់គ្រងបារតនៅក្នុងអាជីវកម្មរ៉ែមាសខ្នាតតូច
- បានរៀបចំផែនការសកម្មភាពគ្រប់គ្រងការសាយភាយបារតនៅកម្ពុជា

- បានរៀបចំគោលការណ៍ណែនាំបច្ចេកទេសគ្រប់គ្រងសំណល់បារតប្រកបដោយសុវត្ថិភាពបរិស្ថាន
- បានរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយអំពីការអនុវត្តអនុសញ្ញា និងផលប៉ះពាល់បារតដល់សុខភាព និងបរិស្ថាន

❖ ជំហានរបស់រដ្ឋាភិបាលក្នុងការអនុវត្តអនុសញ្ញា

- កាត់បន្ថយការសាយភាយបារតពីប្រភពជាក់លាក់ចូលក្នុងបរិស្ថាន
- កាត់បន្ថយ និងលុបបំបាត់ការផលិត ការប្រើប្រាស់ ការនាំចេញ និងការនាំចូលផលិតផលមានបន្ថែមបារត
- លុបបំបាត់ការប្រើប្រាស់បារតនៅក្នុងអាជីវកម្មរ៉ែមាសខ្នាតតូច
- ពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងសំណល់បារត
- ពង្រឹងសមត្ថភាពស្ថាប័នពាក់ពន្ធ័ក្នុងការអនុវត្តអនុសញ្ញា
- លើកកម្ពស់ ការយល់ដឹងសាធារណៈអំពីផលប៉ះពាល់ពីបារត

ផ្នែកទី ៥
ការបង្កើតភាពសក្តិសម

បង្កួយហោះ ឬ បង្កួយស្លាប (Gliding/Flying Lizard)

បង្កួយហោះ ឬបង្កួយស្លាបជាឧរង្គសត្វ ដែលមានស្បែកពិសេសនៅឆ្អឹងជំនីអាចត្រដាង ដើម្បីទប់សម្រាលខ្លួន នៅពេលវាហក់ពីទីតាំង (ដើមឈើ) មួយទៅទីតាំង មួយ ទៀត។ ជាទូទៅបង្កួយហោះញី ឬឈ្មោលអាចបែងចែកបាននៅពេលពេញវ័យតាមរយៈការអង្កេតបួរក (ឈ្មោលមានបួរកវែងជាងញី) ពណ៌ខ្លួន (ឈ្មោលមានពណ៌ច្បាស់ជាងញី) និងប្រវែងខ្លួន (ភាគច្រើនឈ្មោលមាន ប្រវែងខ្លួន វែងជាងញី)។ បង្កួយហោះស៊ីសត្វល្អិតជាអាហារ ជាពិសេសស្រមោច ខ្មោ ចង្រិត និងកណ្តៀរជាអាហារ។ល។ យោងតាមរបាយការណ៍ជាតិស្តីពីស្ថានភាពជីវៈចម្រុះនៅកម្ពុជា ឆ្នាំ២០១៦ ឧរង្គសត្វនៅកម្ពុជាមាន ១៧៣ប្រភេទ ហើយបច្ចុប្បន្នចំនួននេះបានកើនឡើងដល់ ១៨០ប្រភេទ។ ក្នុងចំណោមឧរង្គសត្វទាំង ១៨០ប្រភេទនេះ ក៏មានបង្កួយហោះចំនួន៣ប្រភេទផងដែរគឺ (១)Draco indochinensis Smith, 1928, (២)Draco maculatus Grey, 1845 និង (៣)Draco taeniopterus Günther, 1861។

១. Draco indochinensis Smith, 1928 គឺជាប្រភេទបង្កួយហោះដែលមានទីជម្រកជាព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោង។ បង្កួយនេះមានខ្នងពណ៌ត្នោតប្រផេះ និងមានស្នាមអុជៗ ស្បែកគល់កមានពណ៌ខ្មៅ ហើយវាអាចហក់ទំលាក់ខ្លួនពីទីតាំង ខ្ពស់ទៅទីតាំងទា បៗ ដូចប្រភេទតុកកែហោះដែរ។ បង្កួយនេះមានវត្តមានតែនៅប្រទេសកម្ពុជា និងប្រទេសវៀតណាមប៉ុណ្ណោះ។ នៅកម្ពុជា បង្កួយនេះ ត្រូវបានកត់ត្រាដំបូងនៅឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" ក្នុងឆ្នាំ១៩២៨ និងកត់ត្រាឡើងវិញនៅឧទ្យានជាតិវីរៈជ័យ និងដែនជម្រកសត្វព្រៃកែវសីមាក្នុងឆ្នាំ២០០៣។

២. Draco maculatus Grey, 1845 គឺជាប្រភេទបង្កួយហោះដែលរស់នៅតាមតំបន់ព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃរបោះ។ វាមានខ្នងពណ៌ប្រផេះ មានស្បែកកនិងចុងស្លាបពណ៌លឿង។ បច្ចុប្បន្ន បង្កួយនេះនៅពុំទាន់បានសិក្សាច្បាស់លាស់នៅឡើយ។ អ្នកស្រាវជ្រាវជឿជាក់ថាអាចមានប្រភេទថ្មីមួយចំនួនក្រោមឈ្មោះ Draco maculatus នេះ ដែលអ្នកវិទ្យាសាស្ត្រកំពុងសិក្សាពីធនធានពន្ធុ ដើម្បីបញ្ជាក់អត្តសញ្ញាណពិតប្រាកដ។ របាយបង្កួយ នេះ ត្រូវបានរកឃើញនៅភាគខាងត្បូងប្រទេសចិន ភូមា ថៃ ឡាវ កម្ពុជា វៀតណាម និងម៉ាឡេស៊ី។ នៅប្រទេសកម្ពុជា បង្កួយនេះត្រូវបានគេរកឃើញនៅតំបន់ជួរភ្នំក្រវាញភាគខាងលិច និងតាមកោះមួយចំនួនដូចជាកោះកាពិ ក្នុងខេត្ត កោះ កុង នាឆ្នាំ២០០៧។

៣. Draco taeniopterus Günther, 1861 គឺជាប្រភេទបង្កួយហោះមួយទៀតដែលរស់នៅតាមតំបន់ព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោង។ ជាទូទៅវាមានខ្នងពណ៌បៃតងត្នោត មានស្បែកកនិងចុងស្លាបពណ៌ឈាមជ្រូក។ របាយនៃប្រភេទបង្កួយនេះ ត្រូវបានរកឃើញនៅភាគខាងត្បូងប្រទេសភូមា ក្នុងប្រទេស ថៃ កម្ពុជា ភាគខាងត្បូងប្រទេស វៀតណាម និងឧបទ្វីបម៉ាឡេស៊ី។ នៅប្រទេសកម្ពុជា បង្កួយ នេះត្រូវបានរកឃើញតែនៅតំបន់ជួរភ្នំក្រវាញប៉ុណ្ណោះក្នុងឆ្នាំ២០០៧៕

ការរកឃើញឡើងវិញនូវខ្យងគោកយក្សកម្ពុជា Cambodian Giant Land Snail (Bertia cambojiensis)

ខ្យងគោកយក្សកម្ពុជា (Bertia cambojiensis) គឺជាប្រភេទខ្យងដែលមានសម្បកធំ រស់នៅលើគោកក្នុងព្រៃស្រោង និងត្រូវបានពិពណ៌នាដំបូងដោយអ្នកធម្មជាតិវិទូបារាំងឈ្មោះ Henri Mouhot នៅឆ្នាំ១៨៦០ ពីកន្លែងមួយឈ្មោះថា Brelum (ជាភាសាបារាំង) នៃប្រទេសកម្ពុជា ប៉ុន្តែដោយសារថា ចំណុចនិយាមការនៃទីតាំងនោះពុំមានការកត់ត្រាច្បាស់លាស់ ទើបអ្នកស្រាវជ្រាវក្រោយៗមកមានការលំបាកក្នុងការកំណត់ទីកន្លែងជាក់លាក់ណាមួយក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ ជាងនេះទៀត ព័ត៌មានអំពីប្រភេទខ្យងគោកយក្សកម្ពុជានេះបានបាត់ស្ងាត់ឈឹងដោយសារកង្វះការស្រាវជ្រាវ និងសង្គ្រាមស៊ីវិលក្នុងប្រទេស ហើយប្រការនេះនាំឱ្យមានអ្នកវិភាគខ្លះនិយាយថា ប្រភេទខ្យងនេះពុំមានវត្តមាននៅកម្ពុជាទៀតឡើយ (Sutcharit et al., 2019)។

ទោះជាយ៉ាងនេះក្តី មន្ត្រីក្រសួងបរិស្ថានសហការជាមួយអ្នកជំនាញនៃមជ្ឈមណ្ឌលអភិរក្សជីវៈចម្រុះនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានប្រទះឃើញប្រភេទខ្យងនេះក្នុងដែនជម្រកសត្វព្រៃកែវសីមាក្នុងខេត្តមណ្ឌលគីរី នាឆ្នាំ២០១៨ ហើយជាលទ្ធផលបានប្រមូលសំណាកមករក្សាទុកនៅសារមន្ទីរសត្វវិទ្យាជីវៈចម្រុះនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ តាមរយៈរបកកំហើញឡើងវិញនេះ ក្រុមស្រាវជ្រាវក៏បានបោះពុម្ពផ្សាយពីប្រភេទខ្យងយក្សនេះក្នុងទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រ CJNH នៅឆ្នាំ២០១៩។ របកគំហើញនេះគឺជាការបញ្ជាក់ឱ្យកាន់តែច្បាស់ថា ខ្យងគោកយក្សកម្ពុជាពិតជាមានវត្តមាននៅលើទឹកដីនៃប្រទេសកម្ពុជា ហើយក៏ស្របទៅតាមការដាក់ឈ្មោះរបស់អ្នកស្រាវជ្រាវដំបូងថា Bertia cambojiensis ដែលជាការសម្គាល់ទីតាំងភូមិសាស្ត្រប្រទេសកម្ពុជា (cambojiensis)។ ទោះបីជាមានការបញ្ជាក់ពីការរកឃើញឡើងវិញនៃប្រភេទខ្យងនេះក្នុងប្រទេសកម្ពុជាក៏ដោយ ក៏ព័ត៌មានអំពីរបាយនៃប្រភេទ ចំនួនសរុប (ប៉ូពុយឡាស្យុង) និងកត្តាគំរាមកំហែងលើប្រភេទខ្យងនេះនៅមានកម្រិតនៅឡើយ ដែលប្រការទាំងនេះតម្រូវឱ្យមានការសិក្សាស្រាវជ្រាវបន្ថែម និងចាត់វិធានការការពារឱ្យមានប្រសិទ្ធភាព។

សូមបញ្ជាក់ថា ខ្យងគោកយក្សកម្ពុជានាពេលបច្ចុប្បន្នមានចំណាត់ថ្នាក់ជាប្រភេទសត្វជិតផុតពូជបំផុតជាសាកលក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ពីព្រោះ ខ្យងនេះមានវត្តមានតិចតួចប៉ុណ្ណោះក្នុងប្រទេសវៀតណាម និងពុំមានទិន្នន័យក្នុងប្រទេសកម្ពុជាឡើយ៕

ចកវ៉ែកកម្ពុជា ឬចកវ៉ែកភ្នំក្រវាញ

ចកវ៉ែកកម្ពុជា ឬចកវ៉ែកភ្នំក្រវាញ Cambodian Laughingthrush (Garrulax ferrarius) ចកវ៉ែកកម្ពុជា ជាប្រភេទសត្វស្លាបដែលមានវត្តមានតែនៅតំបន់ជួរភ្នំក្រវាញនៃប្រទេសកម្ពុជាតែប៉ុណ្ណោះ (Endemic)។ សត្វស្លាបប្រភេទនេះត្រូវបានរកឃើញដំបូងនៅឆ្នាំ១៩២៩ (Riley, 1930) ហើយបញ្ជាក់ពីវត្តមានវានៅកម្ពុជាឡើងវិញនៅក្នុងឆ្នាំ២០០០ (Steinheimer et al., 2000)។ ទោះជាយ៉ាងនេះក្តីនៅប្រទេសកម្ពុជាសំណាកស្បែកស្ងួតសម្រាប់គោលបំណងវិទ្យាសាស្ត្រដំបូងត្រូវបានប្រមូលពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៅឆ្នាំ២០១០ (Chhin, 2010) និងកំពុងទុកនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ជាទូទៅ សត្វស្លាបប្រភេទនេះមានវត្តមាននៅតំបន់ភ្នំរយៈកម្ពស់ខ្ពស់(ចាប់ពី៧០០ម៉ែត្រឡើងទៅ) នៃតំបន់ជួរភ្នំក្រវាញមានដូចជា ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដែនជម្រកសត្វព្រៃភ្នំសំកុស និងឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល៕

ផ្នែកទី ៦
ចម្រៀងបរិស្ថាន

ព្រះថោងនាងនាគ

(១) ឱ!បដិមា ព្រះថោងនាងនាគ ប្រណិតឥតប្រៀប ផុសកៀកជលសា

ក្រុងព្រះសីហនុ ស្កឹមស្កៃអស្ចារ្យ សាងដោយខេមរា យុគសន្តិភាព។

(២) នឹកដល់សាវតារ ព្រះថោងមានឫទ្ធ គូព្រេងជីវិត នឹងព្រះនាងនាគ

បង្កើតពង្សខ្មែរ ភ្នំដាជាធាតុ ដើមកំណើតជាតិ នគរគោកធ្លក។

(បន្ទរ) អាល័យភ្នំដា គោកធ្លកបុរី កាលបងថ្នមស្រី ក្រោមម្លប់ដើមធ្នង់

ភក្ត្រអូនញញឹម នេត្រាស្រទន់ វិញ្ញាណបងលង់ មន្តស្នេហ៍វរលក្ខណ៍។

(៣) ស្រមៃថាបង ព្រះថោងតោងស្បៃ ព្រះនាងអូនស្រី ទៅឋានភុជង្គនាគ

ស្ម័គ្រស្មោះមេត្រី ភក្តីឥតងាក ចិន្តាឥតប្រៀក កាយកៀកនិរន្តរ៍៕

និពន្ធទំនុកច្រៀង ៖ ឯកឧត្តម ជួប ប៉ារីស៍

និពន្ធបទភ្លេង ៖ សួង ទិតធានី (លោកគ្រូបា)

ច្រៀងដោយ៖ ៖ ម៉ៅ ហាជី



លង់ស្នេហ៍បន្ទាយមានជ័យ

(១) ឱបន្ទាយឆ្មារ ប្រាសាទល្អឯក សំងំក្នុងខេត្ត បន្ទាយមានជ័យ
ក្បាច់រចនាខ្មែរ សែនល្អពេកក្រៃ អរគុណាចរណៃ ជូនបងទស្សនា។

(២) អាងត្រពាំងថ្ម សម្រស់ល្អប្លែក មើលពីប៉មដែក ឃើញហ្វូងក្រសារ
ក្រៀលរនាលពណ៌ ប្រលោមស្នេហា នាំចិត្តរៀមរ៉ា ក្ដួចស្នេហ៍លើស្រី។

(បន្ទរ) សិរីសោភ័ណ ក្រុងទេពនិមិត្ត ទេសភាពស្អាតពិត ជិតជាប់ដួងចៃ
ឱភ្នំជញ្ជាំង ចងភ្ជាប់និស្ស័យ បងសុំស្នេហ៍ថ្លៃ ក្បែរផ្ទាំងថ្មធំ។

(៣) បន្ទាយមានជ័យ ហឫទ័យជំពាក់ នឹកកែវវរលក្ខណ៍ ភក្ដិស្រស់សទន់
ពេលអូនឃ្លាតទៅ នៅក្លិនឆោមយង់ អូនអើយបងលង់ ក្នុងសម្រស់ស្រី៕

និពន្ធទំនុកច្រៀង ៖ ឯកឧត្តម ជួប ប៉ារីស៍
និពន្ធបទភ្លេង ៖ សួង ទិតធានី (លោកគ្រូបា)
ច្រៀងដោយ៖ ៖ ជួន ចាន់ទិត្យា

Website: www.moe.gov.kh **Facebook:** Ministry of Environment **Youtube:** MoECambodia
TikTok: MoECambodia **App:** MoECambodia